សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

## ( Online )

ស្រាវជ្រាវពីថ្ងៃទី ០២ ខែ ០មេសា ឆ្នាំ ២០១៨ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៨


ស្រាវជ្រាវដោយ | សាស្ត្រាចារ្យណែនាំ

និស្សិតឈ្មោះ **កញ្ញា. សេខ សុវណ្ណារុន** | **បណ្ឌិត សឿន សោភ័ណ**

**លោក. តិន ទិនសៃ**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ** | ឆ្នាំចូលសិក្សា ២០១៤

ជំនាន់ទី ១១ | ឆ្នាំសរសេរសារណា ២០១៨

# អារម្ភកថា

ចាប់តាំងពីប្រទេសកម្ពុជាទទួលបានសន្តិភាពពេញលេញនៅ ថ្ងៃទី ២៣ ខែតុលា ឆ្នាំ១៩៩១ ដែលកើតចេញពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសរួចមក ប្រទេសនេះក៏បានខិតខំអភិវឌ្ឍសង្គមរបស់ខ្លួនឱ្យរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃដោយសារតែការរក្សាបាននូវ ស្ថេរភាពនយោបាយក្នុងស្រុក។ មិនត្រឹមតែប៉ុណ្ណោះ រាជរដ្ឋាភិបាលក៏បានអភិវឌ្ឍសេដ្ឋកិច្ចឱ្យមានដំណើរការល្អដោយរក្សាបាននូវស្ថេរភាពនៃកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំក្នុងរង្វង់អត្រា ៧% ផងដែរ។ដោយមើលឃើញភាពរីកចម្រើនរបស់វិស័យរដ្ឋបាលសាធារណៈកន្លងមក ខ្ញុំបាទ នាងខ្ញុំ ដែលជានិស្សិតនៃ សកលវិទ្យាល័យភូមិន្ទនីតិសាស្រ្តនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ថ្នាក់បរិញ្ញាបត្រជំនាញរដ្ឋបាលសាធារណៈក៏មានចំណាប់អារម្មណ៍ទៅលើកំណែទម្រង់នៃសេវានេះ ដោយពួកយើងបានធ្វើការជ្រើសរើសនូវ ប្រធានបទមួយដែលទាក់ទងទៅនិងរដ្ឋាភិបាលអេឡិចត្រូនិក(E-government) ស្តីអំពី **ការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម** ដើម្បីជាប្រធានបទនៃសារណាបទបញ្ចប់ការសិក្សា។ កម្មវិធីនេះ ជាកម្មវិធីថ្មីមួយទើបតែដាក់ឱ្យដំណើរការនៅក្នុងឆ្នាំ២០១៦ថ្មីៗនេះ ដោយកម្មវិធីនេះស្ថិតនៅក្រោមជំនួយឧបត្ថម្ភរបស់រដ្ឋាភិបាលជប៉ុនសហការណ៍ជាមួយរដ្ឋាភិបាលកម្ពុជាសំដៅជម្រុញឱ្យដំណើរការនៃការចុះបញ្ជីយានយន្តនៅក្នុងប្រទេសកម្ពុជាកាន់តែមានភាពងាយស្រួល ទូលំទូលាយ ហើយជាពិសេសគឺរដ្ឋាភិបាលមានភាពងាយស្រួលនៅក្នុងការគ្រប់គ្រងយានយន្តនៅក្នុងប្រទេស។

យើងខ្ញុំសង្ឃឹមថា ការសិក្សាស្រាវជ្រាវទៅលើ ប្រធានបទមួយនេះអាចនិងជួយសម្រួលចម្ងល់ទៅដល់បងប្អូនសិស្សានុសិស្ស និស្សិត ប្រជាជនខ្មែរទាំងឡាយដែលចង់ស្វែងយល់អំពីការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនៅក្នុងប្រទេសកម្ពុជា។

យើងខ្ញុំក៏សូមធ្វើការអភ័យទោសទុកជាមុនចំពោះការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះ ក្នុងករណីដែលមានការខ្វះចន្លោះនូវព័ត៌មានណាមួយ និងការបកស្រាយមិនបានក្បោះក្បាយជាដើម។ ដូច្នេះសូមបងប្អូនជួយរិះគន់ក្នុងន័យស្ថាបនាទៅលើចំណុចខ្វះខាតទាំងនោះ ហើយយើងនិងធ្វើការទទួលយក នឹងកែរតម្រូវជាក្រោយសូមអគុណា។

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរ ឈ្មោះ ភិន វិនសៃ និង ក. សេង សុវណ្ណារុន ដែលជាដៃគូរសរសេរសារណាបទ និងជានិស្សិតនៃសកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ថ្នាក់បរិញ្ញាបត្រជំនាញរដ្ឋបាលសាធារណៈ ឆ្នាំសិក្សា ២០១៧ -២០១៨ សូមធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

លោកឪពុក សូ ឌី និង អ្នកម្តាយ ហែម ណារ៉ែន របស់ខ្ញុំឈ្មោះ ភិន វិនសៃ និង លោកឪពុក អ៊ាម គឹមសាយ និងអ្នកម្តាយ ប៊ិ វណ្ណា របស់នាងខ្ញុំដែលជាអ្នកមានគុណនៃពួកយើងទាំងពីរ ដោយបានផ្តល់កំណើតដល់ពួកយើងឱ្យបានឃើញពន្លឺថ្ងៃ មើលថែទាំតាំងពីបាតជើងក្រហម រហូតផ្តល់ឱកាសឱ្យពួកយើងបានចូលសិក្សាក្រេបយកចំណេះដឹងតាំងពីបឋមសិក្សារហូតដល់ ថ្នាក់បរិញ្ញាបត្រ ដោយបានទំនុកបំរុងកូនគ្រប់សព្វបែបយ៉ាងតាំងពី សម្ភារៈសិក្សា សម្លៀកបំពាក់ គ្រឿងឧបភោគបរិភោគ និងប្រាក់កាក់ចាយវាយប្រចាំថ្ងៃ ដោយមិនរអ៊ូរទាំព្រោះតែការស្រឡាញ់ចង់ឃើញកូនមានអនាគតល្អ មានកិត្តយស មុខមាត់នៅក្នុងសង្គម ដោយមិនចង់ឱ្យកូនជួបការលំបាកដូចលោកទាំងពីរដែលបានហែលឆ្លងកន្លងមកនេះទេ។

ឯកឧត្តមសាកលវិទ្យាធិការ **លុយ ចន្ធា** ដែលបានលះបង់ពេលវេលា កម្លាំងកាយចិត្តនៅក្នុងការដឹកនាំគ្រប់គ្រងសាកលវិទ្យាល័យទាំងមូលឱ្យមានដំណើរការទៅយ៉ាងរលូន ហើយពួកយើងដែលជានីស្សិតនៃសាកលវិទ្យាល័យនេះក៏មានមោទនភាពដូចគ្នានៅពេលដែលស្ថាប័ននានាជាច្រើនមានការទទួលស្គាល់ពួកយើង។

**បណ្ឌិត សឿន សោភ័ណ** ជាសាស្រ្តាចារ្យដែលបានលះបង់ពេលវេលាដ៏មានតម្លៃនៅក្នុងការជួយបង្ហាត់បង្ហាញទិសដៅនៅក្នុងការសិក្សាស្រាវជ្រាវមួយនេះឱ្យមានលក្ខណៈរលូនទៅមុខ បើសិនជាគ្មានការជួយណែនាំរបស់លោក ម្ល៉េះការសិក្សាស្រាវជ្រាវរបស់ពួកយើងមិនអាចទទួលបានជោគជ័យដោយងាយស្រួលគ្មានឧបសគ្គដូច្នេះបានឡើយ។

លោក លោកស្រីសាស្រ្តាចារ្យទាំងអស់នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចដែលបានលះបង់ពេលវេលា និងកម្លាំងកាយចិត្តនៅក្នុងការបង្រៀនពួកយើងតាំងពីឆ្នាំមូលដ្ឋានរហូតមក។ ការបង្រៀន ក៏ដូចជាការដាក់កិច្ចការស្រាវជ្រាវរបស់លោកទើបពួកយើងអាចមានឱកាសវិវឌ្ឍសម្ថភាពរបស់ខ្លួនឯងរហូតទទួលបានឱកាសនៅក្នុងការធ្វើសារណាបទនេះហើយនឹងមានចំនេះដឹងអាចផ្អែកច្បាប់អាចនិយាយតទល់ជាមួយគេបាន។

# មាតិកា

ទំព័រ

សេចក្តីផ្តើម ........................................................................................................ ១
១. លំនាំបញ្ហា ........................................................................................................ ១
២. ចំណោទបញ្ហា ........................................................................................................ ៣
៣. ដែនកំណត់ និងវិសាលភាព ........................................................................................................ ៤
៤. គោលបំណងនៃការស្រាវជ្រាវ ........................................................................................................ ៤
៥. វិធីសាស្រ្តនៃការស្រាវជ្រាវ ........................................................................................................ ៤
៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........................................................................................................ ៥

## ជំពូក ១

## រំលឹកទ្រឹស្តី

១.១. និយមន័យ ........................................................................................................ ៦
១.២.គោលបំណងនៃការបង្កើត ........................................................................................................ ៦
១.៣.ប្រវត្តិនៃការចុះបញ្ជីយានយន្តនៅកម្ពុជា ........................................................................................................ ៦
១.៤. ផលប្រយោជន៍ដែលទទួលបាន ........................................................................................................ ៨
១.៥. ការអនុវត្តនៅក្នុងប្រទេសមួយចំនួន ........................................................................................................ ១០
៥.១. ការចុះបញ្ជីយានយន្តប្រទេសអូស្រ្តាលី ........................................................................................................ ១០
៥.២.ការចុះបញ្ជីយានយន្តរបស់ឥណ្ឌា ........................................................................................................ ១២
៥.៣.ការចុះបញ្ជីនៅសហរដ្ឋអាមេរិក ........................................................................................................ ១២
៥.៤. ការចុះបញ្ជីយានយន្តរបស់រដ្ឋកាលីហ្វ័រញ៉ា ........................................................................................................ ១៣

## ជំពូកទី ២

## ទិដ្ឋភាពទូទៅនៃការចុះបញ្ជី

២.១. សមិទ្ធិផលដែលសម្រេចបានរបស់ក្រសួង ........................................................................................................ ១៤
២.២.ការចុះបញ្ជីយានយន្តនៅក្នុងកម្ពុជា ២០១៦ ........................................................................................................ ១៧
២.២.១. ប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជី ........................................................................................................ ១៨
២.៣. អង្គភាពដែលទទួលខុសត្រូវ ........................................................................................................ ១៩
២.៣.១. សមាសភាព ........................................................................................................ ២០
២.៣.២. តួនាទី និងភារៈកិច្ច ........................................................................................................ ២០
២.៣.១. ភាតព្វកិច្ចក្រោយដាក់ពាក្យ ........................................................................................................ ២០

២.៣.២. តួនាទីរបស់មន្ត្រី ........ ២០
២.៣.៣. ផ្ទៀងផ្ទាត់ ឯកសារដើម និងផ្តល់ផ្លាក់លេខ ........ ២១

## ជំពូកទី ៣

## ការអនុវត្តការចុះបញ្ជីយានយន្ត

៣.១. ការផ្សព្វផ្សាយ ........ ២២
៣.១.១. តាមទូរទស្សន៍ វិទ្យុ ប្រព័ន្ធសង្គម ........ ២២
៣.១.២. ការធ្វើសិក្ខាសាលា ........ ២២
៣.២. នីតិវិធីនៃការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ........ ២៥
៣.២.១. ជំហានដំបូង Vechicle.mpwt.gov.kh ........ ២៥
៣.២.២. ការបង្កើតគណនីប្រើប្រាស់ ឬកត់ត្រាចូលប្រព័ន្ធ ........ ២៦
៣.២.៣. ការជ្រើសរើស ទិញ នឹងចុះបញ្ជី ........ ២៨
២.៣.១. ព័ត៌មានផ្ទាល់ខ្លួន ........ ២៩
២.៣.២. បញ្ជាក់លេខ និងទម្រង់ផ្លាក់លេខ ........ ៣០
២.៣.៣. ព័ត៌មានរថយន្ត ........ ៣១
២.៣.៤. ការវិភាគមកទទួលបណ្ណ និងផ្លាកលេខ ........ ៣១
២.៣.៥. ឯកសារភ្ជាប់ដែលត្រូវយកមកជាមួយ ........ ៣៣
២.៣.៦. ផ្ទៀងផ្ទាត់ព័ត៌មាន និងឯកសារយោង ........ ៣៣
២.៣.៧. ជម្រើសបង់ប្រាក់ និងតម្លៃសេវា ........ ៣៣
៣.៣. យន្តការនៃការត្រួតពិនិត្យទៅលើការអនុវត្ត ........ ៣៤
៣.៣.១. ប្រសិទ្ធិភាពនៃការចុះបញ្ជី ........ ៣៧
៣.៣.២. កម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋ ........ ៣៨
៣.៣.៣. ការចូលរួមរបស់ដៃគូរអភិវឌ្ឍ ........ ៣៨
៣.៤. យន្តការក្នុងការលើកទឹកចិត្តដៃគូរអភិវឌ្ឍ ........ ៤០
៣.៥. គុណសម្បត្តិ នឹងគុណវិបត្តិ ........ ៤១

## ជំពូកទី ៤

## ពិភាក្សាបញ្ហាប្រឈម និងដំណោះស្រាយ

៤.១. បញ្ហាប្រឈម ........ ៤៣
៤.២. ដំណោះស្រាយ ........ ៤៣
សេចក្តីសន្និដ្ឋាន ........ ៤៤

អនុសាសន៍.................................................................................................................... ៩៦
ឯកសារយោង
បញ្ជីឧបសម្ព័ន

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

នៅក្នុងពិភពលោកយើងនេះមានការអភិវឌ្ឍន៍លើគ្រប់វិស័យទាំងអស់មិនថា វិស័យសាធារណៈនិងវិស័យឯកជន។ នៅក្នុងបណ្តាលប្រទេសមួយចំនួនបាន ធ្វើការប្រើប្រាស់នូវភាពជឿនលឿនផ្នែកបច្ចេកវិទ្យា ដើម្បីធ្វើការអភិវឌ្ឍប្រទេសរបស់ខ្លួនឱ្យមានភាពរីកចម្រើនទៅលើវិស័យសាធារណៈ។ ក្នុងគោលបំណងដើម្បីធ្វើឱ្យការបម្រើ សេវាសាធារណៈជូនដល់ប្រជាពលរដ្ឋរបស់ខ្លួនបានកាន់តែខិតជិតប្រជាពលរដ្ឋ។ ម្យ៉ាងវិញទៀត នៅក្នុងពេលបច្ចុប្បន្ននេះ យើងសង្កេតឃើញថាប្រជាពលរដ្ឋមានចំណេះដឹងក្នុងការប្រើប្រាស់បច្ចេកវិទ្យាបានល្អប្រសើរជាងពីមុនបានច្រើនគួរសមដែរ ការប្រើប្រាស់បច្ចេកវិទ្យានៅក្នុង វិស័យសាធារណៈបានជួយរដ្ឋាភិបាល សម្រាប់ការគ្រប់គ្រងប្រទេសឱ្យមានភាពទំនើបជឿនលឿនតាមបណ្តាលប្រទេសដែលមានភាពរីកចម្រើនខ្លាំងទៀតផង។ ដោយយោងទៅតាមសមិទ្ធិផលដែលយើងសង្កេតឃើញ នៅបណ្តាលប្រទេសដែលមានភាពរីកចម្រើនដោយសារតែមានការចូលរួមប្រើប្រាស់បច្ចេកវិទ្យាទំនើបទៅលើវិស័យសាធារណៈនោះបានធ្វើឱ្យប្រទេសកម្ពុជាយើងនៅពេលបច្ចុប្បន្ននេះបានយកចំណុចនោះមកអនុវត្តស្របពេលជាមួយនឹងការរីកចម្រើន កម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋមានការរីកចម្រើន។

ជាក់ស្តែងប្រទេសកម្ពុជាយើង គឺជាប្រទេសមួយដែលទទួលរងនូវសង្គ្រាមជាច្រើនលើកច្រើនសារដែលធ្វើឱ្យបាត់បង់នូវហេដ្ឋារចនាសម្ព័នជាច្រើន រួមទាំងបានបាត់បង់នូវធនធានមនុស្សដែលមានសមត្ថភាពល្អៗ។ យោងទៅតាមប្រវត្តិសាស្រ្តខ្មែរសម័យការដែលមានសង្គ្រាមរហូតបណ្តាលឱ្យមានការបាត់បង់នូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈច្រើនជាងគេនោះគឺ សង្គ្រាមដែលកើតឡើងនៅក្នុងរបបប្រល័យពូជសាសន៍ សម័យនោះបានធ្វើការស្លាប់ប្រជាពលរដ្ឋរបស់ខ្លួនស្ទើរតែអស់គ្មានសល់ និងបានបំផ្លាញនូវហេដ្ឋារចនា សម្ព័ន្ធដែលបានសេសសល់ពីសម័យ សង្គមរាស្រ្តនិយម។ ក្រោយពីពេលនោះប្រទេសជាតិរបស់យើងបានរួចផុតពីរបបដល់ឃោរឃៅមួយនេះ ហើយយើងក៏បានធ្វើការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈឡើងវិញជាបណ្តើរៗ ដើម្បីដឹងនាំប្រទេសជាតិឡើងវិញ។ បន្ទាប់មកនៅក្នុងឆ្នាំ ១៩៩៣ ប្រទេសកម្ពុជាយើងបានធ្វើ ការរៀបចំការបោះឆ្នោត ដោយមានការរៀបចំដោយ **អ៊ុន តាក់** សម្រាប់ជ្រើសរើសរដ្ឋាភិបាលមកធ្វើ ការដឹកនាំប្រទេសឱ្យមានភាពរីកចម្រើន និងមានស្ថេរភាព ហើយក៏មានអាណិត្តិ (៥) ប្រាំឆ្នាំម្តង។

នៅក្នុងអាណិត្តិទី៥ នេះរដ្ឋាភិបាលបានធ្វើការជ្រើសរើសការដឹកនាំបែបថ្មីមួយដែលគេហៅថា រដ្ឋាភិបាលទំនើប ឬរដ្ឋាភិបាលអេឡិចត្រូនិចដែលរដ្ឋាភិបាលនេះជាការដឹកនាំបែបថ្មីមួយដែលគេប្រើប្រាស់បច្ចេកវិទ្យាច្រើន នៅក្នុងការបង្វិតសេវាសាធារណៈឱ្យបានជិតជាមួយនឹងប្រជាពលរដ្ឋរបស់ខ្លួន។រដ្ឋាភិ

បាលទំនើប ឬ រដ្ឋាភិបាលអេឡិចត្រូនិចនេះគឺ ជាការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យាទំនាក់ទំនង (ICTs) ដើម្បីកែលម្អសកម្មភាពរបស់អង្គការវិស័យសាធារណៈ។ រដ្ឋាភិបាលអេឡិចត្រូនិចនេះបានដាក់ឱ្យមានដំណើរការស្ទើតែគ្រប់វិស័យនៅគ្រប់ក្រសួងស្ថាប័នរបស់រដ្ឋទាំងអស់រៀចំឱ្យមានគេហទំព័រនៅតាមសាមីក្រសួងនីមួយៗជាច្រើនដើម្បីបង្ហាញពីសកម្មភាព ភារកិច្ច និងសមិទ្ធិផលដែលក្រសួងនីមួយៗបានសម្រេចនាពេលកន្លងមក។ រដ្ឋាភិបាលអេឡិចត្រូនិចនេះ និងធ្វើបច្ចុប្បន្នភាពនូវរាល់ បញ្ជីអត្រានុកូលដ្ឋាន បញ្ជីកម្មសិទ្ធិដីធ្លី នឹងបញ្ជីស្លាកលេខយានយន្តគ្រប់ប្រភេទជាដើម។ យោងតាមប្រសាស័នរបស់លោក ខេមរា " ទនឹមនិងនេះរដ្ឋាភិបាលក៏និងបង្កើតឱ្យមានជា កម្មវិធី E-Tourism និង E-Education។ ថ្មីៗនេះបានដឹងតាមរយៈ ប្រសាសន៍របស់សម្តេចអគ្គមហាសេនាធិបតីតេជោ ហ៊ុន សែន បានបន្ថែមទៀតថា និងបង្កើឱ្យមាន E-People ថែមទៀតផង។

ដូចដែលបានធ្វើការរៀបរាប់ខាងលើនេះ ការស្រាវជ្រាវធ្វើការកំណត់យកនូវចំនុចសំខាន់មួយដែលបានបង្ហាញខាងលើគឺ បញ្ជីស្លាកលេខយានយន្តគ្រប់ប្រភេទ ដោយបានបង្កើតឱ្យសេវាសាធារណៈថ្មីមួយដល់ការអភិវឌ្ឍន៍ប្រទេសតាមរយៈក្រសួងមួយគឺ ក្រសួងសាធារណការនិងដឹកជញ្ជូន ដើម្បីធ្វើការអនុវត្តទៅលើប្រព័ន្ធមួយនេះ ដោយដាក់ឈ្មោះថា **ការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម** (Online)។ ការចុះបញ្ជីយានយន្តនេះបានធ្វើការលើកកម្ពស់ក្នុងការអភិវឌ្ឍន៍ប្រទេសបានមួយផ្នែកដែរ គឺបានធ្វើឱ្យដំណើរការចុះបញ្ជីយានយន្តមានដំណើរការឆាប់រហ័ស ចំណេញពេលវេលា ចំណេញថវិការជាងមុនពេលដែលគ្មានប្រព័ន្ធនេះ។ តាមការសង្កេតមើលឃើញពិតជា ការកាត់បន្ថយការចំណាយពេលវេលា ថវិការក្នុងដំណើការនេះក៏បានធ្វើឱ្យកំណើន GDP របស់ប្រជាពលរដ្ឋដែលទទួលបានសេវាបានល្អមួយផ្នែកផងដែរ ថែមទាំងនៅពេលដែលប្រព័ន្ធនេះដាក់ដំណើរការ ការប្រមូលពន្ធក៏មានភាពងាយស្រួលជាងមុន។

ប្រសិនបើប្រជាពលរដ្ឋខ្មែរអាចធ្វើ ការចុះបញ្ជីយានយន្តបានដោយខ្លួនឯងបាននោះវាពិតជាអាចបង្ហាញថា កម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋខ្មែរនៅពេលបច្ចុប្បន្ននេះមានកម្រិតនៃការយល់ដឹងពីបច្ចេកវិទ្យាបានល្អប្រសើរជាងមុនច្រើននិងអាចទទួលយកនូវភាពទំនើបដែលមានប្រទេសជាច្រើនបានប្រើប្រាស់បច្ចេកវិទ្យានេះផងដែរ។ បើយើង ធ្វើការពិនិត្យមើលទៅលើកម្រិតនៃការប្រើប្រាស់បច្ចេកវិទ្យារបស់ប្រជាពលរដ្ឋខ្មែរ និងប្រជាពលរដ្ឋដែលស្ថិតនៅក្នុងប្រទេសដែលមានភាពជឿនលឿននេះវាបានបង្ហាញ ប្រជាពលរដ្ឋខ្មែរនៅមានកម្រិតទាបនៅឡើយនៅក្នុងការប្រើប្រាស់នូវបច្ចេកទំនើបតែក្រោយពេលដែលប្រព័ន្ធនេះបានដាក់ឱ្យដំណើរការមកវាក៏បានបង្ហាញទៅឱ្យ បណ្តាប្រទេសជិតខាងបានដឹងថានៅពេលនេះប្រជាពលរដ្ឋខ្មែរក៏មានការប្រើប្រាស់នៅបច្ចេកវិទ្យាល្អជាងមុនមួយកម្រិតទោះបីការចុះបញ្ជីភាគច្រើនធ្វើឡើងដោយហាងលក់យានយន្តក៏ដោយ តែបើមិនមានការចូលរួមពីអ្នក

ទិញវាក៏មិនអាចដំណើរការបាននោះទេ។ ការចុះបញ្ជីយានយន្តបានធ្វើឱ្យមានភាពងាយស្រួលដល់ប្រជាជនច្រើនជាងមុនទៅលើ ការទទួលបាននូវផ្លាកលេខយានយន្ត ដោយមិនត្រូវការចំណាយពេលវេលាច្រើនដូចពីមុន ពិសេសជាងនេះ យើងមានគំនិតមួយថាត្រូវធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋបានដឹងពី ប្រព័ន្ធនៃការចុះបញ្ជីយានយន្តនេះឱ្យបានកាន់តែទូលំទូលាយជាងពេលបច្ចុប្បន្នដោយគាត់អាចធ្វើការចុះបញ្ជីយានយន្តដោយខ្លួនឯងបាន។ ហេតុនេះហើយ យើងនឹងធ្វើការស្វែងរកនូវចំណុចខ្វះខាត់មួយចំនួនដែលធ្វើឱ្យប្រព័ន្ធនេះជួបនឹងបញ្ហា កត្តាទាំងអស់នោះមានដូចជា៖ ល្បឿននៃការប្រើប្រាស់អ៊ិនធឺណែត បើយើងនិយាយពីចំនុចនេះគឺ ល្បឿនលឿននោះភាគច្រើនគឺស្ថិតនៅក្នុងតំបន់ទីប្រជុំជននិងជាកន្លែងដែលសម្បូរមនុស្សរស់នៅ តែបើវាជាតំបន់ដាចស្រយាល ដូចជានៅតំបន់ភ្នំ តំបន់ពុំសូវមានការអភិវឌ្ឍន៍ជាដើម។ កម្រិតចំណេះដឹងនៃការប្រើប្រាស់អេឡិចត្រូនិច ចំពោះអ្នកដែរមានចំណេះដឹងទៅលើផ្នែកនេះគឺ មនុស្សដែលស្ថិតនៅក្នុងចន្លោះអាយុពី (១៥-៦០) ឆ្នាំ ដែលរស់នៅក្នុងកន្លែងដែលមានការអភិវឌ្ឍន៍ តែនៅក្នុងតំបន់ដែលពុំសូវមានការអភិវឌ្ឍន៍ ឬតំបន់ដាច់ស្រយាលគឺពីអាយុចន្លោះ (២៥-៦០) ឆ្នាំ ពួកគាត់ពុំសូវមានការចាប់អារម្មណ៍ទៅលើបច្ចេកវិទ្យានោះទេ ដូចនេះហើយ ដោយយោងទៅតាមការពិនិត្យមើលក៏ដូចជាតាមភាពពិតជាក់ស្តែងនៅតាម ហាងលក់យានយន្តគឺអ្នកដែលមានលិទ្ធភាពអាចទិញបានមានអាយុពី (២០-៦០) ឆ្នាំ ផ្អែកទៅលើចំនុចនេះហើយទើបគាត់ពុំសូវចេះបច្ចេកវិទ្យា ដូច្នេះត្រូវប្រគល់ដំណើរការចុះបញ្ជីនេះទៅឱ្យម្ចាស់ហាងជាអ្នកចុះជូនពួកគាត់តែនៅពេលខ្លះពួកគាត់គិតថា ការបំពេញពាក្យតាម Online នេះវាមានភាពស៊ាំញ៉ាំច្រើន ដោយសារតែពួកគាត់ពុំមានចំនេះដឹងទៅលើចំណុចនេះ ឬ ពេលខ្លះបណ្តាលមកពីភាពអក្ខរកម្មរបស់គាត់ខ្លះ។ យើងបានដឹងហើយថា មានហាងជាច្រើនដែលកំពុងបើកដំណើរការ ហេតុនេះហើយការចូលរួមពីវិស័យដែលមានការពាក់ព័ន្ធនេះពិតជាកត្តាជុំរុញដែលធ្វើឱ្យ ការចុះបញ្ជីយានយន្តនោះមានដំណើរការទៅបានល្អ។ ចំណុចពិសេសដែលធ្វើឱ្យយើងចង់លើកយកប្រធានបទ ស្តីពី " **ការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម** " នេះមកបង្ហាញឱ្យបានកាន់តែច្បាស់អំពីនីតិវិធី ក៏ដូចជាផលប្រយោជន៍ដែលនិងទទួលបានពីប្រព័ន្ធគឺ ធ្វើការយ៉ាងណាឱ្យអ្នកទិញអាចធ្វើការចុះបញ្ជីយានយន្តដោយខ្លួនឯងបាន ដោយសង្កេតឃើញថា នៅពេលបច្ចុប្បន្នមនុស្សភាគច្រើនមិនថាមនុស្សពេញវ័យ មនុស្សស្ថិតនៅក្នុង វ័យកណ្តាល និងមនុស្សចាស់ក៏ពួកគាត់អាចប្រើប្រាស់នូវបច្ចេកវិទ្យាទំនើបទាំងអស់នេះបានដូចគ្នានៅពេលបានដឹងពីរបៀបនៃការប្រើប្រាស់។

## ២. ចំណោទបញ្ហា

នៅក្នុងការគ្រប់គ្រងរបស់រដ្ឋាភិបាលនាអាណិត្តិទី ៥ បានធ្វើកំណែទម្រង់លើវិស័យសាធារណៈជាច្រើន ក្នុងនោះមានការកែប្រែលើ ការចុះបញ្ជីយាយន្តដែលធ្វើឡើងដោយក្រសួងសាធារណការនិងដឹង

ជញ្ជូនក្រោមគម្រោងថ្មីមួយដែលមានឈ្មោះថា **ការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម** (Online) ។ ដូចដែលបានរៀនរាប់ខាងលើបានធ្វើឱ្យយើងមានចម្ងល់មួយចំនួនដូចខាងក្រោម៖

១. ហេតុអ្វីត្រូវធ្វើការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម?

២. តើការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនេះមានផលលំបាកបែបណាខ្លះ?

៣. យោងតាមសកម្មភាពនៃការចុះទៅអនុវត្តលើការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម (Online) កន្លងមក និងមកដល់ពេលបច្ចុប្បន្ននេះថា តើការអនុវត្តលើគម្រោងនេះមានប្រសិទ្ធភាពបែបណា?

## ៣. ដែនកំណត់ និងវិសាលភាព

ការចុះបញ្ជីយានយន្តគ្រប់ប្រភេទ ត្រូវបានដាក់ទៅឱ្យក្រសួងសាធារណការនិងដឹកជញ្ជូនជាអ្នកអនុវត្តន៍ក្រោមគម្រោងនេះត្រូវបានដាក់ឈ្មោះថា " **ការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម** " ដែលដាក់ឱ្យអនុវត្តរយៈពេល ៣ ឆ្នាំ គិតចាប់ពី ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ ដល់ ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៩ ហើយការស្រាវជ្រាវបានធ្វើការកំណត់យកការចុះបញ្ជីយានយន្តចាប់ពីឆ្នាំ ២០១៦ ដល់ ឆ្នាំ ២០១៩នេះមកធ្វើការស្រាវជ្រាវតែម្តង។ ការសិក្សាលើប្រធាបទនេះ គឺផ្តោតសំខាន់តែទៅលើការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្មដែលមានវិសាលភាពតែទៅលើ ការទិញផ្លាកលេខទុក និងការចុះបញ្ជីតាម Vechicle.mpwt.gov.kh។

## ៤. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើ ប្រធានបទនេះមានគោលបំណង ធ្វើការស្វែងយល់អំពីការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ផលលំបាកអំពីការចុះបញ្ជីយានយន្ត ក៏ដូចជាប្រសិទ្ធភាពនៃការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនេះផងដែរ។ ការសិក្សាស្រាវជ្រាវទៅលើ ប្រធានបទក៏មានបំណងទុកជាឯកសារទុកឱ្យអ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយយកទៅធ្វើ ការសិក្សាស្រាវជ្រាវបន្ត សម្រាប់ធ្វើការប្រៀបធៀបពីប្រសិទ្ធភាព នឹងប្រសិទ្ធផលនៅពេលប៉ុន្មានឆ្នាំទៅមុខទៀត។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវលើប្រធានបទនេះ វិធីសាស្ត្រនៃការស្រាវជ្រាវ និងការប្រមូលទិន្នន័យគឺជាទិន្នន័យដែលមានស្រាប់តាមប្រភពជាច្រើន ការស្វែងរកឯកសារមួយចំនួននៅលើប្រព័ន្ធផ្សព្វផ្សាយរបស់ក្រសួងផ្ទាល់ (www.mpwt.gov.kh) ឯកសាររបាយការណ៍ផ្សេងៗដែលមានចុះផ្សាយនៅក្នុងបណ្តាញសង្គមព័ត៌មាន (ភ្នំពេញប៉ុស៍ ការសែតរស្មីកម្ពុជាថ្មី) ការចូលរួមក្នុងការធ្វើបទបង្ហាញពីការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនេះដោយផ្ទាល់ទៅលើប្រធានបទភាពងាយស្រួលនៃការចុះ

បញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម (Online) ” និងបានធ្វើការបកប្រែពីឯកសារបរទេសមួយចំនួនដែលមានការពាក់ព័ន្ធ (https://en-wikiedra.org/wiki (Moto vehicle registration) , https://www.quora.com ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងប្រធានបទ “ការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម” ត្រូវបានធ្វើការបែងចែកចេញជា ៤ ជំពូក ដែលជំពូកទី១ រំលឹកទ្រឹស្តី និងធ្វើការបង្ហាញពីនិយមមន័យ ការចុះបញ្ជីយានយន្ត គោលបំណងនៃការចុះបញ្ជីយានយន្ត ប្រវត្តិនៃការចុះបញ្ជីយានយន្ត ការអនុវត្តនៅក្នុងប្រទេសមួយចំនួន និងចុងក្រោយនិយាយអំពីផលប្រយោជន៍ដែលទទួលបាន។ ជំពូកទី២ ទិភាពទូរទៅនៃការចុះបញ្ជី នៅក្នុងជំពូកនេះយើងនឹងធ្វើការបង្ហាញនូវ ក្រសួងណាមួយដែលមានតួនាទីក្នុងការចុះទៅអនុវត្ត តួនាទីរបស់មន្ត្រី។ ជំពូកទី ៣ យើងនឹងធ្វើការសិក្សាទៅលើការអនុវត្តការចុះបញ្ជីយានយន្ត រួមទាំងធ្វើការបង្ហាញប្រាប់ពីនីតិវិធីនៃការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនេះឱ្យបានលម្អិត ព្រមទាំងបង្ហាញពីគុណសម្បត្តិ និងគុណវិបត្តដែលកំពុងកើតមានផងដែរ។ ជំពូកទី ៤ ជាជំពូកចុងក្រោយនៃប្រធានបទដោយយើងនិងពិភាក្សាលើបញ្ហាប្រឈម និងដំណោះស្រាយ។ រួមទាំង បានធ្វើការសេចក្តីសនិដ្ឋានទៅលើប្រធានបទទាំងមូល និងបានធ្វើការស្វែងរកនូវអនុសាសន៍មួយចំនួនដែលអាចធ្វើឱ្យប្រព័ន្ធនេះកាន់តែមានប្រសិទ្ធភាព ដោយមានឯកសារយោង នឹងឧបសម្ព័ន្ធសម្រាប់ប្រធានបទ។

# ជំពូកទី ១
# រំលឹកទ្រឹស្តី

## ១.១. និយមន័យ

ការចុះបញ្ជី មានន័យថាការត្រួតពិនិត្យទៅលើឯកសារទាំងឡាយណាដែលពាក់ព័ន្ធមុននឹងយកទៅប្រើការដោយមានរបៀបមានចំនួនច្បាស់លាស់។

យាន គ្រឿងដឹកនាំ គ្រឿងនាំបន្ទុកទៅមក ,គ្រឿងសម្រាប់ជិះ។

យន្ត គឺជាប្រដាប់ដែលកម្រើកបានដោយកម្លាំងយន្ត។

ស្វ័យប្រវត្តិកម្ម គឺជាការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា(អេឡិចត្រូនិច)ដើម្បីឱ្យធ្វើការដោយខ្លួនឯងក្រោយពីពេលដែលយើងបានបញ្ចូលទិន្នន័យម្តងរួចមកហើយ។

និយាយជារួមមក ការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម គឺជាការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ធ្វើការគ្រប់គ្រងទិន្នន័យឱ្យបានត្រឹមត្រូវ ដើម្បីមានភាពងាយស្រួលធ្វើការស្វែងរកនូវពេលក្រោយ ក៏ដូចជាអាចធ្វើការស្វែងរកបានភ្លាមៗដោយសារការប្រើនូវបច្ចកវិទ្យាទំនើប។

## ១.២. គោលបំណងនៃការបង្កើត

គោលបំណងនៃការចុះបញ្ជីយានយន្តគឺ ដើម្បីបង្កើតទំនាក់ទំនងរវាងយានយន្ត និងម្ចាស់យានយន្ត ឬអ្នកប្រើប្រាស់រថយន្តនោះ ហើយការចុះបញ្ជីយានយន្តនោះអាចត្រូវបានប្រើសម្រាប់ការប្រមូលយកពន្ធ ឬគោលបំណងមានភាពងាយស្រួលក្នុងការស្វែងរកបទឧក្រិដ ខណៈពេលដែលយានយន្តស្ទើរតែទាំងអស់ត្រូវបានធ្វើការកំណត់អត្តសញ្ញាណ ដោយឡែកពីលេខអត្តសញ្ញាណរថយន្តនីមួយៗ ហើយមានតែយានយន្តដែលនាំចូលដោយស្របច្បាប់តែប៉ុណ្ណោះដែលអាចធ្វើការចុះបញ្ជីបាន។ការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនេះមានគោលបំណង ដើម្បីសម្រួលដល់ការចុះបញ្ជីយានជំនិះ ត្រួតពិនិលក្ខណៈបច្ចេកទេសយានជំនិះ ចុះឈ្មោះប្រឡងបណ្ណបើកបរ និងផ្តល់បណ្ណបើកបរតាមរយៈការធ្វើទំនើបកម្មប្រព័ន្ធចុះបញ្ជីដោយកាត់បន្ថយ និតិវិធីរដ្ឋបាល ផ្តល់សេវាងាយស្រួល និងឆាប់រហ័ស ព្រមទាំងលុបបំបាត់ការចំណាយក្រៅផ្លូវការប្រកបដោយប្រសិទ្ធភាពតម្លាភាព ការជឿជាក់ និងទំនុកចិត្ត។

## ១.៣. ប្រវត្តិនៃការចុះបញ្ជីយានយន្តនៅកម្ពុជា

ដោយយោងទៅតាមច្បាប់ចរាចរណ៍ផ្លូវគោកឆ្នាំ ២០០៧ បានបង្ហាញឱ្យយើងបានដឹងថាការចុះបញ្ជីយានយន្តត្រូវបានប្រគល់ទៅឱ្យ ក្រសួងសាធារណការនិងដឹកជញ្ជូនតាំងតែពីពេលនោះមកម្លេះ បើយោងទៅតាមមាត្រា ៤៨ នៃច្បាប់នេះ។ក្រសួងសាធារណការនិងដឹកជញ្ជូន បានចេញរបាយការណ៍របស់ខ្លួនឱ្យដឹងថាការចុះបញ្ជីយានយន្តនៅប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ ១៩៩០

ដល់ ២០១៦ កន្លងទៅនេះមានចំនួនជាង ៣៦០.០០០.០គ្រឿង។ យោងតាមរបាយការណ៍របស់ក្រសួងសាធារណការនិងដឹកជញ្ជូនបានចេញផ្សាយនៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៦ នេះ បង្ហាញថាគិតចាប់ពីឆ្នាំ ១៩៩០ ដល់បច្ចុប្បន្ននេះមានយានយន្តដែលចុះបញ្ជីជាមួយនឹងក្រសួងសាធារណការនិងដឹកជញ្ជូន នៅទទូលទាំងប្រទេសមានចំនួន ៣.៦៦៩.៨២០ គ្រឿង ក្នុងនោះមានម៉ូតូចំនួន ៣.១៣២.៣៦១ គ្រឿង និងរថយន្តគ្រប់ប្រភេទចំនួន ៥៣៧.៤៥៩ គ្រឿង។

មាត្រ ៤៨ បានចែងថា បែបបទ និងនីតិវិធីនៃការចុះបញ្ជីយានយន្ត ការផ្តល់ស្លាកលេខ សម្គាល់យានយន្ត និងការលុបចេញពីបញ្ជីយានយន្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសាធារណការនិងដឹកជញ្ជូន។

មាត្រា ៤៨ថ្មី បានចែងបន្តថា ការលក់ទិញ ការធ្វើអំណោយ និងរាល់ទម្រង់ផ្សេងៗទៀត ដែលនាំឱ្យមានការផ្លាស់ប្តូរកម្មសិទ្ធិករនៃយានយន្ត ត្រូវបំពេញសំណុំបែបបទ ដើម្បីផ្ទេរ កម្មសិទ្ធិយានយន្ត។ បែបបទ និងនីតិវិធីនៃការផ្ទេរកម្មសិទ្ធិយានយន្ត មានកំណត់ក្នុងប្រកាសអន្តរក្រសួងរវាង ក្រសួងសាធារណការនិងដឹកជញ្ជូន នឹងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ម្ចាស់យានយន្តគ្រប់ប្រភេទ មានកាតព្វកិច្ចបំពេញបែបបទលុបចេញពីបញ្ជីយានយន្តនូវយានយន្តទាំងឡាយដែលគេឈប់ប្រើប្រាស់។ នេះបើតាមមាត្រា ៤៨ថ្មី នៃច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោក ដែលរដ្ឋសភាបានអនុម័ត វិសោធនកម្មលើសំឡេង ៩៣/១០០សំឡេង ក្នុងសម័យប្រជុំសភា នៅថ្ងៃទី ២៦ ធ្នូ ២០០៧នេះនាវិមានរដ្ឋសភា។

រដ្ឋាភិបាលបានធ្វើសេចក្តីព្រាងច្បាប់វិសោធនកម្ម នៃច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោកក្រោយមានការប្រទាំងប្រទើសមួយចំនួនកើតឡើងពេលសមត្ថកិច្ចចុះអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកថ្មីចាប់តាំងពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៦ រហូតមកតែជួបការលំបាកក្នុងការចុះទៅអនុវត្តន៍បែបនេះ ព្រោះមានមូលហេតុជាច្រើនបានលើឡើងថា រាល់ការបំពេញសំណុំឯកសារដើម្បីឱ្យការប្រើប្រាស់យានយន្ត និងទោលចក្រយានយន្តស្របច្បាប់មានភាពយឺតយ៉ាវខ្លាំងបែបនេះហើយបានជាច្បាប់នេះពុំសូវមានប្រសិទ្ធភាព។ស្របជាមួយនឹងការរីកចម្រើននៃបច្ចេកវិទ្យាផងដែរ រដ្ឋាភិបាលក៏បានឱ្យក្រសួងសាធារណនិងដឹកជញ្ជូនដាក់ចេញនូវការចុះបញ្ជីយានយន្តបែបទំនើបមួយគឺ ការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម (online) ដែលបានដាក់ឱ្យដំណើរការសាកល្បងចាប់តាំងពីថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ រហូតដល់ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៧ទើបមានពិធីដាក់ឱ្យដំណើការជាផ្លូវការ ។ដើម្បីឱ្យគម្រោងថ្មី នេះអាចដំណើរការទៅបានវាត្រូវការចូលរួមពីផ្នែកប្រព័ន្ធព័ត៌មានវិទ្យា ស្របពេលដែលរដ្ឋាភិបាលរបស់យើងនៅពេលនេះ កំពុងតែវិវត្តខ្លួនទៅរកការដឹកនាំរដ្ឋតាមបែបអេឡិចត្រូនិចដែលគេបានឱ្យឈ្មោះថា រដ្ឋាភិបាលអេឡិចត្រូនិច។

## ១.៤. ផលប្រយោជន៍ដែលទទួលបាន

ការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិចនេះ គឺពិតជាបានលើកម្ពស់អភិបាលកិច្ចល្អជាច្រើន ដែលវាសំដៅដល់ការអនុវត្តបច្ចេកវិទ្យាព័ត៌មាននៅក្នុងដំណើរការការងារ និងមុខងាររបស់រដ្ឋាភិបាលដើម្បីធ្វើឱ្យអភិបាលកិច្ចមានលក្ខណៈសាមញ្ញាមានសីលធម៌ មានគណនេយ្យភាព និងតម្លាភាព។ លើសពីនេះទៅទៀតវាតម្រូវឱ្យមានការទទួល និងការផ្តល់សេវារបស់រដ្ឋាភិបាលមានការផ្សព្វផ្សាយព័ត៌មាន ការប្រាស្រ័យទាក់ទងយ៉ាងឆាប់រហ័ស និងមានប្រសិទ្ធភាព។ អត្ថប្រយោជន៍សំខាន់ៗ នៃប្រព័ន្ធអេឡិចត្រូនិចរួមមានជាច្រើនក្នុងការចុះបញ្ជីយានយន្តយាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

- កាត់បន្ថយអំពើពុករលួយ៖ តាមរយៈនេះអ្នកទទួលសេវា (ប្រជាពលរដ្ឋ) ជៀសវាងការចំណាយក្រៅផ្លូវការ និងដំណាក់ការច្រើននៃការិយាធិបតេយ្យ
- តម្លាភាពខ្ពស់៖ ទាំងអ្នកផ្តល់សេវា និងអ្នកទទួលសេវាបានឃើញពីដំណើរការប្រព្រឹត្តិទៅទាំងអស់គ្នាមិនមានការលាក់បាំង ឬក្លែងបន្លំបាន
- ការបង្កើតភាពងាយស្រួល៖ សំដៅដល់ភាពលឿនរហ័ស ចំណាយតិច និងទទួលសេវាបានច្រើននិងឆ្លើតបតតាមតម្រូវការរបស់ប្រជាពលរដ្ឋ
- កំណើន ផ.ស.ស៖ អ្នកផលិតក្នុងស្រុក អ្នកវិនិយោគក្នុងស្រុក មានលទ្ធភាពទទួលបានការបញ្ជាក់ ការទទួលស្គាល់ផលិតផលទំនិញបានលឿននិងមានការទុកចិត្តជាមួយនឹងតម្លាភាព បង្កើនការផលិតបានកាន់តែច្រើនទាំងបរិមាណ គុណភាពសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក និងការនាំចេញ
- ការចូលរួមដោយផ្ទាល់ពីមណ្ឌលបោះឆ្នោត៖ ទទួលបាននូវជឿទុកចិត្តខ្ពស់ មានការកក់ក្តៅទៅលើសម្លេងគាំទ្ររបស់ខ្លួន
- ការបន្ថយចំណាយសរុប៖ ការចំណាយទាបជាងមុនដែលរួមផ្សំនឹងការលុបបំបាត់ចំណាយក្រៅផ្លូវការ
- ការពង្រឹកនៃរដ្ឋាភិបាល៖ រដ្ឋាភិបាល និងនៅកាន់តែកៀកជាមួយនឹងប្រជាពលរដ្ឋងាយស្រួលទទួលបានព័ត៌មានដែលជាបញ្ហាជួបប្រទះ និងធ្វើការដោះស្រាយបានទាន់ពេលវេលា។[1]

តាមរយៈអភិបាលកិច្ចតាមប្រព័ន្ធអេឡិចត្រូនិច រដ្ឋាភិបាលមានគម្រោងបង្កើតការគ្រប់ដណ្តប់ និងគុណភាពនៃព័ត៌មាន និងសេវាកម្មដែលបានផ្តល់ជូនសាធារណៈជនទូទៅ។ដោយការប្រើប្រាស់ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ក្នុងភាពងាយស្រួលឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។

[1] http://busiessjargons/e-government.html

ដំណើរការនេះមានភាពស្មុគស្មាញខ្លាំង ដែលតម្រូវឱ្យមានការរៀបចំផ្នែក Hardware និង Software ការតភ្ជាប់បណ្ដាញ និងការបង្កើតឡើងវិញនូវរាល់ដំណើរការទាំងអស់ ដើម្បីសម្រួលដល់ការផ្ដល់សេវា។[2] យើងក្រឡេចមកមើលលើការចុះបញ្ជីយានយន្តវិញ ក្រសួងសាធារណការនិងដឹកជញ្ជូនបានប្រកាសដាក់ឱ្យដំណើរការជាផ្លូវការនូវប្រព័ន្ធស្វ័យប្រវត្តិកម្ម សម្រាប់ការចុះបញ្ជីយានជំនិះ ការត្រួតពិនិត្យលក្ខណបច្ចេកទេសយានជំនិះ ការផ្ដល់បណ្ណបើកបរយានយន្ត និងកម្មវិធីយល់ដឹងអំពីទ្រឹស្ដីនៃការបើកបរលើទូរស័ព្ទដៃ។

តាមរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** ការដាក់ឱ្យដំណើរការប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន គឺជាការបំពេញសន្យារបស់លោកជាមួយលោកនាយករដ្ឋមន្ត្រី និងដើម្បីបង្កិតសេវាសាធារណៈដ៏មានប្រសិទ្ធភាព តម្លាភាព និងរហ័សឱ្យទៅកៀកនឹងប្រជាពលរដ្ឋ។ មុខងារទាំង ៤ (បួន) នៃប្រព័ន្ធស្វ័យប្រវត្តិកម្ម របស់ក្រសួងសាធារណការដែលកំពុងប្រកាសឱ្យប្រើប្រាស់នេះមានដូចខាងក្រោម

សម្រាប់ការចុះបញ្ជីយានយន្ត ប្រព័ន្ធស្វ័យប្រវត្តិកម្មនេះនឹងតភ្ជាប់តាមអនឡាញទៅតាមបណ្ដាហាងលក់យានយន្ត ដើម្បីចុះបញ្ជីផ្ដល់បណ្ណសម្គាល់យានយន្តភ្លាមៗ ហើយអតិថជនក៏អាចបញ្ជាទិញលេខពិសេស លើគេហទំព័ររបស់ក្រសួងសាធារណការនិងដឹកជញ្ជូន តាមតារាងតម្លៃក្នុងបញ្ជីផ្លាកលេខដែលមានស្រាប់។ ដូចជា ផ្លាកលេខ ភ្នំពេញ 2BA 0001 ក្រសួងប្រកាសលក់ក្នុងតម្លៃ ២ លានរៀលជាដើម។ ចំពោះការត្រួតពិនិត្យបច្ចេកទេសយានជំនិះម្ចាស់យានយន្ត អាចទទួលសេវាបាន ឈៀកនៅ ១១ កន្លែង តាមរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តមួយចំនួន រួមទាំងសេវាឈៀករថយន្តចល័តពីរគ្រឿងរបស់ក្រសួង។

ម្ចាស់យានយន្តអាចណាត់កាលវិភាគត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ តាមប្រព័ន្ធស្វ័យប្រវត្តិកម្មថ្មីបាន។ ចំពោះអ្នកប្រើប្រាស់ទូរស័ព្ទដៃ Smart Phone ក៏អាចទាញយក និងតម្លើងកម្មវិធីយល់ដឹងអំពីទ្រឹដ្ដីនៃការបើកបរដែលមានឈ្មោះថា Cambodia Driving Rule ដើម្បីស្វែងយល់ពីទ្រឹស្ដីការបើកបរ ឬប្រលងសាកល្បងផ្នែកទ្រឹស្ដី លេងល្បែងកំសាន្តបញ្ហាទាក់ទងនឹងច្បាប់លិខិតបទដ្ឋានចរាចរណ៍នានា។ បេក្ខជនប្រឡងយកបណ្ណបើកបរយានយន្ត ដែលជាប់ភ្លាម និងទទួលបានបណ្ណបើកបរភ្លាមក្នុងថ្ងៃតែមួយ លែងរង់ចាំរាប់ខែដូចពីមុនទៀតហើយ។[3]

[2] http://businessjargons.com/r-government.html#ixzz4nCONBXKJ
[3] ការថ្លែងរបស់រដ្ឋមន្ត្រីនៅក្នុងពិធីសម្ពោទដាក់ឲ្យប្រើប្រាស់ការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

## ១.៥. ការអនុវត្តនៅក្នុងប្រទេសមួយចំនួន

### ៥.១.ការចុះបញ្ជីយានយន្តក្នុងប្រទេសអូស្ត្រាលី

ការចុះបញ្ជីយានយន្តនៅប្រទេសអូស្ត្រាលី ត្រូវបានធ្វើឡើងតាមរយៈរដ្ឋនីមួយៗ និងរដ្ឋបាលដែនដីតាមរយៈភ្នាក់ងារដឹកជញ្ជូនផ្លូវរបស់ពួកគេ។ក្នុងការដែលវិញ្ញាបនបត្រចុះបញ្ជីកត់ត្រាពីប្រតិបត្តិការដែលបានចុះបញ្ជីរថយន្តជាទូទៅពួកគេធ្វើជាភស្តុតាងនៃភាពជាម្ចាស់ ទោះបីជាមិនមានច្បាប់ទេសក៏ដោយ។ កម្មសិទ្ធិត្រូវបានគ្រប់គ្រងដោយច្បាប់រួម កម្មសិទ្ធិករនៃយានយន្ត (ប្រសិនបើទ្រព្យសម្បត្តិហិរញ្ញវត្ថុដែលមានសុវត្ថិភាព) អាចត្រូវបានត្រួតពិនិត្យតាមរយៈ ស៊ីស៊ីផ្ទាល់ខ្លួនអចលនទ្រព្យនៃរដ្ឋាភិបាលសហព័ន្ធ ប៉ុន្តែនេះមិនមែនជាការចុះឈ្មោះជាចាំបាច់ទេ។ ជាញឹកញាប់ភស្តុតាងនៃ សិទ្ធិ ឬភាពជាម្ចាស់ត្រូវបានតម្រូវឱ្យចុះបញ្ជីរថយន្ត។ លិខិតចុះបញ្ជីយានយន្ត ឬស្រដៀងគ្នានេះត្រូវបានចេញដោយភ្នាក់ងាររដ្ឋ ឬដែនដី ឯកសារនេះអាចត្រូវបានប្រើជាឯកសារអត្តសញ្ញាណទីពីររបស់ប្រតិបត្តិករនេះ។ ស្របតាមវិញ្ញាបណ្ណបត្រនេះភ្នាក់ងារក៏បានចេញនូវស្លាកលេខរថយន្តផងដែរ។ ការចុះបញ្ជីនេះមានរយៈពេលជា អតិបរមាមួយឆ្នាំហើយក្រោយមកដែលការចុះបញ្ជីយានយន្តនេះត្រូវតែបន្តប្រើប្រាស់រហូត។វិញ្ញាបនបត្រនេះចុះបញ្ជីកត់សម្គាល់ គំរូ ឆ្នាំផលិត រូបរាងលេខ VIN លេខឈៀក លេខម៉ាស៊ីន ទម្ងន់ម៉ាស៊ីន និងចំនួនអ្នកដំណើរ។

គោលនយោបាយធានារ៉ាប់រងភាគីទីបី ត្រូវបានទាមទារដើម្បីបន្តរថយន្តក៏ដូចជា ការត្រួតពិនិត្យសម្រាប់រថយន្តចាស់ ឬពាណិជ្ជកម្ម។ ខណៈពេលដែលរដ្ឋ និងដែនដីភាគច្រើនលែងចេញការចុះបញ្ជីសម្រាប់រថយន្តនោះ ព័ត៌មានលម្អតនៃការចុះឈ្មោះអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិចតាមរយៈប៉ូលិស ឬតាមសរវាអ៊ីនធឺណែតដែលមានក្នុងទូរស័ព្ទដៃរបស់អ្នកផ្ទាល់។ នៅក្នុងរដ្ឋភាគច្រើនការចុះបញ្ជីយានយន្តអាចចុះញ្ជីតាមរយៈក្រុមហ៊ុន ឬបុគ្គល។ រថយន្តមួយចំនួនត្រូវបាន ចុះឈ្មោះជាមួយរដ្ឋាភិបាលសហព័ន្ធយោធា ឬតាមរយៈប្រព័ន្ធចុះបញ្ជីអន្តោប្រវេសន៍សហព័ន្ធ (FIRS) តាមរយៈភ្នាក់ងាររដ្ឋ ឬតំបន់។ មុខងារជាច្រើនអាចត្រូវបានចុះឈ្មោះតាមរយៈអ៊ីនធឺណែត។

ជាទូទៅរថយន្តឯកជនដែលបាន ចុះបញ្ជីនៅក្នុងប្រទេសណាមួយនៃសហភាពអឺរ៉ុបត្រូវតែបង្ហាញនូវការអនុលោមតាមបទបញ្ជារបស់ជាតិ និងបទបញ្ជារបស់សហភាពអឺរ៉ុបដែលរួមមានការរៀបចំខ្សែក្រវ៉ាត់ ការគណនាភាពធន់(រយៈពេលប្រើប្រាស់ ទម្ងន់)ផលប៉ះពាល់ផ្នែកខាងមុខចំហៀងទំនងជាការពារអ្នកដំណើរ និងអ្នកថ្មើរជើងក្នុងប្រភេទគ្រោះថ្នាក់មួយចំនួន។

រថយន្តតូចៗដែលបានផ្តល់ជាតួរទទេគ្មានរូបរាងកាយ និងកង់មិនមានលក្ខណស្តង់ដាសុវត្ថិភាព របស់សហភាពអឺរ៉ុបសម្រាប់ការចុះឈ្មោះ។

ការចុះបញ្ជីយានយន្តសម្រាប់ប្រទេសអង់គ្លេសស្កុតឡេន និងវ៉េលគឺជាការទទួលខុសត្រូវរបស់អ្នកបើកបរយានយន្ត

➢ ការចុះឈ្មោះយានយន្តថ្មី

ចក្រភពអង់គ្លេសកំពុងដំណើរ ការប្រព័ន្ធអនុម័តបួន (៤) ប្រភេទដែលអាចនាំឱ្យវិញ្ញាបនបត្រសមស្រប។ដំបូងគឺ ជាគ្រោងការណ៍ជាទៀងទាត់សម្រាប់រថយន្តផលិតផលដែលអាចចុះបញ្ជីគ្រប់ទីកន្លែងនៅក្នុងសហគមន៍អឺរ៉ុប។ គម្រោងផ្សេងទៀតដែលត្រូវបានគេស្គាល់ថាជា ការអនុម័តប្រភេទធុនតូចថ្នាក់ជាតិដែលមាន SVA/ESVA និងការអនុម័តរថយន្តឯកជន (IVA) ត្រូវបានបម្រុងទុកសម្រាប់រថយន្តដែលត្រូវចុះឈ្មោះនៅក្នុងចក្រភពអង់គ្លេស។

- សហគមន៍អឺរ៉ុប (ECWVA) គឺជាវិញ្ញាបនបត្រស្របច្បាប់មួយសម្រាប់ EC ដែលជាក្រុមហ៊ុនផលិត បរិមាណនៃប្រភេទរថយន្តដែលផលិតនៅក្នុងឆ្នាំនីមួយៗដែលអាចលក់ផលិតផលរបស់ពួកគេតាមរយៈភ្នាក់ងារដែលមាន ការអនុញ្ញាតនៅតាមបណ្តាលប្រទេសជឿនលឿននានាដោយគ្មានការធ្វើតេស្តបន្ថែម។ ECWVTA ត្រូវបានរួមបញ្ចូលជាមួយនិងកិច្ចព្រមព្រៀង គណៈកម្មការសេដ្ឋកិច្ចរបស់សហប្រជាជាតិសម្រាប់ឆ្នាំ១៩៩៨ទាក់ទងនិងការបង្កើតបទបញ្ញាបច្ចេកទេសសកលសម្រាប់យានយន្តគ្រឿងបរិក្ខា និងផ្នែកដែលត្រូវបានបំពាក់ ឬ ត្រូវបានប្រើនៅលើយានយន្តដែលមាននៅក្នុងប្រទេសផ្សេងៗ ដែលមិនមែនជាសហគមន៍អឺរ៉ុប ដូចជារុស្ស៊ី និងអាហ្វ្រិកខាងត្បូងជាដើម។
- ការអនុម័តរថយន្តប្រភេទធនតូចនៅសហភាពអឺរ៉ុប (ECSSTA) គឺសម្រាប់ក្រុមហ៊ុនផលិតរថយន្តដែលអាចលក់រថយន្តបានរហូតដល់ ១.០០០ គ្រឿងក្នុងមួយឆ្នាំៗ។ ទោះបីជា ECSSTA អនុញ្ញាតឱ្យមានការលក់នៅគ្រប់ទីកន្លែងនៅក្នុងសហភាពអឺរ៉ុបក៏ដោយក៏អាចមានតម្រូវការផ្នែកបច្ចេកទេសនិងរដ្ឋបាលមួយចំនួននៅតាមបណ្តាប្រទេសមួយចំនួនដើម្បីធានាឱ្យការលក់នៅគ្រប់ទីកន្លែង នៅក្នុងសហភាពអឺរ៉ុបក៏អាចមានតម្រូវការផ្នែកបច្ចេកទេស និងរដ្ឋបាលមួយចំនួននៅតាមបណ្តាប្រទេសមួយចំនួនដើម្បីធានាឱ្យមានការគោរពតាមវិញ្ញាបនបត្រដែលអនុលោមតាមច្បាប់ ជាពិសេសសហគ្រាសធនតូចនិងមធ្យមដើរតួជាភ្នាក់ងារលក់ ឬអាចផ្តល់ជូននូវសេវាប្តូរតាមបំណងដោយមិនចាំបាច់មានការដាក់ឱ្យផ្ទៀងផ្ទាត់ការបណ្តុះបណ្តាលអន្តរជាតិ និងស្តង់ដារត្រួតពិនិត្យគុណភាព។

- ការអនុម័តយានយន្តឯកតា (SVA) គឺសម្រាប់រថយន្តខ្នាតតូច ដូចជារថយន្តសង្គ្រោះ និងរថយន្ត ដែលជារឿយៗត្រូវបានគេកែច្នៃតាមតម្រូវការរថយន្ត និងសម្រាប់រថយន្ត ដែលផលិតទៅតាស្តង់ដារដែលមិនត្រូវបានទទួលស្គាល់ដែលត្រូវបាននាំចូលទៅចក្រភពអង់គ្លេសពីខាងក្រៅ EC
- ការអនុម័តយានជំនិះលើកដំបូង (ESVA) គឺសម្រាប់រថយន្តតូចៗ
- ការអនុម័តយានយន្តឯកត្តជន (IVA) គឺសម្រាប់រថយន្តកូនកាត់និងរថយន្តដែលផលិតនៅផ្ទះ។

ជាការចាំបាច់ចាប់តាំងពីរថយន្តដែលបាន ចុះបញ្ជីអេឡិចត្រូនិចអាចដឹកជញ្ជូនដោយសេរីនៅក្នុងប្រទេសនានារបស់សហគមន៍អឺរ៉ុប ទោះបីជាអាជ្ញាធរខ្លះមានភាពស្ទាក់ស្ទើរក្នុងការទទួលយកគំរូដើម ឬរថយន្តដែលមានបរិមាណតិចដោយគ្មានការសាកល្បងតឹងរឹងខ្លាំង។

## ៥.២.ការចុះបញ្ជីយានយន្តរបស់ឥណ្ឌា

ការចុះបញ្ជីរថយន្តផ្លូវថ្នល់ នៅក្នុងប្រទេសឥណ្ឌាត្រូវបានធ្វើឡើងដោយការិយាល័យដឹកជញ្ជូនតាមតំបន់ក្នុងតំបន់របស់រដ្ឋ។ រថយន្តពាណិជ្ជកម្មដែលបាន ចុះបញ្ជីនៅក្នុងរដ្ឋមួយមិនអាចចូលរដ្ឋផ្សេងទៀតដោយគ្មានការអនុញ្ញាតទេ ដែលជាធម្មតាទទួលបានការចំណាយដ៏ច្រើន ។យានយន្តដឹកអ្នកដំណើរដែលបាន ចុះបញ្ជីក្នុងរដ្ឋមួយត្រូវបានអនុញ្ញាតឱ្យឆ្លងកាត់រដ្ឋមួយផ្សេងទៀតប៉ុន្តែមិនត្រូវបានអនុញ្ញាតឱ្យស្នាក់នៅក្នុងរដ្ឋមួយទៀតបានយូរជាងចំនួនថេរទេ លុះត្រាតែ ការបង់ពន្ធផ្លូវត្រូវបានបង់ដោយផ្អែកលើវិធានការដឹកជញ្ជូនរបស់រដ្ឋ។

## ៥.៣.ការចុះបញ្ជីយានយន្តរបស់សហរដ្ឋអាមេរិក

ការចុះបញ្ជីយានយន្ត នៅសហរដ្ឋអាមេរិកត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានយានយន្តរបស់រដ្ឋនីមួយៗ ឬទីភ្នាក់ងារផ្សេងទៀតប្រសិនបើគ្មាននាយកដ្ឋាន។ អ្នកដំណើរ និងយានជំនិះត្រូវតែចុះបញ្ជីជាលក្ខណនៃ ការប្រើប្រាស់នៅលើផ្លូវសាធារណៈ។ រថយន្តដែលមិនត្រូវបានប្រើនៅលើផ្លូវសាធារណៈដូចជាត្រាក់ទ័រ ឬយានជំនិះដែលប្រើប្រាស់មានកំណត់ទៅជាទ្រព្យសម្បត្តិឯកជនមិនត្រូវបានតម្រូវឱ្យ ចុះបញ្ជីរថយន្តទេរួមមាន វត្ថុបុរាណ គ្រឿងផ្សំ មធ្យោបាយធ្វើជំនួញពាណិជ្ជកម្ម។ នៅក្នុងរដ្ឋអាមេរិកភាគច្រើន គោលនយោបាយធានារ៉ាប់រងបំណុលដែលឆ្លើយតបនិងតម្រូវការការធានារ៉ាប់រងដោយខ្លួនឯងត្រូវបានទិញមុនពេលយានយន្តអាចចុះបញ្ជីតាមនាយកដ្ឋានរថយន្ត។

## ៥.៤.ការចុះបញ្ជីយានយន្តរបស់រដ្ឋកាលីហ្វ័រញ៉ា

ការចុះបញ្ជីត្រូវបាន គ្រប់គ្រងដោយនាយកដ្ឋានរថយន្តម៉ូតូនៃរដ្ឋកាលីហ្វ័ញ៉ា។ វាគឺជាការទទួលខុសត្រូវរបស់អ្នកលក់រថយន្ត ដើម្បីចុះបញ្ជីយានយន្តថ្មី និងរថយន្តដែលបានលក់ដោយអ្នកលក់របស់ពួកគេ។ ក្រុមហ៊ុនលក់ដុំប្រើប្រាស់អ្នកឯកទេស ចុះបញ្ជីដើម្បីប្រមូល និងបំពេញបែបបទដែលចាំបាច់ដើម្បីដាក់ចំណងជើង និងចុះបញ្ជីរថយន្ត។ ទោះបីជា មានឈ្មួញជាច្រើនបានដំណើរការដោយប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងស្តង់ដារធំៗ (DMV) ហើយការងារភាគច្រើននៃការងារដែលបានធ្វើនៅកន្លែងចុះឈ្មោះគឺដោយដៃ ភ្នាក់ងារចុះបញ្ជី រហូតដល់ឆ្នាំ ២០០៦ រដ្ឋបានធ្វើការតាមដានទៅកិច្ចព្រមព្រៀងគ្នាដោយប្រើប្រាស់ប្រតិទិនក្រដាស និង logbooks ដែលជាដំណើរការដែលគ្មានប្រសិទ្ធភាពនឹងបណ្តាលឱ្យមានការពិន័យជា ប្រាក់រាប់លានដុល្លារនៅក្នុង DMV និងការពិន័យដែលកើតឡើងដោយក្រុមហ៊ុនលក់ដុំ។ បច្ចេកវិទ្យាត្រូវបាននៃនាំពីកម្មវិធីមួយដែលមានឈ្មោះថា "Business Partner Automation(BPA)" ដែលអនុញ្ញាតឱ្យឈ្មួញដែលចូលរួមក្នុងការចុះបញ្ជីឯកសារអេឡិចត្រូនិច។ ភាគច្រើននៃយានយន្តដែលបាន ចុះញ្ជីនៅក្នុងរដ្ឋកាលីហ្វ័រញ៉ា គឺតាមរយៈប្រតិបត្តការរបស់ភាគីបីដែលរថយន្តនេះត្រូវបានលក់ពីអង្គភាពមួយទៅអង្គភាពមួយទៀត ដោយមិនចាំបាច់ប្រើប្រាស់ឈ្មួញ។ ការចុះបញ្ជីយានយន្តដែលបានលក់តាមរបៀបនេះត្រូវបានធ្វើឡើងតាមរយៈសាខា DMV ក្នុងស្រុក ឬតាមរយៈការប្រើប្រាស់អ្នកផ្តល់សេវាកម្មចុះបញ្ជីឯករាជ្យ។ សម្រាប់ជនណាដែលបានស្នើសុំ ឬទទួលបាន ការចុះបញ្ជីយានយន្តត្រូវជូនដំណឹងដល់ DMV នៅទីលំនៅថ្មី ក្នុងរយៈពេល ១០ថ្ងៃ ហើយប្រសិនបើការចុះបញ្ជីនេះមានការយឺតយ៉ាវនោះត្រូវប្រឈមនឹងការផាកពិន័យដោយជាធម្មតាមានតម្លៃ ១៧៨ដុល្លា។[4]

[4] https:/en.wikipedia.org/wiki/Moto vehicle registration

# ជំពូកទី ២

# ទិដ្ឋភាពទូទៅនៃការចុះបញ្ជី

## ២.១. សមិទ្ធិផលដែលសម្រេចបានរបស់ក្រសួង

គិតចាប់ពីថ្ងៃឡើងកាន់តំណែងជា រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ក្នុងឆ្នាំ២០១៣ មកដល់បច្ចុប្បន្ន **ឯកឧត្តម ស៊ុន ចាន់ថុល** បានសម្រេចសមិទ្ធផលធំៗជាច្រើនជូន ប្រជាពលរដ្ឋខ្មែរ។ នៅក្នុងឆ្នាំ ២០១៧ នេះលោកបានសម្រេចសមិទ្ធផលជាបន្តបន្ទាប់ និងទទួលបានការសាទរខ្លាំងពីសំណាក់ប្រជាពលរដ្ឋខ្មែរ ហើយសមិទ្ធផលសំខាន់ៗរបស់រដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** ក្នុងឆ្នាំ ២០១៧ ខាងក្រោមនេះមាន

- ការដាក់ឱ្យដំណើរការមណ្ឌលប្តូរ និងពន្យារបណ្ណបើកបរ នៅផ្សារទំនើប AEON Mall ភ្នំពេញ (ចំណាយពេលប្រមាណ ១៥នាទី ដើម្បីទទួលបានបណ្ណបើកបរ)
- ការបិទផ្លាកសុវត្ថិភាព (ស្ទីគ័រចំណាំផ្លាតពន្លឺពេលយប់) ចំនួន ៣.៤ លានសន្លឹក
- យុទ្ធនាការចែកមួកសុវត្ថិភាពរាប់ម៉ឺនមួកជូនប្រជាពលរដ្ឋស្ទីគ័រចំណាំផ្លាតពន្លឺពេលយប់ ចំនួន ៣.៤ លានសន្លឹក
- យុទ្ធនាការចែកមួកសុវត្ថិភាពរាប់ម៉ឺនមួកជូនប្រជាពលរដ្ឋ
- ការរៀបចំរចនាសម្ព័ន្ធអង្គការលេខរបស់ក្រសួងឡើងវិញដើម្បីបំពេញការងារឱ្យកាន់តែមានប្រសិទ្ធភាព
- ការដាក់ឱ្យដំណើរកាចុះបញ្ជីយានយន្ត និងការផ្តល់ជូនបណ្ណបើកយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម
- បង្កើតកម្មវិធីយល់ដឹងអំពីទ្រឹស្តីនៃការបើកបរលើទូរស័ព្ទ
- ឈៀកចល័ត និងផ្លាកលេខយានយន្តដែលមាន RQ code ដើម្បីកាត់បន្ថយការក្លែងបន្លំ និងការបង្កើតមជ្ឈមណ្ឌលត្រួតពិនិត្យលក្ខណបច្ចេកទេសជាច្រើនកន្លែងនៅរាជធានីភ្នំពេញ។ល។

ដោយឡែកសមិទ្ធផលផ្សេងៗទៀតនិងចេញជារូបរាងជាបន្តបន្ទាប់ដូចជា៖

- ការសាងសង់ផ្លូវរថភ្លើងពីភ្នំពេញទៅព្រលាយន្តហោះដើម្បីកាត់បន្ថយការកកស្ទះចរាចរណ៍ ដែលគ្រោងដាក់ឱ្យដំណើរការឆាប់ៗ
- ការដឹកជញ្ជូនតាមផ្លូវទឹក ការរៀបចំក្របខណ្ឌស្ថាប័នទទួលបន្ទុកភស្តុភកម្មដើម្បីកាត់បន្ថយថ្លៃដឹកជញ្ជូន

- ការធ្វើសមាហរណកម្មនូវទូទាំងប្រទេសតាមរយៈការកសាងនិងពង្រីកបណ្តាញផ្លូវតភ្ជាប់ការកសាងផ្លូវរថភ្លើងការគ្រប់គ្រងការដឹកជញ្ជូនលើសទម្ងន់កំណត់
- ការកសាងកំពង់ផែទឹកជ្រៅការលុបគ្រលុកនៅទូទាំងប្រទេស

តាមរយៈការដាក់ឱ្យដំណើរការរម៉កដែលបំពាក់ដោយឧបករណ៍ចំនួនជាង ៣០០ គ្រឿងនិងសម្ភារគ្រប់គ្រាន់សម្រាប់ចល័តចុះពិនិត្យ និងជួសជុលគ្រលុកភ្លាមៗ ក្នុងគោលបំណងថែរក្សាបណ្តាញផ្លូវថ្នល់របស់យើងឱ្យជាប់បានយូរ។កាលពីព្រឹកថ្ងៃទី០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៧ នៅមជ្ឈមណ្ឌលសហប្រតិបត្តការកម្ពុជាកូរ៉េ (CKCC) **ឯកឧត្តម ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី នៃក្រសួងសាធារណការបានធ្វើបទបង្ហាញស្តីពី កំណែទម្រង់វិស័យសាធារណការ និងដឹកជញ្ជូន។ ក្នុងនោះឯកឧត្តមក៏បានបង្ហាញពី សមិទ្ធផលសំខាន់ៗដូចរៀបរាប់ខាងលើនេះមានយានយន្តចំនួន ២២០.០០០.០គ្រឿង ហើយដែលបានចុះបញ្ជីរួចរាល់បើគិតត្រឹមឆមាសទី ១ ឆ្នាំ ២០១៣ នេះបើតាមការឱ្យដឹងពី មន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូននៃ កម្ពុជាដែលបានធ្វើបទសម្ភាសជាមួយអ្នកសារព័ត៌មានកាលពី ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០១៦។លោក **ព្រាប ចាន់ទិបុល** ប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោកបានឱ្យដឹងថាក្នុងចំណោមចំនួនទាំងនេះគឺ មានរថយន្តចំនួន ៣៥០.០០០គ្រឿង ក្រៅពីនោះគឺ សុទ្ធតែទោចក្រយានយន្តជាប្រភេទម៉ូតូ។ ចំនួនតួលេខនេះគឺគិតចាប់តាំងពីឆ្នាំ ១៩៩០ មកត្រឹមឆមាសទី១ឆ្នាំ ២០១៣។ លោកបន្តទៀតថា ការចុះបញ្ជីយានយន្តគ្រប់ប្រភេទ ក្នុងមួយឆ្នាំ គឺមានអត្រាពី ២៥ ម៉ឺនគ្រឿងទៅ ៣០ ម៉ឺនគ្រឿង។

ដោយមិនរាប់បញ្ចូលពីចំនួនយានយន្តតម្កលលក់នៅក្នុងឃ្លាំងនីមួយៗនោះឡើយពោលគឺរាប់តែយានយន្តដែល អ្នកប្រើប្រាស់បានទិញពីម្ចាស់ឃ្លាំង ឬក៏ពីក្រុមហ៊ុនហើយត្រូវយកទៅចុះបញ្ជីតែប៉ុណ្ណោះ។ **លោក ព្រាប ចាន់ទិបុល** បញ្ជាក់ថាតាមតួលេខរថយន្តដែលបានយកទៅចុះបញ្ជី គឺភាគច្រើនជាប្រភេទរថយន្តមួយទឹកនេះដែលសរបញ្ជាក់ថាយានយន្តប្រភេទទាំងនេះគឺមានការនាំចូលនិងប្រើប្រាស់នៅកម្ពុជាច្រើននៅឡើយ បើប្រៀបធៀបជាមួយនឹងរថយន្តថ្មីនាពេលចុងក្រោយនេះក៏មានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ។

ទាក់ទងនឹងប្រការដែលធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ចូលមកពាក់ព័ន្ធក្នុងរឿងនេះ**លោក ព្រាប ចាន់ទិបុល** បានឱ្យដឹងថាដោយសារស្ថាប័នមួយនេះបានផ្តល់នូវថវិកាចំនួន ៥០ ម៉ឺនដុល្លារអាមេរិកដល់ក្រសួងសាធារណការនិងដឹកជញ្ជូន កម្ពុជាដើម្បីធ្វើកំណែទម្រង់ការគ្រប់គ្រងការងារដឹកជញ្ជូនផ្លូវគោកនៅកម្ពុជាដូចជាការចុះបញ្ជីយានយន្ត និងការត្រួតពិនិត្យយានយន្តគ្រប់ប្រភេទឱ្យមានលក្ខណៈកាន់តែប្រសើរឡើងខណៈដែល បញ្ហានេះកំពុងមានការស្មុគស្មាញនៅឡើយ។

បានបន្ថែមថា ជំនួយនេះគឺត្រូវបានអនុវត្តចាប់តាំងពី ខែឧសភា ឆ្នាំ ២០១២ ដល់ ខែមិថុនា ឆ្នាំ ២០១៣ ដោយការបំពាក់នូវប្រព័ន្ធការងារ (Network) ដូចជាប្រព័ន្ធកុំព្យូទ័រជាដើម។ ប៉ុន្តែ ការងារនៅមិនទាន់បញ្ចប់នៅឡើយទេ គឺតម្រូវឱ្យបន្តប្រមាណជា ២ ឬ៣ខែ ទៅមុខទៀត។ លោកបញ្ជាក់ថានេះជាលើកដំបូងហើយដែលធនាគារអភិវឌ្ឍន៍អាស៊ី ADB ផ្ដល់ជំនួយបែបនេះដល់ក្រសួងសាធារណការនិងដឹកជញ្ជូននៅកម្ពុជា។

**លោក តូច ចាន់កុសល** រដ្ឋលេខាធិការនៃក្រសួងសាធារណការ និងដឹកជញ្ជូនក្នុងកិច្ចពិភាក្សាលើ កំណែទម្រង់ការគ្រប់គ្រងការងារដឹកជញ្ជូនផ្លូវគោក នៅកម្ពុជាមានប្រសាសន៍ថា បច្ចុប្បន្ននេះ វិស័យដឹកជញ្ជូននៅកម្ពុជាដើរមិនទាន់សភាពការណ៍នៃ ការអភិវឌ្ឍន៍នៅឡើយទេ ហើយប្រសិនបើនៅបណ្ដែតបណ្ដោយទៀត បញ្ហានេះកាន់តែធ្ងន់ធ្ងរ និងប៉ះពាល់យ៉ាងខ្លាំងដល់សេដ្ឋកិច្ចជាតិ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ លោកបញ្ជាក់ថា ការគ្រប់គ្រងមធ្យោបាយដឹកជញ្ជូននៅមានការលំបាកដូចជា ការចុះបញ្ជីយានយន្ត និងចេញបណ្ណបើកបរនៅប្រើរយៈពេលវេលាយូរចំណែកឯការត្រួតពិនិត្យប្រព័ន្ធសុវត្ថិភាពក៏ នៅពុំទាន់បានល្អប្រសើរដែលអាចជះឥទ្ធិពលដល់វិស័យដឹកជញ្ជូន ពិសេសដល់ការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកក្រសួងត្រូវតែកែទម្រង់បញ្ហានេះ ជាបន្ទាន់ដើម្បីឱ្យវិស័យដឹកជញ្ជូននៅកម្ពុជាមានភាពកាន់តែប្រសើរឡើងប្រកបដោយតម្លាភាព ប្រសិទ្ធភាពជាងមុន ពិសេសសំដៅការឆ្លើយតបទៅនិងការត្រៀមធ្វើសមាហរណកម្មវិស័យដឹកជញ្ជូនផ្លូវគោកនៅក្នុងសហគមអាស៊ានឆ្នាំ ២០១៥។

លោក Don Townsend មន្ត្រីសម្របសម្រួលគម្រោង និងជាអ្នកជំនាញការអភិវឌ្ឍសមត្ថភាពនៃ ADB និយាយថា កម្ពុជានៅខ្វះលទ្ធភាពច្រើនក្នុងការអភិវឌ្ឍន៍វិស័យនេះ ដែលទាមទារឱ្យមានការចូលរួមពីស្ថាប័នពាក់ពន្ធ័ជាច្រើនទៀតដើម្បីធ្វើឱ្យកំណែទម្រង់នេះទទួលបានជោគជ័យជាប្រយោជន៍សម្រាប់ប្រជាពលរដ្ឋ។ ជាពិសេស ដើម្បីធ្វើការធ្វើកំណែទម្រង់ការគ្រប់គ្រងការងារដឹកជញ្ជូនផ្លូវគោកជាការបើកទំព័រសករាជ្យថ្មីក្នុងវិស័យដឹកជញ្ជូននៅកម្ពុជា។សូមបញ្ជាក់កាលពី ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៧ ក្រសួងសាធារណការ និងដឹកជញ្ជូនផ្លូវគោក និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានរួមគ្នាធ្វើការពិគ្រោះយោបល់ក៏ដូចជាពិនិត្យឡើងវិញពីការធ្វើកំណែទម្រង់លើការងារគ្រប់គ្រងវិស័យដឹកជញ្ជូន នៅកម្ពុជាដោយមានការចូលរួមពីគ្រប់មន្ត្រីនៃ មន្ទីរសាធារណការ និងដឹកជញ្ជូននៅទូទាំងប្រទេស។ នៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៧ នៅអគ្គនាយកដ្ឋានដឹកជញ្ជូននៃក្រសួងសាធារណការ និងដឹកជញ្ជូនឯកឧត្តមអគ្គនាយក **ពៅ ម៉ាលី** បានទទួលជួបពិភាក្សាការងារជាមួយ គណៈប្រតិភូនៃសាធារណៈរដ្ឋសហភាពមីយ៉ាន់ម៉ាមួយក្រុមប្រមាណ ៣០ រូប ដែលដឹកនាំដោយឯកឧត្តម Nyunt shwe រដ្ឋមន្ត្រីក្រសួងផែនការ និងហិរញ្ញវត្ថុ

ដោយមានកាចូលរួមពីតំណាងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំសាធារណៈរដ្ឋ សហភាពមីយ៉ានម៉ា និងមន្ត្រីនៃអគ្គនាយកដ្ឋានដឹកជញ្ជូនផងដែរ។ ចំនួបពិភាក្សារបស់ក្រុមគណៈប្រតិភូនេះមានគោលបំណងស្វែងយល់អំពី កិច្ចដំណើរការនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋតាមរយៈយន្តការិយាល័យច្រកចេញចូលតែមួយជាពិសេសដើម្បីស្វែងយល់អំពី យន្តការផ្តល់សេវានានារបស់អគ្គនាយកដ្ឋានដឹកជញ្ជូនពាក់ព័ន្ធការគ្រប់គ្រងយានយន្ត និងមធ្យោបាយដឹកជញ្ជូនផ្សេងៗទៀតទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ថ្លែងនៅក្នុងបទបង្ហាញទៅកាន់ក្រុមគណៈប្រតិភូនាឱកាសនោះដែរ ឯកឧត្តមអគ្គនាយក **ពៅ ម៉ាលី** បានគូសបញ្ជាក់អំពីប្រវត្តិនៃ ការគ្រប់គ្រងការដឹកជញ្ជូនរបស់កម្ពុជា ជាពិសេស ការធ្វើប្រតិភូកម្មការចុះបញ្ជីយានយន្តទៅច្រកចេញចូលតែមួយ ការអនុញ្ញាតឱ្យម្ចាស់ហាងលក់យានយន្ត មានសិទ្ធិចុះបញ្ជីយានជំនិះតាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្មជូនដល់អតិថិជនប្រកបដោយតម្លាភាព ប្រសិទ្ធភាព កាត់បន្ថយការចំណាយក្រៅផ្លូវការ និងងាយស្រួលក្នុងការគ្រប់គ្រងសម្រាប់អាជ្ញាធរមានសមត្ថកិច្ចក្រោម គំនិតផ្តួចផ្តើមកំណែទម្រង់របស់ក្រសួងសាធារណការនិងដឹកជញ្ជូន។

ជាមួយគ្នានោះផងដែរ ក៏មានការចាក់បញ្ចាំងវីដេអូខ្លីប (Video) រយៈពេលប្រាំនាទី (៥min) បង្ហាញអំពីជម្រើសនៃ ការចុះបញ្ជីយានជំនិះជម្រើសនៃ ការបង់ប្រាក់គេហទំព័រស្តីពីការចុះបញ្ជីយានជំនិះសេវាបង់ប្រាក់ ការចេញបណ្ណសម្គាល់យានជំនិះ និងការកិបផ្លាកលេខនៅនឹងកន្លែងជូនអតិថិជនផងដែរ។

សូមជម្រាបថា៖ នៅថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០១៧ ក្រសួងសាធារណការ និងដឹកជញ្ជូនបានដាក់ឱ្យដំណើរការជាផ្លូវការនូវប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះ ត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ ផ្តល់បណ្ណបើកយានយន្ត កម្មវិធីយល់ដឹងអំពីទ្រឹស្តីនៃការបើកបរលើទូរស័ព្ទ ដើម្បីផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋឲ្យបានឆាប់រហ័ស កាត់បន្ថយការិយាធិបតេយ្យស្មុគស្មាញ និងអនុញ្ញាតឱ្យទូទាត់ប្រាក់កម្រៃសេវាតាមអនឡាញ (Online) ប្រកបដោយតម្លាភាព។

## ២.២. ការចុះបញ្ជីយានយន្តនៅកម្ពុជាក្នុងឆ្នាំ ២០១៦

ដោយឡែក ការចុះបញ្ជីយានយន្តគ្រប់ប្រភេទនៅទូទាំងប្រទេសក្នុងឆ្នាំ ២០១៦ នេះមានចំនួន ៤៥៩.៥៩៧ គ្រឿង ខណៈនៅឆ្នាំ ២០១៥ មានចំនួន ៣៩៨.៥០ គ្រឿង កើនឡើង ១.១ ភាគរយ ម្យ៉ាងវិញទៀតគិតត្រឹម ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១៦ យានយន្តដែលបាន ចុះបញ្ជីក្នុងរាជធានីភ្នំពេញមានចំនួនជាង ១លានគ្រឿង ក្នុងនោះមានម៉ូតូសរុបចំនួន ១.៦០១.៤៥១ គ្រឿងនិងរថយន្តសរុបចំនួន ៤៤២.៩៧២ គ្រឿង។ បើតាមរបាយការណ៍របស់ **លោក សាំ ពិសិដ្ឋ** ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនសាលារាជធានីភ្នំពេញផ្ញើរជូន អភិបាលរាជធានីភ្នំពេញ**លោក ប៉ា**

**សុជាតិខេង** នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៧ បានឱ្យដឹងថាក្នុងនោះមានរថយន្តគ្រប់ប្រភេទសរុបចំនួន ៩៤២.៩៧២ គ្រឿង រួមមានឯកជន ៩២៣.៩៥៨ គ្រឿង រាជការ ១១.៥៦១ គ្រឿង អង្គការអន្តរជាតិ ៧.៤៥៣ គ្រឿង។ ក្រសួងសាធារណការ និងដឹកជញ្ជូនបានកែប្រែពីការចុះបញ្ជីយានយន្តមកចុះបញ្ជីតាមប្រព័ន្ធអនឡាញ (Online) វិញ ដើម្បីធ្វើឱ្យបានលឿនរហ័សនិងមានប្រសិទ្ធភាពដែលក្រសួងបានដាក់ឱ្យសាកល្បងកាលពី ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ កន្លងមកហើយមកដល់ដើមខែមករាមានយានយន្តបានចុះបញ្ជីជាង២ពាន់គ្រឿង។ ប្រព័ន្ធនេះក្រសួងក៏បានដាក់ឱ្យ ប្រើប្រាស់នៅទូទាំងប្រទេស ដើម្បីសម្រួលដល់ការចុះបញ្ជីយានយន្តប្រជាពលរដ្ឋដោយខ្លួនឯង។

### ២.២.១. ប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជី

ប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីនិងត្រួតពិនិត្យបច្ចេកទេសយានយន្ត ព្រមទាំងកម្មវិធីប្រលងទ្រឹស្តីបើកបរលើទូស័ព្ទស្មាតហ្វូនរបស់ក្រសួងសាធារណការ និងដឹកជញ្ជូនត្រូវបានយកទៅដាក់តាំងបង្ហាញនៅក្នុងកិច្ចប្រជុំទូរគមនាគមន៍នឹងព័ត៌មានវិទ្យាអាស៊ានដែលបានប្រារព្ធធ្វើឡើងនៅក្នុងខេត្តសៀមរាបនាព្រឹក ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០១៧នេះ។ ប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ និងកម្មវិធីទ្រឹស្តីនៃ ការបើកបរទទួលបានការចាប់អារម្មណ៍ជាខ្លាំងពីបណ្តាមន្ត្រីមកពីប្រទេសនានាដែលបានចូលរួមកិច្ចប្រជុំ។ សូមរំលឹកថាក្រសួងសាធារណការ និងដឹកជញ្ជូនក្រោមកំណែទម្រង់ការផ្តល់សេវារបស់ លោក **ទេសរដ្ឋមន្ត្រី ស៊ុន ចាន់ថុល** នោះកាលពីខែ មករា ឆ្នាំ ២០១៧ បានដាក់ឱ្យដំណើរការប្រព័ន្ធស្វ័យប្រវត្តិកម្ម (Online) ចំនួន៣ ក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។

សេវាកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្មទាំង ៣ នេះរួមមាន៖ សេវាចុះបញ្ជីយានយន្ត សេវាត្រួតពនិត្យបច្ចេកទេសយានយន្ត និងសេវាផ្តល់បណ្ណបើកបរយានយន្ត។ ប្រព័ន្ធស្វ័យប្រវត្តិកម្មថ្មីនេះបានជួយសម្រួលនិងផ្តល់ភាពងាយស្រួលកាន់តែច្រើនជូនប្រជាពលរដ្ឋ ក្នុងការទៅរកសេវាចុះបញ្ជីយានយន្តត្រួតពិនិត្យបច្ចេកទេសយានយន្ត និងធ្វើបណ្ណបើកបរ។ ក្រសួងសាធារណការក៏បានសហការជាមួយកន្លែងលក់រថយន្ត និងចេញស្លាកលេខយានយន្តជូនអតិថិជនរបស់ខ្លួនបានផងដែរ។ ក្រសួងសាធារណៈការ បានឱ្យដឹងទៀតថា គិតចាប់ពីខែសីហាឆ្នាំ២០១៦ រហូតមកដល់ ខែ កញ្ញា ឆ្នាំ ២០១៧ មានរថយន្តមកចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្មរួមមាន៖ រថយន្តធុនស្រាលចំនួន ៦៤,០៤១ គ្រឿងរថយន្តធុនធ្ងន់ចំនួន ១០,២៩៩ គ្រឿង និងទោចក្រយានយន្តចំនួន ៤១២,០៩៩គ្រឿង។

## ២.៣. អង្គភាពដែលទទួលខុសត្រូវ

នាកយកដ្ឋានដឹកជញ្ជូនផ្លូវគោកទទួលបន្ទុករៀបចំត្រួតពិនិត្យបទបញ្ញត្តិទាំងឡាយ ដើម្បីគ្រប់គ្រងថែរក្សាសុវត្ថិភាព និងធ្វើការសម្របសម្រួលការដឹកជញ្ជូន តាមផ្លូវថ្នល់ ផ្លូវក្នុងទីក្រុង និង ផ្លូវដែក។

### ក. ការគ្រប់គ្រងតាមប្រព័ន្ធកុំព្យូទ័រទៅលើសកម្មភាពជាច្រើនដូចជា

- បញ្ចូលបណ្ណបើកបរវិញ្ញបណ្ណប័ត្រនៃការចុះឈ្មោះនិងការអនុញ្ញាតិដែលពាក់ព័ន្ធទៅនឹងការដឹកជញ្ជូនចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ
- គ្រប់គ្រងលិខិតស្នាមដែលទាក់ទងទៅនិងការប្រើប្រាស់ថវិកា
- រៀបចំនូវស្ថិតិទាំងឡាយនៃសកម្មភាពគ្រប់ទិសទាំងអស់

### ខ. ការគ្រប់គ្រងបទបញ្ញត្តិទាំងឡាយ និង ការគ្រប់គ្រងចរាចរណ៍

- ត្រួតពិនិត្យនូវបទបញ្ញត្តិទាំងឡាយដែលទាក់ទងនឹងចរាចរណ៍ផ្លូវគោក
- គ្រប់គ្រងការបណ្តុះបណ្តាលរបស់អ្នកប្រលងយកបណ្ណបើកបរ និងគ្រូបង្រៀនបើកបរ
- សម្រាប់សម្រួលនូវសកម្មភាពទាំងឡាយដែលទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍តាមផ្លូវគោក និងការគ្រប់គ្រងចរាចរណ៍ផ្លូវគោក
- ផ្តល់និងចែកចាយនូវការអនុញ្ញាតិផ្នែកចរាចរណ៍

### គ. រៀបចំ ផ្តួចផ្តើមគំនិត និងគ្រប់គ្រងការដឹកជញ្ជូនផ្លូវគោក

- សិក្សាអនុវត្ត និងគ្រប់គ្រងនូវបទបញ្ញត្តិទាំងឡាយព្រមទាំងចូលរួម និងធានានូវសុវត្ថិភាពក្នុងការដឹកជញ្ជូនអ្នកដំណើរ
- សិក្សាអនុវត្ត និងគ្រប់គ្រងនូវបទបញ្ញត្តិទាំងឡាយ ព្រមទាំងរួមចំណែកដើម្បីធានានូវការដឹកជញ្ជូនតាមផ្លូវគោកឱ្យបានល្អ
- ផ្តល់នូវការអនុញ្ញាត្តិក្នុងការដឹកជញ្ជូនជាអន្តរជាតិ និងក្នុងតំបន់សម្រាប់អ្នកដំណើរនិងទំនិញទាំងឡាយ
- ណែនាំដល់សាលាក្រុង និងពង្រីកនូវតំបន់ដែលទាក់ទងនឹងការដឹកជញ្ជូននៅក្នុងទីក្រុង និងក្នុងតំបន់ដែលត្រូវបានពង្រីក
- សម្របសម្រួលនូវបច្ចេកទេស និងតារាងតំលៃរវាងផ្លូវគោក និងផ្លូវដែក

### ២.៣.១. សមាសភាព

សមាសភាពដែលជាសមាជិកនៃគណៈកម្មការសម្របសម្រួលរួមមានមកពី៖

- អគ្គនាយកដ្ឋានពន្ធដារ
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងអគ្គស្នងការនគរបាលជាតិ
- អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក
- នាយកដ្ឋានព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ និងតំណាងអង្គការ JICA មួយ

ចំនួនផងដែរ។

### ២.៣.២. តួនាទី និងភារកិច្ច

### ២.៣.១. ភាគព្វកិច្ចក្រោយដាក់ពាក្យ

រាល់ការបំពេញពាក្យតាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់លោកអ្នកទាំងអស់នឹងត្រូវបានធ្វើការពិនិត្យចុងក្រោយដោយមន្ត្រីភ្នាក់ងាររបស់ក្រសួងសាធារណការនិងដឹកជញ្ជូនរាប់ទាំងកន្លែងមួយចំនួនដែលជាបញ្ជូររបស់ក្រសួង យើងនាំគ្នាមកមើលអំពីអ្វីដែលត្រូវធ្វើជាចុងក្រោយដោយមន្ត្រីភ្នាក់ងារ។

### ២.៣.២. តួនាទីរបស់មន្ត្រី

នៅខណៈពេលនេះជាតួនាទីរបស់ភ្នាក់ងារទាំងស្រុងក្នុងការបញ្ជាប់ ការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនេះត្រូវផ្តល់ជូនម្ចាស់យានយន្តដែលបានដាក់ពាក្យស្នើរសុំ៖

✓ ពិនិត្យ និងអនុម័ត ឬ ឯកភាព ដើម្បីបញ្ជូនពាក្យសុំទៅបោះពុម្ព ឯកសារដែលបានធ្វើការកំណត់រួចក្នុងប្រកាសស្តីពី បែបបទនិងនីតិវិធីនៃការចុះបញ្ជីយាយន្ត ការផ្តល់ផ្លាកលេខសម្គាល់យានយន្ត និងការលុបចេញពីបញ្ជីយានយន្ត បានចែងក្នុងប្រការ ៤ អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោកត្រូវគ្រប់គ្រងតាមដានត្រួតពិនិត្យ និងណែនាំអនុវត្ត ការចុះបញ្ជីយានជំនិះ ការអនុញ្ញាតបំពេញបែបបទចុះបញ្ជីយានជំនិះនៅក្នុងព្រះរាជាណាចក្រកម្ពុជា ការងារខាងក្នុងរបស់មន្ត្រីទាំងនោះមានដូចខាងក្រោម ៖

1. ពិនិត្យពាក្យសុំតាម Online
2. អនុម័តតាម Online

3. បញ្ជូនទៅបោះពុម្ពអូតូម៉ាទិច (automatic) គឺនៅពេលដែលមន្ត្រីរបស់យើងបានពិនិត្យឃើញថាពាក្យសុំត្រឹមត្រូវហើយនោះ។

4. ជូនដំណឹងទៅដល់អ្នកដាក់ពាក្យសុំឱ្យមកទទួលយកបណ្ណ និងផ្លាកលេខទៅអ្នកដាក់ពាក្យតាមរយៈ Email ,SMS

ការជូនដំណឹងនេះគឺត្រូវធ្វើឡើងតាមរយៈគណនីដែលលោកអ្នកបានបង្កើតនោះ ដូចដែលយើងបានបានធ្វើការរៀបរាប់ខាងលើនេះ។

## ២.៣.៣. ផ្ទៀងផ្ទាត់ឯកសារដើម និងផ្តល់ផ្លាកលេខ

- ផ្ទៀងផ្ទាត់ឯកសារដើម៖ នៅពេលម្ចាស់យានយន្តទៅទទួលយកបណ្ណ និងផ្លាកលេខតាមរយៈសារ SMS ឬ Email ត្រូវយកឯសារដើមទាំងអស់ដែលមានការទាក់ទងទៅនឹងយានយន្តរបស់លោកអ្នកជាពុំខាន ដើម្បីឱ្យមន្ត្រីភ្នាក់ងារធ្វើការពិនិត្យជាចុងក្រោយ នៅពេលដែលឯកសារទាំងអស់មានភាពត្រឹមត្រូវហើយនោះមន្ត្រីភ្នាក់ងារនិងធ្វើការកិបផ្លាកលេខជូនទៅលោកអ្នក។

- ផ្តល់ផ្លាកលេខ៖ ជាចុងបញ្ចប់នៃដំណើរការចុះបញ្ជីតាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ ម្ចាស់យានយន្ត និងភ្នាក់ងាររបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ឬបញ្ជូរភ្នាក់ងារដែលធ្វើការសហការជាមួយវិស័យសាធារណៈ។ សំណុំឯកសារចុះបញ្ជីយានជំនិះត្រូវបានធ្វើការរក្សាទុកដោយត្រឹមត្រូវ យោងទៅតាមប្រកាសស្តីពីបែបបទនីតិវិធីនៃការចុះបញ្ជីយានយន្ត ការផ្តល់ផ្លាកលេខសម្គាល់យានយន្ត និងការលុបចេញពីបញ្ជីយានយន្តក្នុងប្រការ ៨ បានចែង គ្រប់សំណុំឯកសារចុះបញ្ជីយានជំនិះត្រូវរក្សាទុកនៅ៖
  - ✓ អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោកចំពោះរថយន្តរម៉ក សីមីរ៉ុម៉ក
  - ✓ មន្ទីសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ចំពោះទោលចក្រយានយន្ត ត្រីចក្រយានយន្តកសិកម្មកែច្នៃ។

យើងមកប្រឡៃកមើលទៅលើរយៈពេលដែលម្ចាស់រថយន្តអាចទទួលបានផ្លាកលេខ និងប័ណ្ណសម្គាល់យានយន្តនោះគឺ មានរយៈពេល ១០ថ្ងៃ ទៅ៣០ថ្ងៃ នៅពេលដាក់ឲឱ្យប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មដំបូង តែនៅពេលក្រោយមកក្រសួងសាធារណការ និងដឹកជញ្ជូនបានធ្វើការបង្ហាញពីភាពងាយស្រួលដែលអាចទទួលបានផ្លាកលេខ និងបណ្ណសម្គាល់យានយន្តត្រឹមតែ ១ថ្ងៃ ដោយម្ចាស់រថយន្តធ្វើការអនុវត្តទៅតាមវិធីដែលបានរៀបរាប់។

# ជំពូកទី ៣
# ការអនុវត្តចុះបញ្ជី

## ៣.១. ការផ្សព្វផ្សាយ

### ៣.១.១. តាមទូរទស្សន៍ វិទ្យុ ប្រព័ន្ធសង្គម

យើងបានសង្កេតឃើញថាមានការផ្សព្វផ្សាយ នៅតាមវិទ្យុ FM ជា ណគរភ្នំ 103 MHZ នៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧ ស្តីអំពី ការប្រើប្រាស់ប្រព័ន្ធទំនើបកម្មក្នុងការចុះបញ្ជី និងផ្តល់ប័ណ្ណបើកបរយានយន្ត ដែលបានធ្វើឡើងដោយលោក **អ៊ុំ សារ៉ាវុធ** ជាប្រធានអង្គភាពចុះបញ្ជី និងផ្តល់បណ្ណ័បើកបរយាយន្តនៃមន្ទីសាធារណការ និងដឹកជញ្ជូនបានលើឡើងថា ពាក់ព័ន្ធនឹងការប្រើប្រាស់ប្រព័ន្ធទំនើបកម្មក្នុង ការចុះបញ្ជី និងផ្តល់បណ្ណបើកបរយានយន្តនេះពិតជាមានភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋក្នុងការចុះបញ្ជី។ ស្ថានីទូរទស្សន៍ CNC TV ក៏បានធ្វើការបង្ហាញអំពីលទ្ធផលនៃការចុះបញ្ជីយានយន្តតាមប្រព័ន្ធទំនើបកម្មនេះផងដែរ។

អ្វីដែលកាន់តែពិសេសជាងនេះទៅទៀតនោះ គឺបណ្តាញសង្គម Facebook របស់ក្រសួងសាធារណកានិងដឹកជញ្ជូន បានធ្វើការផ្សព្វផ្សាយអំពីសារៈប្រយោជន៍ដែលនឹងទទួលបានពីការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនេះជាច្រើន មិនត្រឹមតែប៉ុណោះអ្នកកាន់គេហទំព័រក៏បានធ្វើការបង្ហោះនូវវិដេអូ (Video) ស្តីអំពី នីតិវិធីនៃការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្មបន្ថែមទៀតផង។

### ៣.១.២. ការធ្វើសិក្ខាសាលា

ពិធីដាក់ឱ្យដំណើរការជា ផ្លូវការប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ ផ្តល់បណ្ណបើកបរយានយន្ត កម្មវិធីយល់ដឹងអំពីទ្រឹស្តីនៃការបើកទូរស័ព្ទនៅព្រឹកថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៧ ឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូនបានអញ្ជើញជាអធិបតី ពិធីដាក់ឱ្យដំណើរការជាផ្លូវការប្រព័ន្ធស្វ័យប្រវត្តកម្មចុះបញ្ជីយានជំនិះ ត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ ផ្តល់បណ្ណ័បើកបរយានកម្មវិធីយល់ដឹងអំពីទ្រឹស្តីនៃការបើកលើទូរស័ព្ទដែលបានប្រព្រឹត្តទៅនៅសណ្ឋាគារ Intercontinental Phnom Penh។ ពីធីដាក់ឱ្យដំណើរការនេះ មានការអញ្ជើញចូលរួមពីឥស្សរជនជាន់ខ្ពស់ថ្នាក់ ដឹកនាំក្រសួងសាធារណការ និងដឹកជញ្ជូន មន្ត្រីជាន់ខ្ពស់អន្តរក្រសួង សមាជិកគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក (NRSC) ឯកអគ្គរដ្ឋទូតដៃគូរអភិវឌ្ឍន៍មន្ត្រីធនាគារ និងភាគីពាក់ព័ន្ធវិស័យឯកជនផ្សេងទៀត ក្រុមហ៊ុនចែកចាយនិងលក់រថយន្ត និងសាលារៀនបើកបរសរុបទាំងអស់

ប្រមាណ ៣០០ នាក់។ កម្មវិធីនេះមានគោលបំណងផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋបានដឹងជ្រួតជ្រាប អំពីការដាក់ឱ្យដំណើរការជាផ្លូវការប្រព័ន្ធស្វ័យប្រវត្តកម្មដែលបានបង្កើតឡើង ក្រសួងសាធារណការនិងដឹកជញ្ជូនមានជាគំនិតផ្តួចផ្តើមកំណែទម្រង់ដ៏សំខាន់មួយក្នុងការផ្ទេរសេវា ដោយប្រសិទ្ធភាពសម្រាប់ប្រជាពលរដ្ឋទៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មអនឡាញ (Online) របស់ក្រសួង ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** បានលើកឡើងអំពីសារៈសំខាន់នៃប្រព័ន្ធស្វ័យប្រវត្តិកម្មទាំងនេះថាជា មធ្យោបាយធ្វើទំនើបកម្មសេវាកម្មសម្រាប់ប្រជាពលរដ្ឋពាក់ពន្ធ័ នឹងការដឹកជញ្ជូនកម្ពុជាអាចជួយសម្រួល ដល់ការចុះបញ្ជីយានយន្ត និងការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ដបាន ឆាប់រហ័សកាត់បន្ថយការិយាធិបតេយ្យស្មុគស្មាញ និងអនុញ្ញាតឱ្យទូទាត់ប្រាក់កម្រៃសេវាតាមអនឡាញ (Online) ប្រកបដោយតម្លាភាពសម្រាប់ប្រជាពលរដ្ឋផងដែរ។ កម្មវិធីស្មាតហ្វូន (Smart Phone) ដែលអាចទាញយកមានឈ្មោះថា ច្បាប់នៃការបើកបរកម្ពុជាដែលនឹងត្រូវប្រើសម្រាប់អ្នកដែលចង់ត្រៀមខ្លួនប្រឡងយកប័ណ្ណបើកបរ។ នៅចុងបញ្ចប់នៃកម្មវិធីនេះ ឯកឧត្តមទេសរដ្ឋមន្ត្រីបានកត់សម្គាល់ថា ដៃគូរអភិវឌ្ឍន៍ក្នុងគំនិតផ្តួចផ្តើមនេះ គឺជាក្រុមហ៊ុនខ្មែរទាំងអស់ ហើយ ឯកឧត្តមទេសរដ្ឋមន្ត្រីក៏បានសម្តែងនូវ ការកោតសរសើរចំពោះក្រុមហ៊ុនទាំងនោះដែលបានជួយអភិវឌ្ឍន៍ប្រព័ន្ធនិងកម្មវិធី App ទាំងនេះក៏ដូចជាបានជួយឧបត្ថមដល់ការដាក់ឱ្យដំណើរ ការប្រព័ន្ធនេះផងដែលក្នុងនោះរួមមានក្រុមហ៊ុន KTS, CMBIC, HK, WING, SMARTLY, BMW, CAM INFO, BLUE TECHNOLOGY, KHICT, SINET និង MITSUBISHI MOTORS។ បទបង្ហាញស្តីពីប្រព័ន្ធស្វ័យប្រវត្តិកម្ម ប្តូរ ពន្យារ និងចុះបញ្ជីប័ណ្ណបើកបរ ចុះបញ្ជីយានយន្ត និងត្រួតពិនិត្យបច្ចេកទេសយានយន្ត (ឆៀក) នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ ២០១៦ **ឯកឧត្តម ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន បានទទួលជួបពិភាក្សាការងារ ជាមួយគណៈប្រតិភូតដែលដឹកនាំដោយលោក Jonas Lind នាយកប្រតិបត្តិ និងលោក Ahmad Faudzil Hashim ប្រធានក្រុមហ៊ុន Hei Tech global Services លោក Ong chin Wei នាយកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនប្រឹក្សាយោបល់ Vantagepoint Consulting លោក Bernt Ola Bernsten នាយកគ្រប់គ្រងនៃក្រុមហ៊ុន Silverlake Group និងលោក Tan khee Kheng ប្រធានគ្រប់គ្រងដៃគូរនៃក្រុមហ៊ុនBaker Tilly MH Audit Ltd។ ក្រុមការងារនេះបានធ្វើបទបង្ហាញអំពី ប្រព័ន្ធស្វ័យប្រវត្តិកម្ម ប្តូរ ពន្យារ និងចុះបញ្ជីបណ្ណបើកបរចុះបញ្ជីយានយន្ត និងត្រួតពិនិត្យបច្ចេកទេសយានយន្តដែលត្រូវបានដាក់ឱ្យដំណើរការដោយជោគជ័យនៅប្រទេសម៉ាឡេស៊ី និងប្រទេសដទៃទៀតនៅទូទាំងពិភពលោក។

ក្រុមការងារនេះបានពិភាក្សាជាមួយឯកឧត្តមទេសរដ្ឋមន្ត្រី អំពីបញ្ហាប្រឈមក្នុងការធ្វើសមាហរណកម្មប្រព័ន្ធ និងបញ្ហាផ្សេងទៀតទាក់ទងទៅនឹង ប្រព័ន្ធថ្នាក់ជាតិដែលអាចផ្តល់សេវាជូនសាធារ

ណៈជនទាន់ពេលវេលា និងមានប្រសិទ្ធភាពនៅគ្រប់រាជធានីខេត្តទូទាំងប្រទេស។ នៅព្រឹកថ្ងៃសុក្រ ទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៥ នេះក្រសួងសាធារណការនិងដឹកជញ្ជូន កម្ពុជាបានរៀបចំសិក្ខាសាលា ជាមួយក្រសួងរៀបចំដែនដី និងដឹកជញ្ជូនទេសចរណ៍ប្រទេសជប៉ុន ក្នុងគោលបំណង ដើម្បីពិភាក្សាអំពីបញ្ហាថ្មីៗទាក់ទងនឹងការចុះបញ្ជី និងត្រួតពិនិត្យលក្ខណៈបច្ចេកទេសធ្វើយ៉ាងណាឱ្យមានសុវត្ថិភាពចរាចរណ៍តាមដងផ្លូវ។ កាពិភាក្សានេះរៀបចំឡើងដោយក្រសួងសាធារណការ និងដឹកជញ្ជូនកម្ពុជាជាមួយក្រសួងរៀបចំដែនដី និងដឹកជញ្ជូនទេសចរណ៍ប្រទេសជប៉ុន នៅថ្ងៃទី ០៦ ខែ វិច្ឆិកា។ រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូនលោកស្រី **មិន មានវី** បានមានប្រសាសន៍តាមរយៈអ្នកបកប្រែថា ប្រភេទយានយន្តដែលបានជួសជុលមិនត្រឹមត្រូវបានបង្កឱ្យមានផលប៉ះពាល់ដល់សុវត្ថិភាពចរាចរណ៍ និងបង្កគ្រោះថ្នាក់ចរាចរណ៍នៅក្នុងប្រទេសកម្ពុជា។ លោកស្រីថា បញ្ហានេះត្រូវតែដោះស្រាយជាន្ទាន់។ ប្រភេទនៃយានយន្តបានបង្កនូវបញ្ហាសុវត្ថិភាពចរាចរណ៍ និងសម្រាប់បញ្ហាបរិស្ថានផងដែលជាមួយនឹងការជួសជុលមិនបានត្រឹមត្រូវ ព្រមទាំងលក្ខខ័ណ្ឌមួយចំនួនដែលវា ប៉ះពាល់គ្រោះថ្នាក់ឧបទ្ទវហេតុចរាចរណ៍នៅក្នុងប្រទេសកម្ពុជាហើយអ្វីដែលជាការសំខាន់ថែមទៀតនោះគឺប្រព័ន្ធនៃ ការចុះបញ្ជីនិងត្រួតពិនិត្យត្រូវបានប្រើប្រាស់ជា ១០ ឆ្នាំមកហើយ ហើយវាមិនស្របទៅតាមភាពកើននៃយានយន្ត និងការគ្រប់គ្រងយានយន្ត និងប្រព័ន្ធគ្រប់គ្រង ដូច្នេះហើយការដោះស្រាយបញ្ហាទាំងអស់នេះ គួរត្រូវតែដោះស្រាយជាបន្ទាន់។

លោកស្រីបន្តថាសិក្ខាសិលានៅថ្ងៃនេះ ផ្តោតជាសំខាន់ទៅលើសកម្មភាពថ្មីៗនានាក្នុងការធ្វើឱ្យប្រសើរឡើងនូវការចុះបញ្ជីយានយន្ត និងរដ្ឋបាលនៃការត្រួតពិនិត្យនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងការផ្លាស់ប្តូរបទពិសោធន៍ពីប្រទេសជប៉ុននៅក្នុងគម្រោងមួយនេះ។ លោកស្រីថា ការចុះបញ្ជីយានយន្ត និងការត្រួតពិនិត្យយានយន្តជា កត្តាសំខាន់ក្នុងការធ្វើឱ្យប្រសើរឡើងនូវសុវត្ថិភាពចរាចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងតាមឱ្យទាន់នូវកំណើននៃយានយន្ត និងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក និងភ្ជាប់ជាមួយនឹងខេត្ត និងបណ្តាញភ្នាក់ងារផ្សេងទៀតដែលពាក់ព័ន្ធដូចជាអគ្គនាយកដ្ឋានពន្ធដា អគ្គនាយកដ្ឋានគយ និងរដ្ឋាករនៃកម្ពុជា និងប្រព័ន្ធត្រួតពិនិត្យចុះបញ្ជីដែល មានទំនាក់ទំនងគ្នាពាក់ពន្ធទៅនឹងការកាន់កាប់កម្មសិទ្ធិនៃយានយន្ត។ ទាក់ទងនឹងករណីខាងលើនេះដែរ អគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូនក្រសួងសាធារណការ និងដឹកជញ្ជូនលោក **ចាន់ តារា** បានប្រាប់អ្នកសារព័ត៌មាននៅថ្ងៃសុក្រ ទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៥នេះដែរថា ពេលបច្ចុប្បន្ននេះប្រទេសកម្ពុជា មានមជ្ឈមណ្ឌលត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តចំនួន ៦ កន្លែង។

លោកថា ក្នុងការត្រួតពិនិត្យយានយន្តនេះរាល់យានយន្តតាមបណ្តាខេត្តទាំងអស់ អាចទៅធ្វើការត្រួតពិនិត្យបានទៅលើទីតាំងទាំង ៦ នោះ មានរាជធានីភ្នំពេញ ២ កន្លែង ក្នុងនោះមានមួយនៅកន្លែងចាស់ គឺអគ្គនាយកដ្ឋានដឹកជញ្ជូន នៅពេលបច្ចុប្បន្ននេះគឺជិតស្នងការដ្ឋានរាជធានី ហើយមួយ កន្លែងទៀតនៅតាមផ្លូវទៅចំការដូងស្ទឹងមានជ័យ និងនៅកំពង់ចាម សៀមរាប បាត់ដំបង និងក្រុងព្រះសីហនុ ហើយទិសដៅអនាគត នឹងមានកន្លែងត្រួតពិនិត្យបច្ចេកទេសយានយន្តគ្រប់ខេត្តក្រុងទាំងអស់។ លោក ចាន់ តារា បន្តថា គិតចាប់តាំងពីឆ្នាំ ១៩៩៣ រហូតមកដល់បច្ចុប្បន្ន យានយន្តដែលបានមកត្រួតពិនិត្យបច្ចេកទេសមានចំនួន ៣ លាន គ្រឿង រីឯយានយន្តដែលមិនទាន់បានចុះបញ្ជី គឺលោកមិនអាចប៉ាន់ស្មានបាននោះទេ។ សូមជ្រាបថា ក្នុងសិក្ខាសាលានេះក្រុមមន្ត្រីឱ្យដឹងថាអ្នកប្រើប្រស់យានយន្តដែលមិនបានយកទៅចុះបញ្ជីនិងមិនបានយកទៅត្រួតពិនិត្យបច្ចេកទេស គឺជាការល្មើសច្បាប់ចរាចរណ៍ផ្លូវគោក ហើយអ្នកទាំងនោះនឹងត្រូវទទួលបានការពិន័យ ប៉ុន្តែក្រុមមន្ត្រីមិនបានបញ្ជាក់ថា តើការពិន័យនោះមានកម្រិតណានោះទេ។

### ៣.២. នីតិវិធីនៃការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យវត្តិកម្ម

ការបង្ហាញ ឬបង្រៀនទៅឱ្យប្រជាពលរដ្ឋបានយល់ច្បាស់ពីភាពងាយស្រួលនៃការចុះបញ្ជីយានយន្ត ដោយធ្វើបានលឿនៗបែបនេះ លុះត្រាតែប្រជាពលរដ្ឋយល់ពីរបៀបនៃការប្រើប្រាស់ប្រព័ន្ធនេះនៅខាងក្រោម និងធ្វើការបកស្រាយឱ្យបានលម្អត

#### ៣.២.១. ជំហានដំបូង Vehicle.mpwt.gov.kh

Vehicle.mpwt.gov.kh នេះគឺជាគេហទំព័រក្នុងការប្រើប្រាស់សម្រាប់ធ្វើការចុះបញ្ជីយានយន្តតាមប្រព័ន្ធអនឡាញ (online) នោះ ដូច្នេះហើយមុន នឹងអាចចូលទៅកាន់គេហទំព័រនេះបានយើងត្រូវមានគ្រឿងអេឡិចត្រូនិចមួយដែលអាចធ្វើការតភ្ជាប់អ៊ិនធឺណេត (Internet) បានទាំងអស់នោះមានដូចជា Smart ទូរស័ព្ទ (Phone),កុំព្យូទ័រ (Computer) និងឧបករណ៍អេឡិចត្រូនិចផ្សេងៗ បន្ទាប់មកយើងត្រូវធ្វើការបើកទៅលើ App មួយចំនួនដូចជា Google Firefox និងមាន App ជាច្រើនទៀតដែលអាចប្រើប្រាស់បាន ហើយធ្វើការវាយបញ្ចូលពាក្យដែលមានដូចជា Vehicle.mpwt.gov.kh ក្រោយមកពេលដែលយើងអាចធ្វើការបើកនូវគេហទំព័រនេះរួចហើយយើងនឹងបានឃើញពីរបៀបប្រើប្រាស់ ហើយលោកអ្នកអាចធ្វើការជ្រើសរើសភាសាមកប្រើប្រាស់បាន ដោយក្នុងនោះមានភាសាចំនួន(២) ពីរ គឺភាសាខ្មែរ និងភាសាអង់គ្លេស សម្រាប់ធ្វើការបង្កើតគណនីផ្ទាល់ខ្លួន សម្រាប់ដំណើការប្រព័ន្ធនេះដើម្បីទិញលេខបាន លក្ខណៈងាយស្រួល ឬពិសេសនេះ ដោយលោកអ្នកអាចទិញលេខទុកមុនពេលលោកអ្នកមានរថយន្តបាន។

ប្រសិនបើលោកអ្នកមានបំណងធ្វើការចុះបញ្ជីយានយន្តរបស់លោកអ្នកដោយផ្ទាល់ត្រូវតែធ្វើការបង្កើតគណនីផ្ទាល់ខ្លួនជាមុន ដើម្បីធ្វើការបំពេញពាក្យតាមអនឡាញ (Online)។

តារាងទី១៖ ប្រកាសលក់




### ៣.២.២. ការបង្កើតគណនីប្រើប្រាស់/ ភត់ត្រាចូលប្រព័ន្ធ

ដូចដែលបានរៀបរាប់នៅខាងលើយើងមកមើលថា តើត្រូវធ្វើបែបណាខ្លះ? យើងត្រូវធ្វើការស្វែងរកពាក្យថា បង្កើតគណនី នៅក្នុងគេហទំព័រដែលបានបង្ហាញខាងលើ Vehicle.mpwt.gov.kh ហើយធ្វើការពិនិត្យមើលទៅលើ ផ្នែកខាងលើផ្ទាំងដែលបានបង្ហាញនៅលើគេហទំព័រដែលកំពុងមានដំណើរការលើកុំព្យូទ័រ (Computer) របស់លោកអ្នកពីព្រោះវាមានការបង្ហាញយ៉ាងច្បាស់ តែក្នុងករណីដែលលោកអ្នកប្រើប្រាស់គេហទំព័រនៅលើទូរស័ព្ទ (Smart Phone) នោះលោកអ្នកនឹងឃើញពីភាពខុសគ្នាពីនៅលើកុំព្យូទ័រ (Computer) បន្តិច គឺលោកអ្នកត្រូវចុចលើទីកន្លែងមួយទៀតទើបអាចរកឃើញពាក្យថា "បង្កើតគណនី" ដែលមានសញ្ញាដូចក្នុងរូបនេះ ☰ សម្រាប់ប្រព័ន្ធ Android បន្ទាប់មកលោកអ្នកនឹងបានឃើញ សូមស្វែងរកពាក្យថា បង្កើតគណនី ដើម្បីបង្កើតគណនីផ្ទាល់ខ្លួននាក់ចំពោះចំណុចនេះមិនថាកុំព្យូទ័រ (Computer) ឬទូរស័ព្ទ (Smart Phone) មានលក្ខណៈដូចគ្នា។ នៅពេលដែលយើងចុចទៅលើពាក្យថា បង្កើតគណនី រួចហើយនិងមានការបង្ហាញតារាងមួយ សម្រាប់លោកអ្នកធ្វើការបំពេញព័ត៌មានផ្ទាល់ខ្លួនដូចខាងក្រោម

តារាងទី២៖ របៀបបង្កើតគណនីថ្មី




នៅពេលដែលលោកអ្នកបានបំពេញគ្រប់ទៅតាមអ្វីដែលមាន នៅក្នុងតារាងនោះរួចហើយ លោកអ្នកត្រូវចុចទៅលើពាក្យខាងក្រោម √ I'm not a robot. ជាចុងក្រោយត្រូវចុចលើពាក្យ បង្កើតគណនីជាការស្រេច។ បន្ទាប់ពីពេលដែលដំណើរការនៃប្រព័ន្ធការរួចរាល់ហើយលោកអ្នក នឹងទទួលបាន Mail ឬ SMS ពីក្រសួងសាធារណការនិងដឹកជញ្ជូនថា លោកអ្នកបានបង្កើត គណនីបានសម្រេចនោះលោកអ្នកអាចធ្វើការជ្រើសរើសទិញ និងចុះបញ្ជីយានយន្តបានដោយ ខ្លួនឯងបាន។ សម្រាប់ការជ្រើសរើសទិញដោយលោកអ្នកត្រូវត្រឡប់ទៅមើលលើគេហទំព័រ ដើមវិញ ដើម្បីពិនិត្យមើលថាលេខណាខ្លះដែលបានធ្វើការដាក់លក់។ប្រសិនបើលោកអ្នកមាន ការស្រឡាញ់ទៅលើលេខណាមួយដែលកំពុងដាក់លក់នោះហើយ ខណ:ពេលលោកអ្នកមិន ទាន់មានយានយន្ត លោកអ្នកក៏អាចធ្វើការទិញលេខនោះទុកសម្រាប់ប្រើប្រាស់នៅពេលក្រោយ ក៏បានដែរ។

### ៣.២.៣. ការជ្រើសរើស "ទិញ និងចុះបញ្ជី"

ដំណើរការនៃការទិញស្លាកលេខដែលបានដាក់លក់នៅលើគេហទំព័រនោះគឺ បានធ្វើការកំណត់យ៉ាងច្បាស់លាស់ទៅតាមប្រភេទរថយន្តនីមួយៗ ក៏មានការកំណត់ដូចគ្នា។ គ្រប់ស្លាកលេខដាក់លក់នៅលើគេហទំព័រគឺបានធ្វើការកំណត់តម្លៃនៃស្លាកលេខនោះរួចជាស្រេច ដូចនេះរាល់អ្នកដែលមានបំណងទិញអាចធ្វើការជ្រើសរើសលេខដែលខ្លួនស្រឡាញ់បានរួមទាំងបានដឹងពីតម្លៃរួចជាមុន វាធ្វើឱ្យលោកអ្នកមានភាពងាយស្រួលសម្រាប់ការចំណាយ។

- ចំពោះការទិញនៅពេលអ្នកកំពុងស្ថិតនៅលើគេហទំព័រលោកអ្នកនឹងបានឃើញតារាងមួយដែលបានដាក់ថា តារាប្រកាសផ្លាក់លេខលក់។

ដើម្បីធ្វើឱ្យការទិញរបស់លោកអ្នកអាចដំណើរការទៅបាន ដោយមិនមានការខំខាននោះលោកអ្នកត្រូវបំពេញទៅតាម ប្រវត្តិរូបដោយគ្មានការក្លាងបន្លំព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក។ វិធីធ្វើឱ្យលោកអ្នកអាចធ្វើការបំពេញនូវព័ត៌មានឱ្យកាន់តែងាយស្រួលនោះ យើងនឹងធ្វើការបង្ហាញឱ្យបានលម្អិតពី ការបំពេញតារាងដែលមានប្រអប់សម្រាប់បំពេញព័ត៌មានអំពីរថយន្តដូចជា ប្រភេទយានយន្ត មានន័យថារថយន្តដែលលោកអ្នកបានទិញនេះ ជារថយន្តធនធូន រថយន្តធនស្រាល់ជាដើម។ ប្រភេទផ្លាកលេខ ចង់ប្រាប់ទៅឱ្យអ្នកទិញបានដឹងថា បើលោកអ្នកមានអាស្រយដ្ឋាន អចិន្ត្រៃនៅទីណានោះលោកអ្នកត្រូវជ្រើសយកកន្លែងនោះ។ ឧទាហរណ៍ បើលោក (ក) រស់នៅខេត្ត កំពង់ចាម នោះលោក (ក) ត្រូវចុចយកពាក្យថា កំពង់ចាម ដែលមានក្នុងប្រអប់ស្រាប់ដោយចុចលើសញ្ញា នឹងមានឃើញខេត្តដែលលោក (ក) ត្រូវបំពេញ ពីព្រោះថានៅក្នុងប្រអប់នោះគឺអាចឱ្យលោក (ក) ធ្វើការជ្រើសរើសបានគ្រប់ខេត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែដើម្បីឱ្យការទិញរបស់លោក (ក) ដំណើការបានរលូននោះលោក (ក) ត្រូវបំពេញឱ្យបានត្រឹមត្រូវតាមប្រវត្តិរូបរបស់គាត់ ដែលបានបំពេញពីពេលបង្កើតគណនី។ ស៊េរីអក្ស ជាអក្សរ៍ដែលនឹងធ្វើការសេសរដាក់ភ្ជាប់ជាមួយលេខចំនួនបួនខ្ទង់ ដោយអក្សទាំងនេះមានដូចជា A , AA ,AT, AU នេះជាដើម។ ដើម្បីភាពងាយស្រួល ក្នុងការស្វែងរកនូវស៊េរីអក្សរ៍កំពុងដាក់លក់នៅលើគេហទំព័រ អាចធ្វើការបំពេញទៅលើផ្នែកខាងលើដូចរូបភាពនេះបាន

តារាងទី៣ បញ្ជាក់អក្សរ







❖ ការចុះបញ្ជី ការចុះបញ្ជីយានយន្តរបស់លោកអ្នកចាប់ពីពេលអ្នកជ្រើសរើសបានលេខស្រឡាញ់ហើយ ដើម្បីទទួលបានលេខនោះត្រូវធ្វើការបំពេញនូវព័ត៌មានមួយចំនួន ឬ ជំហានទៀតដែលយើងនឹងធ្វើការបកស្រាយឱ្យបានលម្អិតនៅខាងក្រោមៈ

### ២.៣.១. ព័ត៌មានផ្ទាល់ខ្លួន

ជាធម្មតា រាល់ការធ្វើអ្វីមួយឯកសារណាមួយអាចទុកជាការបាននោះវាពិតប្រាកដណាស់ដែលត្រូវតែធ្វើការបំពេញនូវព័ត៌មានផ្ទាល់ខ្លួន ឬដែលមនុស្សភាគច្រើនហៅថា ប្រវត្តិរូបសង្ខេបនេះឯង។ បែបនេះហើយយើងមកមើលថា តើត្រូវបំពេញអ្វីខ្លះទៅនូវជំហានទី១ នៃការចុះបញ្ជីយានយន្តរបស់លោកអ្នកក្នុងការទិញផ្លាកលេខតាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ។ លោកអ្នកត្រូវបំពេញឈ្មោះរបស់អ្នកទៅក្នុងប្រអប់ ទាំងឈ្មោះជាភាសាខ្មែរ នឹងជាភាសាឡាតាំង ភេទ ថ្ងៃ ខែ ឆ្នាំ កំណើត និងសញ្ជាតិ ជាភាពងាយស្រួលក្នុងការបំពេញនូវជំហាននេះ លោកអ្នកអាចយកអត្តសញ្ញាណប័ណ្ណរបស់លោកអ្នកមកបំពេញតាមបានដោយហេតុថា នៅក្នុងអត្តសញ្ញាប័ណ្ណគឺមានព័ត៌មាននេះរួចជាស្រាច ដោយត្រឹមត្រូវមិននាំឱ្យលោកអ្នកខាត់ពេលវេលា។

## ២.៣.២. បញ្ជាក់លេខ និងទម្រង់ផ្លាកលេខ

❖ **បញ្ជាក់លេខ** នេះជាជំហានទី ២ ដែលអ្នកទិញត្រូវបំពេញអំពីព័ត៌មានពីលេខរថយន្ត ដោយមានដូចជា ប្រភេទយានយន្ត លោកអ្នកអាចស្វែងរកប្រភេទយានយន្តរបស់អ្នក នៅក្នុងប្រអប់នោះបានរថយន្តដែលបានទិញ។ ផ្លាកលេខ លោកអ្នកត្រូវទៅធ្វើការស្វែងរកលេខ ដែលមាននៅក្នុងប្រអប់នោះពីលេខរបស់លោកអ្នកបានស្រឡាញ់ក្រោយពីបានពិនិត្យមើលនៅលើតារាងដំបូងពេលចូលទៅចុចលើពាក្យថាចុះបញ្ជីយានយន្ត

រូបភាព បញ្ជាក់ពីការទិញផ្លាកលេខ




❖ **ប្រភេទផ្លាកលេខ** ដូចដែលបានរៀបរាប់ខាងលើរួចហើយនៅក្នុងប្រអប់នោះគឺត្រូវរើសយកខេត្ត ឬរាជធានីបានត្រឹមត្រូវតាមអាសយដ្ឋានអចិន្ត្រៃរបស់លោកអ្នក។

❖ **តម្លៃជា** ប្រអប់ត្រូវបំពេញទឹកប្រាក់នៃថ្លៃផ្លាកលេខ ដែលអ្នកចង់ទិញ ហើយតម្លៃនោះក៏បាន បង្ហាញយ៉ាងច្បាស់នៅលើតារាងផ្លាកលេខដែលប្រកាសលក់ស្រាប់។

❖ **ស្ថានភាព** នៅក្នុងប្រអប់នេះលោកអ្នកត្រូវធ្វើការជ្រើសរើសនូវជំរើសមួយសម្រាប់បង់ប្រាក់ជាមួយនឹងដៃគូរសហការជាមួយក្រសួង ( មិនទានទូរទាត់ ឬទូទាត់) មានន័យថាប្រសិនបើលោកអ្នកមានគណនីណាមួយដូចជាវីង (Wing) នោះលោកអ្នកអាចធ្វើការទូទាត់បានដោយលោកអ្នក ចុចយកពាក្យថា ទូរទាត់នោះវានឹងឱ្យលោកអ្នកធ្វើការបញ្ចូលនូវលេខគណនីវីង (Wing) របស់លោកអ្នក តែបើលោកអ្នកគ្មានគណនីណាមួយនោះទេលោកអ្នកចុចយកពាក្យថា មិនទាន់ទូរទាត់នោះភ្នាក់ងារនិងផ្ញើរសារអេឡិចត្រូនិច (SMS) ឬអ៊ីម៉ែល (Mail) ទៅតាមការបង្កើតគណនីទិញរបស់លោកអ្នកតាមប្រព័ន្ធស្វ័យប្រត្តិកម្មនេះ។

❖ **ទម្រង់ផ្លាកលេខ** នៅពេលដែលលោកអ្នកបានជ្រើសរើសលេខបានរួចរាល់ហើយអ្វីត្រូវធ្វើបន្តនេះគឺ ការជ្រើសរើសទំហំផ្លាកលេខសម្រាប់កិបភ្ជាប់ជាមួយនិងរថយន្ត ដោយក្នុងនោះមន្ត្រីគាត់បានធ្វើទៅតាមភាពជឿនលឿន គឺលោកអ្នកអាចស្នើរធ្វើផ្លាកលេខដែលមានប្រវែងវែងជាងផ្លាកលេខធម្មតា ប៉ុន្តែនៅក្នុងករណីនេះអ្នកត្រូវធ្វើការបន្ថែមទឹកប្រាក់ចំនួន ១៨០០០ រៀបន្ថែមលើតម្លៃដែលបានដាក់នៅក្នុងតារាប្រកាសលក់ ដើម្បីទទួលបានផ្លាកលេខទំហំវែងនោះ។ ទំហំនៃផ្លាកលេខនោះមាន ការបែងចែកជាប្រភេទ

A. ១២.០ * ៥២.០

B. ១៤.០ * ៥០.០

C. ១៦.០ * ៥២.០

D. ១៦.៥ * ៣១.៥

ទាំងអស់នេះគឺជាទំហំផ្លាកលេខដែលលោកអ្នកអាចធ្វើការជ្រើសរើសទៅតាមការពេញចិត្តតែត្រូវបន្ថែមចំនួន ១៨០០០ រៀលដូចគ្នាគ្រប់ទំហំ។

### ២.៣.៣. ព័ត៌មានរថយន្ត

ការបង្ហាញព័តិមានអំពីរថយន្តរបស់លោកអ្នកដែលបានទិញរួចក៏ ជាតម្រូវការចាំបាច់ក្នុងការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនេះដំណើរការលើចំណុចមួយនេះគឺត្រូវធ្វើការបំពេញដូចជា ម៉ាករថយន្ត ម៉ូឌែល ពណ៌ កម្លាំងសេះ ប្រភេទ ចំនួនភ្លៅ ចំនួនស៊ីឡាំង។

### ២.៣.៤. ការវិភាគមកទទួលប័ណ្ណ និងផ្លាកលេខ

ក្រោយពីពេលដែលលោកអ្នកបានធ្វើការបំពេញនូវរាល់ជំហ៊ានខាងលើរួចរាល់បានត្រឹមត្រូវហើយនោះលោកអ្នកត្រូវកំណត់ទីតាំងដែលត្រូវទៅទទួលផ្លាកលេខរបស់លោកអ្នក ដើម្បីជាភាពងាយស្រួលដល់អ្នកទទួលសេវាក្រសួងសារធារណាការនិងដឹកជញ្ជូនបានអនុញ្ញាតឱ្យម្ចាស់យានយន្ត អាចធ្វើការកំណត់យកនៅទីតាំងណាមួយដែលនូវជិតលោកអ្នកបំផុត តាមរយៈការិយាល័យច្រកចេញចូលតែមួយនៅគ្រប់ខេត្ត រាជធានី។ ឧទាហណ៍ លោក (ខ) រស់នៅខេត្តកំពង់ចាម ដូចនេះគាត់អាចធ្វើការកំណត់យកនូវ មន្ទីសាធារណៈការ និងដឹកជញ្ជូននៅទីនោះ ឬនៅបញ្ជូរភ្នាក់ងាររបស់មន្ទីបាន ពិសេសជាងនេះលោកអ្នកជាអ្នកធ្វើការកំណត់នៅថ្ងៃទៅយកបានថែមទៀត ដូចជា លោក (ខ) ចង់បាននូវថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៨។

### ២.៣.៥. ឯកសារភ្ជាប់ដែលត្រូវយកមកជាមួយ

តាមប្រការ ៨ នៃប្រកាសស្តីពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីយានយន្ត ការផ្តល់ផ្លាកលេខយានយន្ត និងការលុបចេញពីបញ្ជីយានយន្តបានចែងថា " ម្ចាស់យានយន្តត្រូវដាក់ពាក្យសុំចុះបញ្ជីយានជំនិះ តាមប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះដែលមានអាស័យដ្ឋាន vehicle.mpwt.gov.kh ទៅទីតាំងផ្តល់សេវាសាធារណៈរបស់ក្រសួងសធារណការ និងដឹកជញ្ជូន តាមគំនូរបំព្រួញអំពីការចុះបញ្ជីយានជំនិះដូចមានចែងក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

ដោយត្រូវភ្ជាប់សំណុំឯកសារដូចខាងក្រោម៖

១. យាន្តជំនះដែលជាកម្មសិទ្ធឯកជន

- ✓ ពាក្យសុំចុះបញ្ជីយានជំនិះ
- ✓ អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរ
- ✓ វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ
- ✓ បង្កាន់ដៃពន្ធយានយន្ត
- ✓ វិក្កយបត្រហាងលក់យានយន្ត។

២. យានជំនិះដែលជាកម្មសិទ្ធិក្រុមហ៊ុន

- ✓ ពាក្យសុំចុះបញ្ជីយានជំនិះ
- ✓ អត្តសញ្ញាណប័ណ្ណសញ្ញាតខ្មែរ ឬលក្ខន្តិកៈក្រុមហ៊ុន ឬវិញ្ញាបនបត្របញ្ជីពាណិជ្ជកម្ម
- ✓ វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ
- ✓ បង្កាន់ដៃពន្ធយានយន្ត
- ✓ វិក្កយបត្រហាងលក់យានយន្ត

៣. យានជំនិះដែលជាកម្មសិទ្ធក្រសួងស្ថាប័នរដ្ឋ

- ✓ ពាក្យសុំចុះបញ្ជីយានជំនិះ
- ✓ លិខិតស្នើសុំរបស់ក្រសួងស្ថាប័នសាមី
- ✓ វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ
- ✓ បង្កាន់ដៃពន្ធយានយន្តជាបន្ទុករបស់រដ្ឋ
- ✓ ករណីស្នើរសុំចុះបញ្ជីយានជំនិះ ដែលមានបង្កាន់ដៃពន្ធយានយន្តត្រូវភ្ជាប់ជាមួយនឹងវិក្កយបត្រហាងលលក់យានយន្ត

ក្នុងករណីអាសយដ្ឋានបច្ចុប្បន្នខុសពីអាសយដ្ឋានដែលមាននៅក្នុងអត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរ ត្រូវភ្ជាប់សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ហើយចំពោះជនបរទេសត្រូវភ្ជាប់លិខិតឆ្លងដែន នឹងសៀវភៅស្នាក់នៅ។

៤. យានជំនិះដែលជាកម្មសិទ្ធស្ថានទូត អង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល

- ✓ ពាក្យសុំចុះបញ្ជីយានជំនិះ
- ✓ លិខិតអនុញ្ញាតពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬក្រសួងមហាផ្ទៃ
- ✓ វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណ:បច្ចេកទេសយានជំនិះ
- ✓ បង្កាន់ដៃពន្ធយានយន្តជាបន្ទុករបស់រដ្ឋ។

ករណីស្នើសុំចុះបញ្ជីយានជំនិះ ដែលមានបង្កាន់ដៃពន្ធយានយន្ត ត្រូវភ្ជាប់ជាមួយនឹងវិក្កយបត្រហាងកល់យានយន្ត។

៥. យានជំនិះក្រោមរបបគយនាំចូលបណ្តោះអាសន្ន

- ✓ ពាក្យសុំចុះបញ្ជីយានជំនិះ
- ✓ លិខិតអនុញ្ញាតពីក្រសួងស្ថាប័នសាមី
- ✓ វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណ:បច្ចេកទេសយានជំនិះ
- ✓ បង្កាន់ដៃពន្ធយានយន្តក្រោមរបបគយនាំចូលបណ្តោះអាសន្ន។

### ២.៣.៦. ផ្ទៀងផ្ទាត់ព័ត៌មាន និងឯកសារយោង

រាល់ការបំពេញកិច្ចការទាំងអស់លោកអ្នកគួរគប្បី ធ្វើការពិនិត្យមើលឯកសារនោះឱ្យបានយ៉ាងហោចណាស់បានពីរដងទៅលើ ឯកសាររបស់លោកអ្នកដែលបានបំពេញរួច ដោយហេតុនេះហើយទៅប្រព័ន្ធមួយនេះក៏បានដាក់ជំហានមួយនេះ ដើម្បីឱ្យលោកអ្នកធ្វើការពិនិត្យមើលព័ត៌មានរបស់លោកអ្នកបានបំពេញរួចរាល់ ពិសេសនេះគឺ ព័ត៌មានផ្ទាល់ខ្លួន ឬព័ត៌មានម្ចាស់រថយន្ត ដោយនិយាយឱ្យខ្លី គឺព័ត៌មានសង្ខេបរបស់ម្ចាស់យានយន្ត។

### ២.៣.៧. ជម្រើសបង់ប្រាក់ និងតម្លៃសេវា

ទោះបីជាប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ គឺជាសេវាកម្មសាធារណ:ក៏ពិតមែនតែក៏ត្រូវមានការបង់នូវកម្រៃដើម្បីធ្វើឱ្យសេវានេះអាចធ្វើដំណើរការទៅបានជាបន្ត ហើយកម្រៃដែលទទួលបានពីអ្នកត្រូវការសេវា។ រដ្ឋាភិបាលធ្វើឱ្យការផ្តល់កម្រៃរបស់លោកអ្នកកាន់តែមានភាពងាយស្រួលដល់

ប្រជាពលរដ្ឋ រដ្ឋាភិបាលបានធ្វើការសហការជាមួយ និងដៃគូរឯកជនក្នុងការសម្រួលដល់ដំណើរការនេះរួមមាន៖

1. លី ហួរវេលុយ
2. Wing
3. Smart luy

លោកអ្នកអាចធ្វើការជ្រើសរើសយកនូវសេវាណាមួយក៏បានក្នុងការជ្រើសរើស ដែលលោកអ្នកគិតថាវាមានភាពងាយស្រួលសម្រាប់អ្នក។ លោកអ្នកនិងទទួលបាននៅបង្កាន់ដៃសម្រាប់បង់ប្រាក់ដែលបានចេញដោយក្រសួងសាធារណការនិងដឹកជញ្ជូន។ ក្នុងករណីលោកអ្នកធ្វើការដំណើរការប្រព័ន្ធស្វ័យប្រវត្តិកម្មនោះដោយខ្លួនឯងនោះក្រសួងសាធារណការនិងដឹកជញ្ជូន និងធ្វើការបញ្ជូនបង្កាន់ដៃនោះទៅតាមរយៈអ៊ីម៉ែល (Email) ឬសារអេឡិចត្រូនិច (SMS) ទៅតាមការបំពេញព័ត៌មានពីពេលដំបូងរបស់លោកអ្នកនេះមានន័យថា ការបង្កើតគណនីដោយការប្រើប្រាស់លេខទូរស័ព្ទ នោះក្រសួងនឹងបញ្ជូនបង្កាន់ដៃទៅតាមរយៈសារអេឡិចត្រូនិច (SMS) ហើយបើលោកអ្នកបង្កើតគណនីតាមរយៈអ៊ីម៉ែល (Email) នោះក្រសួងសារធារណការនិងដឹកជញ្ជូន នឹងបញ្ជូនបង្កាន់ដៃទៅតាមរយៈនោះវិញជាមិនខាន។ តម្លៃសេវា និងបង្ហាញនូវក្នុងបង្កាន់ដៃយ៉ាងច្បាស់មានដូចជា

តារាងទី៤ វិកយបត្រសម្រាប់ថ្លៃសេវា

| លេខ | មុខចំណាយ | ស្ថានភាព | ប្រាក់ត្រូវទូរទាត់ |
|---|---|---|---|
| ១ | ផ្លាក់លេខ 2AQ-0004 | មិនទាន់ទូរទាត់ | ៤០០.០០០ រៀល |
| ២ | ផ្លាក់លេខខ្នាត់ | មិនទាន់ទូរទាត់ | ១៨០.០០០ រៀល |
| ៣ | Lexus lx 570 ចុះបញ្ជីយានយន្ត | មិនទាន់ទូរទាត់ | ១២៥.០០០ រៀល |

ដោយយោងទៅតាមប្រការ ១១ នៃប្រកាសស្តីពី បែបបទ និងនីតិវិធីនៃការចុះបញ្ជីយានយន្តការផ្តល់ផ្លាកលេខសម្គាល់យានយន្ត នឹងការលុបចេញពីបញ្ជីយានយន្តបានចែងថា " ការចុះបញ្ជីយានជំនិះត្រូវបង់កម្រៃសេវាសាធារណៈតាមការកំណត់ក្នុងប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

## ៣.៣. យន្តការនៃការត្រួតពិនិត្យទៅលើការអនុវត្ត

លោកទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូនបានចុះទៅពិនិត្យការដាក់ឱ្យដំណើរការប្រព័ន្ធចុះបញ្ជីយានយន្ត តាមប្រព័ន្ធអនឡាញ (Online) នៅក្រុមហ៊ុនហាងជា

(Honda) និងក្រុមហ៊ុនស៊ុយស៊ូគី (Suzuki) ព្រមទាំងបានពិភាក្សាដាក់ចេញនូវវិធានការមួយចំនួនទៀតដើម្បីឱ្យដំណើរការចុះបញ្ជីយានយន្ត នៅតាមក្រុមហ៊ុនទាំងពីរឱ្យកាន់តែល្អប្រសើរថែមទៀត។ ក្នុងនោះលោកទេសរដ្ឋមន្ត្រីបានគូសបញ្ជាក់ថា ក្រសួងសាធារណការ និងដឹកជញ្ជូនកំពុងខិតខំប្រឹងប្រែងយ៉ាងយកចិត្តទុកដាក់ក្នុងការផ្តល់សេវាចាំបាច់ សេវាតម្រូវការ សេវាសាធារណៈឱ្យបានឆាប់រហ័ស មានប្រសិទ្ធភាព និងតម្លាភាពជូនបងប្អូនប្រជាពលរដ្ឋ។ ក្នុងស្មារតីនេះលោកទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** បានស្នើឱ្យគ្រប់សាខាទាំងអស់របស់ក្រុមហ៊ុនហុងដា (Honda) និងក្រុមហ៊ុនស៊ុយស៊ូគី (Suzuki) តភ្ជាប់ប្រព័ន្ធអនឡាញ (Online) ជាមួយក្រសួង ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការចុះបញ្ជីយានយន្តកុំឱ្យមានការកកស្ទះ។ កាលពីថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០១៧ កន្លងទៅនេះ ក្រសួងសាធារណការ និងដឹកជញ្ជូនបានដាក់ឱ្យដំណើរការប្រព័ន្ធស្វ័យប្រវត្តិកម្មអនឡាញ (Online) ចំនួន ៣ ក្នុងការផ្តល់ការសេវាសាធារណៈជូនពលរដ្ឋ ។ សេវាកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្មទាំង ៣ នោះរួមមាន៖ សេវាចុះបញ្ជីយានយន្ត សេវាត្រួតពិនិត្យបច្ចេកទេសយានយន្ត និងសេវាផ្តល់បណ្ណបើកបរយានយន្ត។ ក្រសួងសាធារណការនិងដឹកជញ្ជូនក៏បានសហការជាមួយកន្លែងលក់យានយន្តដាក់ឱ្យប្រើប្រាស់សេវា ចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនេះផងដែរ ពោលកន្លែងលក់យានយន្តអាចចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម និងចេញស្លាកលេខយានយន្តជូនអតិថិជនរបស់ខ្លួនបានផងដែរ។ ក្នុងដំណើរ ការចុះពិនិត្យការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានយន្តនៅក្រុមហ៊ុនហុងដា (Honda) និងស៊ុយស៊ូគី (Suzuki) នោះទាំងខាងក្រុមហ៊ុន និងប្រជាពលរដ្ឋសុទ្ធតែបានបង្ហាញ ភាពរីករាយចំពោះការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មក្នុងការចុះបញ្ជីយានយន្តនេះ។ ប្រជាពលរដ្ឋបានធ្វើការបញ្ជាក់ថា ប្រព័ន្ធថ្មីនេះ បានជួយឱ្យពួកគាត់មានភាពងាយស្រួលក្នុងការចុះបញ្ជីយានយន្ត ក៏ដូចជាទទួលបានស្លាកលេខភ្លាមៗនិងមិនមានភាពស្មុគស្មាញ និងមិនចំណាយច្រើនដូចពីពេលមុនទៀតនោះឡើយ។

សម្រាប់ភាគីក្រុមហ៊ុនវិញក៏បានបញ្ជាក់ថា ការសហការជាមួយក្រសួងសាធារណការនិងដឹកជញ្ជូនក្នុងការដាក់ឱ្យដំណើរការប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ បញ្ចប់ការចុះបញ្ជីយានយន្តតាមអង្គភាពរដ្ឋដោយផ្តល់សិទ្ធិទៅឱ្យម្ចាស់ហាងលក់យានយន្តជាអ្នកចុះបញ្ជី។ យោងតាម សេចក្តីជូនដំណឹងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូនចុះថ្ងៃទី ៧ ខែ មេសា ឆ្នាំ ២០១៧ បានឱ្យដឹងថាក្នុងគោលបំណងបង្ខិតសេវាសាធារណៈឱ្យជិតប្រជាពលរដ្ឋ និងជំរុញនូវការផ្តល់សេវាឱ្យបានរហ័សទាន់ចិត្ត និងមានប្រសិទ្ធភាពខ្ពស់ ក្រសួងសាធារណការ និងដឹកជញ្ជូនបានដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធស្វ័យប្រវត្តិកម្មនៃការចុះបញ្ជីយានយន្តកាលពីថ្ងៃទី ៣០ មេសា ឆ្នាំ ២០១៧ កន្លងមកនេះ។

ទន្ទឹមនឹងនេះដែរ ក្រសួងសាធារណការនិងដឹកជញ្ជូន សូមជម្រាបជូន និងអំពាវនាវដល់សាធារណជន និងម្ចាស់ហាងលក់យានយន្តទាំងអស់ដូចខាងក្រោម៖

1. ដើម្បីបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋ ក្រសួងអនុញ្ញាតឱ្យហាងលក់យានយន្តទាំងអស់មានសិទ្ធិចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីផ្តល់ប័ណ្ណសម្គាល់ និងបំពាក់ស្លាកលេខជូនអតិថិជនរបស់ខ្លួននៅហាងតែម្តង ដោយគ្រាន់តែដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតបំពេញបែបបទចុះបញ្ជីយានយន្តនៅ អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក។

2. ហាងលក់យានយន្តត្រូវ ធានាថាយានយន្តដែលបានលក់ជូនអតិថិជនពីហាងរបស់ខ្លួនត្រូវមានប័ណ្ណសំគាល់ និងបំពាក់ស្លាកលេខដើម្បីអាចធ្វើចរាចរណ៍លើផ្លូវថ្នល់បាន។

3. ចាប់ពីថ្ងៃទី ១ កក្កដា ២០១៧ តទៅហាងលក់យានយន្តទាំងស់ត្រូវមានលិខិតអនុញ្ញាតបំពេញបែបបទចុះបញ្ជីយានយន្ត និងបំពេញកាតាព្វកិច្ចចុះបញ្ជីដើម្បីផ្តល់បណ្ណសម្គាល់ និងស្លាកលេខជូនអតិថិជនរបស់ខ្លួន ក្នុងន័យនេះម្ចាស់ហាងលក់យានយន្តដែលមិនទាន់មានលិខិតអនុញ្ញាតត្រូវរួសរាន់មកដាក់ពាក្យសុំនៅអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោកកុំបីខាន។

4. ម្ចាស់យានយន្តត្រូវស្នើសុំចុះបញ្ជីយានយន្តរបស់ខ្លួននៅហាងលក់យានយន្ត ក្នុងករណីនេះការចុះបញ្ជីយានយន្តនៅមន្ទីសាធារណការ និងដឹកជញ្ជូនរាជធានីខេត្ត ឬទីតាំងផ្តល់សេវាសាធារណដទៃទៀតមិនត្រូវបានអនុញ្ញាតឡើយចាប់ពីថ្ងៃទី ១ កក្កដា ២០១៧ នេះតទៅ។

សេចក្តីជូនដំណឹងនេះមានក្តីសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា ម្ចាស់យានយន្ត និងម្ចាស់ហាងលក់រថយន្តទាំងអស់បានជ្រាបជាព័ត៌មាន និងសហការអនុវត្តន៍តាមការជូនដំណឹងនេះជាក់ជាពុំខាន។ ទោះជាយ៉ាងណាក្តី នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៧ លោក **ស៊ុន ចាន់ថុល** បានដឹកនាំក្រុមមន្ត្រីជំនាញមួយក្រុមរបស់ក្រសួងសាធារណការនិងដឹកជញ្ជូនអញ្ជើញចុះពិនិត្យមើលហាម៉ូតូដើម្បីសង្កេតមើល អំពីរបៀបដំណើរការប្រព័ន្ធអនឡាញ (Online) ក្នុងការចុះបញ្ជីយានយន្ត និងយានជំនិះ និងដើម្បីពិភាក្សាជាមួយម្ចាស់ហាងហុងដា (Honda) និងស៊ុយស៊ូគី (Suzuki) ក្នុងគោលបំណងរិះរកវិធីធ្វើឱ្យប្រព័ន្ធនេះមានភាពប្រសើរឡើង។ លោកទេសរដ្ឋមន្ត្រីបានបញ្ជាក់ជូនអតិថិជនដែលកំពុងទិញម៉ូតូនៅហាងម៉ូតូហុងដា (Honda) និងស៊ូស៊ូគី (Suzuki) ថាបណ្ណសម្គាល់យានយន្តថ្មីដែលបានដាក់ឱ្យដំណើរការនេះមានគុណភាពល្អ ស្វិត មិនងាយរហែក មិនជ្រាបទឹក និងមានលក្ខណៈ

ពិសេសចាំបាច់ដែលមិនធ្លាប់មានពីមុនកមគឺឃ្យូងកូត (QR Code) ដែលមិនអាចធ្វើការក្លែងបន្លំនូវព័ត៌មានបានឡើយ។

### ៣.៣.១. ប្រសិទ្ធភាពនៃការចុះបញ្ជី

យោងតាមមន្ត្រីជំនាញនៃ ក្រសួងសាធារណការនិងដឹកជញ្ជូនបានឱ្យដឹងថារហូតមកដល់ពេលនេះប្រជាពលរដ្ឋទូទាំងប្រទេសបានយកយានយន្តរបស់ខ្លួនទៅ ចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្មត្រួតពិនិត្យលក្ខណៈបច្ចេកទេសមានប្រមាណជាង ៥០ម៉ឺន គ្រឿងហើយ។ **លោក ជា សុជាតិ** ប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោក បន្ទាប់ពីបន្ទាប់ពីបញ្ចប់បទបង្ហាញ និងតាំងបង្ហាញសេវាសាធារណៈរបស់ខ្លួនដែលមានទម្រង់ជាប្រព័ន្ធអនឡាញថ្មី នៅថ្ងៃទី ២៣ កុម្ភៈ ២០១៨ នៅមជ្ឈមណ្ឌលសហប្រតិបត្តការកម្ពុជាជប៉ុន (CJCC) បានឱ្យដឹងថា ក្រសួងសាធារណការនិងដឹកជញ្ជូនបានចាប់ផ្តើមចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ពីថ្ងៃទី ៣០ មករា ឆ្នាំ ២០១៧ រហូតមកដល់ពេលនេះបានជាង ៥០ ម៉ឺនគ្រឿងហើយ។ ទោចក្រយានយន្តមានភាគច្រើន ចំពោះឡានតូច ឡាយធំ មានមួយចំនួនដែលនៅតិចជាងទោលចក្រយានយន្ត។ លោកបានឱ្យដឹងទៀតថានាយកដ្ឋានដឹកជញ្ជូនផ្លូវគោកបានសម្រេចធ្វើយ៉ាងណាឱ្យពលរដ្ឋមានការយល់ដឹងកាន់តែច្បាស់ចំពោះបញ្ហាចុះបញ្ជីប្រព័ន្ធស្វ័យប្រវត្តិកម្ម។ ព្រះរាជាណាចក្រកម្ពុជាជាប្រទេសទី១ដែលបានប្រើប្រាស់ឃ្យូអកូត (RQ Code) បំពាក់លើផ្លាកយានយន្តមុនគេ។ជាពិសេសឃ្យូអកូត (RQ Code) មានសារសំខាន់យ៉ាងខ្លាំងចំពោះការពារយានយន្តក្លែងក្លាយ។

**លោក ជា សុជាតិ** បានបញ្ជាក់ថា ចំពោះបញ្ហាក្លែងក្លាយយានយន្តបណ្តាលឱ្យរាជរដ្ឋាភិបាលបាត់បង់ចំណូលពន្ធ និងបញ្ហាសន្តិសុខជាដើម។ ពលរដ្ឋដែលមានអាសយដ្ឋាននៅរាជធានីភ្នំពេញត្រូវធ្វើផ្លាកលេខនៅរាជធានីភ្នំពេញ ពលរដ្ឋមានអាសយដ្ឋាននៅតាមបណ្តាខេត្តត្រូវធ្វើស្លាកលេខនៅតាមខេត្ត ដើម្បីងាយស្រួលក្រែងមានបញ្ហាអ្វីដែលអាចកើតឡើងបាន។ គួរបញ្ជាក់ ថាប្រព័ន្ធស្វ័យប្រវត្តិកម្មជាមធ្យោបាយធ្វើទំនើបកម្មសេវាកម្មសម្រាប់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងការដឹកជញ្ជូនកម្ពុជាអាចជួយសម្រួលដល់ការចុះបញ្ជីយានយន្តរបស់ពលរដ្ឋ ការផ្តល់បណ្ណបើកបរ ការប្រឡងទ្រឹស្តីបើកបរ ការចុះបញ្ជីយានយន្ត និងការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តបាន ឆាប់រហ័ស កាត់បន្ថយភាពស្មុគស្មាញនិងអនុញ្ញាតឱ្យទូទាត់ប្រាក់កម្រៃសេវាតាមអនឡាញ (Online) ប្រកបដោយតម្លាភាព។

### ៣.៣.២. កម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋ

ដោយយោងទៅតាមការឆ្លើយនឹងសំនួររបស់លោក បណ្ឌិត **មាស នី** ប្រជាពលរដ្ឋប្រហែលជា១៥ទៅ២០ភាគរយតែប៉ុណ្ណោះដែលអាចមានលទ្ធភាពឈានទៅការប្រើប្រាស់កុំព្យូទ័រ (Computer) បាន។ ដូច្នេះមួយចំនួនធំនៃប្រជាជនយើង គឺទំនងជាពុំទាន់អាចឈានទៅទទួលបានផលប្រយោជន៍ពី E-government នៅឡើយទេ។ ដោយតាមបទពិសោធន៍បង្រៀននៅតាមសកលវិទ្យាល័យជាច្រើនឆ្នាំលោកបានបញ្ជាក់ថា ចំពោះនិស្សិតនៅតាមសាកលវិទ្យាល័យរហូតមកដល់ពេលនេះ យើងអាចវាយតម្លៃបានថា ពួកគាត់ប្រមានជា ៧០ ទៅ ៨០ ភាគរយអាចប្រើប្រាស់កុំព្យូទ័រ (Computer) សម្រាប់ជួយដល់ការសិក្សារបស់ពួកគេបាននោះ ប៉ុន្តែពួកគាត់ក៏នៅមានកម្រិតក្នុងការស្រាវជ្រាវទិន្នន័យឱ្យបានច្បាស់លាស់ដែរ។[5] ផ្អែកទៅលើការប្រសាសន៍នេះអាចបង្ហាញឱ្យយើងបានដឹងមួយចំណុចថា ការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ (Online) វាពិតជាមានការលំបាកណាស់សម្រាប់ប្រជាពលរដ្ឋធម្មតានោះពីព្រោះថាប្រជាពលរដ្ឋដែលអាចអនុវត្តគម្រោងនេះវាមានតិចជាងចំនួននៃការកើនឡើងរបស់យានយន្ត។

### ៣.៣.៣. ការចូលរួមរបស់ដៃគូរអភិវឌ្ឍ

ប្រជាពលរដ្ឋរបស់យើងនៅមានកម្រិតនៅក្នុងការប្រើប្រាស់បច្ចេកវិទ្យា ហេតុនេះហើយដើម្បីសម្រួលដល់ប្រជាពលរដ្ឋក្រសួងសាធារណការនិងដឹកជញ្ជូន បានអនុញ្ញាតឱ្យដៃគូរឯកជនមកធ្វើការចូលរួមជាដៃគូរសហការជាមួយ វិស័យសាធារណៈក្នុងការអនុវត្តគម្រោងមួយនេះឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលទៅតាមការរំពឹងទុករបស់ខ្លួន។ ក្រសួងសាធារណកានិងដឹកជញ្ជូនបានធ្វើការកំណត់នៅការចូលរួមរបស់ដៃគូរឯកជននៅក្នុងប្រការ ១០ នៃប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីយានយន្ត ការផ្តល់ផ្លាកលេខសម្គាល់យានយន្ត និងការលុបចេញពីបញ្ជីយានយន្តបានកំណត់ដូចខាងក្រោម៖

ក្រសួងសាធារណការនិងដឹកជញ្ជូន អនុញ្ញាតឱ្យម្ចាស់ហាងលក់យានយន្ត បំពេញបែបបទចុះបញ្ជីយានជំនិះឱ្យបានចប់សព្វគ្រប់មុននឹងប្រគលឱ្យអ្នកទិញ។ ម្ចាស់ហាងលក់យានយន្ត ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតបំពេញបែបបទ ចុះបញ្ជីយានជំនិះតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម (Online) ផ្តល់លិខិតអនុញ្ញាតបំពេញបែបបទ ចុះបញ្ជីយានជំនិះទៅទីតាំងផ្តល់សេវាសាធារណៈ

[5] សិក្ខាសាលាអំពីរដ្ឋាភិបាល អេឡិចត្រូនិកថ្ងៃ សុក្រ ទី ០៦ ខែ មិថុនា ឆ្នាំ ២០១៤

ដែលកំណត់ដោយក្រសួងសាធារណការនិងដឹកជញ្ជូន ដោយត្រូវភ្ជាប់សំណុំឯកសារដូចខាងក្រោម៖

- ✓ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- ✓ វិញ្ញាប័ណ្ណបត្របុះបញ្ជីពាណិជ្ជកម្ម
- ✓ បណ្ណប៉ាតង់។

ក្នុងករណីអាសយដ្ឋានបច្ចុប្បន្ន ខុសពីអាសយដ្ឋាននៅក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ត្រូវភ្ជាប់សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ហើយចំពោះជនបរទេស ត្រូវភ្ជាប់លិខិតឆ្លងដែន និងសៀវភៅស្នាក់នៅ ៖

- ✓ វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម អស់សុពលភាព
- ✓ ប្តូរអាសដ្ឋានហាងលក់យានយន្ត
- ✓ មិនគោរពតាមច្បាប់ជាធរមាន។

ទម្រង់ពាក្យសុំលិខិតអនុញ្ញាតបំពេញបែបបទចុះបញ្ជីយានជំនិះ និងលិខិតអនុញ្ញាតបំពេញបែបបទចុះបញ្ជីយានជំនិះមានចែងនៅក្នុងឧបសម្ព័ន្ធទី៦ នៃប្រកាសនេះ។ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) នៅកម្ពុជា និងក្រសួងសាធារណការ និងដឹកជញ្ជូនបានរៀបចំសន្និសិទសារព័ត៌មាន អំពីគម្រោងរៀបចំប្រព័ន្ធចុះបញ្ជីយាយន្ត និងត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តនៅកម្ពុជា ជាគម្រោងដែលមានរយៈពេល៣ឆ្នាំទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) បានត្រៀមកញ្ចប់ថវិការជិត ៩០០.០០០.០ ក្នុងទិសដៅធ្វើឱ្យប្រសើរឡើងការចុះបញ្ជីយានយន្ត ការត្រួតពិនិត្យលក្ខណៈបច្ចេកទេស និងប្រព័ន្ធព័ត៌មានវិទ្យានៅកម្ពុជា។ នៅក្នុងសន្និសិទសារព័ត៌មានស្តីពី សកម្មភាពរបស់អង្គការ JICA គម្រោងទំនើបកម្មប្រព័ន្ធចុះបញ្ជីយានយន្ត និងត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តនេះគឺដើម្បីធានាបាននូវគុណតម្លៃចលនទ្រព្យយានយន្ត និងរក្សានូវសុវត្ថិភាពចរាចរណ៍នៅកម្ពុជា។ ចំណែក **លោក តាណាកា ក្វូតារ៉ូ** អនុប្រធានតំណាងការិយាល័យទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) វិញបានកត់សម្គាល់ថា ខណៈចំនួនយានយន្តនៅកម្ពុជាមានកើនឡើង ករណីនៃគ្រោះថ្នាក់ចរាចរណ៍ក៏កើនឡើងដូចគ្នា។ បន្ថែម ពីការលើកឡើងរបស់តំណាងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) លោក **តូច ចាន់កុសល** រដ្ឋលេខាធិការ ក្រសួងសាធារណការនិងដឹកជញ្ជូន បានទទួលស្គាល់ថា ប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីរថយន្ត និងត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តនៅមិនទាន់ មានលក្ខណៈគ្រប់គ្រាន់នៅឡើយដែលជាហេតុបង្កឱ្យមានបញ្ហាទាក់ទង និងសុវត្ថិភាពចរាចរណ៍ និងបរិស្ថាន។ មន្ត្រីជំនាញនៃក្រសួងសាធារណការនិងដឹកជញ្ជូនបានឱ្យដឹងថា បច្ចុប្បន្ននេះការចុះបញ្ជីយានយន្តនៅកម្ពុជានៅ

មានបញ្ហាប្រឈមមួយចំនួនដូចជា៖ ព័ត៌មានចុះបញ្ជីកន្លងមកមិនធ្វើបច្ចុប្បន្នកម្ម ប្រព័ន្ធប្រតិបត្តិការដែលមានសុវត្ថិភាពសម្រាប់ចុះបញ្ជីមិនត្រូវបានអនុវត្តន៍ចំណែកព័ត៌មាន ចុះបញ្ជីមិនត្រូវបានប្រើប្រាស់សម្រាប់ក្រសួងពាក់ព័ន្ធហើយទ្រព្យសម្បត្តិម្ចាស់យានយន្តក៏មិនត្រូវបានការពារដែរ។

យ៉ាងណាក៏ដោយ លោក **តូច ចាន់កុសល** ជឿជាក់ថាតាមរយៈដែលមានការគាំទ្រដោយរដ្ឋាភិបាលជប៉ុនដែលមានរយៈពេល ៣ ឆ្នាំ ២០១៦-២០១៩ នេះនឹងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីយានយន្ត ការត្រួតពិនិត្យលក្ខណៈ បច្ចេកទេសយានយន្ត និងប្រព័ន្ធស្វ័យប្រវត្តិកម្មនៅកម្ពុជា ជាក់ជាមិនខាន។ ក្រសួងសាធារណការនិងដឹកជញ្ជូន និងភាគីជប៉ុនរំពឹងទុកទៀតថា តាមរយៈគម្រោងទំនើបកម្មប្រព័ន្ធចុះបញ្ជីយានយន្ត និងត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តនៅកម្ពុជា ក៏នឹងជួយជម្រុញអគ្គនាយកដ្ឋានពន្ធដារអាចប្រមូលពន្ធផ្លូវមានប្រសិទ្ធិភាពផងដែរ។

## ៣.៤. យន្តការក្នុងការលើកទឹកចិត្តដៃគូរអភិវឌ្ឍ

ដើម្បីបង្កភាពងាយស្រួលដល់ពលរដ្ឋ ក្រសួងសាធារណការ និងដឹកជញ្ជូនបានអនុញ្ញាតឱ្យហាងលក់យានយន្តទាំងអស់ មានសិទ្ធិចុះបញ្ជីយានយន្តតាមប្រព័ន្ធអនឡាញ (Online) ដើម្បីផ្តល់បណ្ណ័សម្គាល់ និងបំពាក់ស្លាក់លេខជូនអតិថិជនរបស់ខ្លួននៅហាងតែម្តង។ បើតាមសេចក្តីជូនដំណឹងរបស់ក្រសួងសាធារណការ ហាងនីមួយៗត្រូវមានលិខិតអនុញ្ញាតបំពេញបែបបទ ចុះបញ្ជីយានយន្តនៅអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ចាប់ពីថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០១៧ ហើយត្រូវធានាថា យានយន្តដែលបានលក់ជូនអតិថិជនពីហាងរបស់ខ្លួនត្រូវមានបណ្ណ័សម្គាល់ និងបំពាក់ស្លាកលេខ ដើម្បីអាចធ្វើចរាចរណ៍លើផ្លូវថ្នល់បាន។ សេចក្តីជូនដំណឹងដដែលបានបន្តថា ម្ចាស់យានយន្តត្រូវស្នើសុំចុះបញ្ជីយានយន្តរបស់ខ្លួននៅហាងលក់យានយន្ត។ ក្រសួងសាធារណការនិងដឹកជញ្ជូនបានបញ្ជាក់ដូច្នេះថា ការចុះបញ្ជីយានយន្តនៅ មន្ទីរសាធារណការខេត្ត ឬ ទីតាំងផ្តល់សេវាសាធារណៈដទៃទៀតមិនត្រូវបានអនុញ្ញាតឡើយ ចាប់ពីថ្ងៃ ទី១ កក្កដា ២០១៧។ កាលពីថ្ងៃទី ៥ ខែមេសា ឆ្នាំ ២០១៧ ក្រសួងបានចេញសេចក្តីណែនាំមួយ ដើម្បីបញ្ជាក់ពីការចុះបញ្ជីទោចក្រយានយន្ត (ម៉ូតូ) នៅមន្ទីរសាធារណការ ខេត្ត ដោយប្រគល់សិទ្ធិ នេះទៅការិយាល័យច្រកចេញចូលតែមួយរបស់រដ្ឋបាលខណ្ឌនៃរាជធានី និងខេត្ត អនុវត្តន៍សាកល្បងមុខងារចុះបញ្ជីតាមអនឡាញ (Online) នេះ។ ចំពោះការិយាល័យច្រកចេញចូលនៅតាមរាជធានីខេត្តណាដែលមិនទាន់ត្រៀមលក្ខណៈរួចរាល់មន្ទីរសាធារណការនៅតែបន្តផ្តល់សេវាចុះបញ្ជីទោចក្រយានយន្តដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

លោក **ពៅ ម៉ាលី** អគ្គនាយកដ្ឋានដឹកជញ្ជូននៃក្រសួងសាធារណការនិងដឹកជញ្ជូនបានប្រាប់សារព័ត៌មានថ្មីៗថា ការចុះបញ្ជីទាំងរថយន្ត និងម៉ូតូ អាចធ្វើបាននៅហាងលក់យានយន្ត ប៉ុន្តែករណីមួយទៀតនោះគឺម្ចាស់ម៉ូតូក៏អាចសុំចុះបញ្ជីនៅការិយាល័យច្រកចេញចូលតែមួយបានដែរ។

### ៣.៥. គុណសម្បត្តិ និងគុណវិបត្តិ

### គុណសម្បត្តិ

- ការចុះបញ្ជីយានយន្ត ធ្វើឱ្យមានភាពត្រឹមត្រូវលើព័ត៌មានចុះបញ្ជីយានយន្ត គឺយុទ្ធនាការកែតម្រូវព័ត៌មានយានយន្តដែលបានចុះបញ្ជីរួច ប្រព័ន្ធលុបពត៌មានយានយន្តចេញពីបញ្ជី និង ណែនាំពីប្រកាសគោលការណ៍ណែនាំ និងតារាងត្រួតពិនិត្យ ។ល។
- ជៀសវាងការលក់រថយន្តបន្តមុនពេលបញ្ចប់កិច្ចសន្យាបង់ប្រាក់កម្ចីទិញយានយន្តគឺបញ្ចូលបន្ថែមនូវព័ត៌មានកម្ចី និងឈ្មោះអ្នកប្រើប្រាស់ចូលក្នុងប្រព័ន្ធចុះបញ្ជីយានយន្ត ។
- ការត្រួតពិនិត្យលក្ខណៈបច្ចេកទេស ពោលគឺកំណត់ស្តង់ដារបច្ចេកទេសទៅលើឧបករណ៍ត្រួតពិនិត្យលក្ខណៈបច្ចេកទេស និងលក្ខណៈស្តង់ដារសម្រាប់អ្នកត្រួតពិនិត្យបច្ចេកទេស ណែនាំអំពីប្រព័ន្ធគ្រប់គ្រងឧបករណ៍ត្រួតពិនិត្យលក្ខណៈបច្ចេកទេស ណែនាំអំពីប្រកាស គោលការណ៍ណែនាំ និង តារាងត្រួតពិនិត្យ ។ល។ ណែនាំអំពីតារាងត្រួតពិនិត្យ សម្រាប់ឧបករណ៍ត្រួតពិនិត្យលក្ខណៈបច្ចេកទេសដែលមានអទិភាព។[6]
- ការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ បានជួយសម្រួលដល់ការប្រមូលពន្ធលើការប្រើប្រាស់យានយន្តមានភាពងាយស្រួល ព្រមទាំងអាចធ្វើចរាចរណ៍បាននៅក្នុងបណ្តាលប្រទេសដែលជាសមាជិកអាស៊ានថែមទៀតផង។
- ធ្វើឱ្យប្រជាពលរដ្ឋធម្មតាអាចធ្វើការចុះបញ្ជីយានយន្តបានដោយខ្លួនឯងផ្ទាល់ ដោយគ្រាន់តែពួកគាត់ចេះប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា
- ម្ចាស់យានយន្តដែលមានបំណងទិញផ្លាកលេខថ្មី អាចធ្វើការជ្រើសរើសផ្លាកលេខដែលខ្លួនស្រឡាញ់បានដោយងាយស្រួល និងកំណត់ពីទំហំនៃផ្លាកលេខបានដោយខ្លួនឯងថែមទៀត

[6] http://www.cen.com.kh/archives/22543.html

- ដោយសារតែមានការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនេះបានធ្វើឱ្យម្ចាស់យានយន្តទាំងអស់មានភាពងាយស្រួលក្នុងត្រួតពិនិត្យបច្ចេកទេសបានឆាប់ជាងមុន
- ម្ចាស់យានយន្តទាំងអស់នឹងទទួលបានផ្លាកលេខភ្លាមៗនៅពេលដល់ថ្ងៃដែលបានកំណត់ការបរិច្ឆេតទៅទទួល

**គុណវិបត្តិ**

- ធ្វើឱ្យមានការលំបាកចំពោះម្ចាស់យានយន្តមួយចំនួនដែលពួកគាត់នៅមានភាពអក្ខរកម្ម
- ទោះបីជាមានការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម (Online) នេះក៏ពិតមែនតែម្ចាស់យានយន្តភាគច្រើនមិនបានដឹងពីសារៈសំខាន់នៃឃ្លអក្វត) QR code( នោះទេ
- មិនទាន់ឃើញមានការធ្វើបទបង្ហាញ ឬការធ្វើអ្វីមួយដើម្បីឱ្យប្រជាពលរដ្ឋនៅជនបទបានដឹងពីសារៈសំខាន់នៃឃ្លអក្វត (QR code)
- រាជរដ្ឋាភិបាលត្រូវធ្វើការចំណាយថវិការដ្ឋច្រើនទៅលើការគ្រប់គ្រងនៃដំណើរការនៃប្រព័ន្ធចុះបញ្ជីយានយន្តនេះ ដូចជាការបង្កើតនូវមជ្ឈមណ្ឌលត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តជាដើម។
- កង្វះខាតធនធានមនុស្សផ្នែកព័ត៌មានវិទ្យា (IT) ច្រើនដើម្បីគ្រប់គ្រងដំណើរការនៃប្រព័ន្ធចុះបញ្ជីយានយន្តឱ្យប្រព្រឹត្តទៅបានរលូន។
- មានការលំបាកចំពោះប្រជាពលរដ្ឋនៅតាមទីជនបទមួយចំនួនដែលពួកគាត់ពុំមានការប្រើប្រាស់ទូរស័ព្ទស្មាតហ្វូន (Smart Phone) ប្រើប្រាស់ដើម្បីចូលទៅក្នុងកម្មវិធីដោយផ្ទាល់បាន និងកង្វះព័ត៌មានក៏ដូចជាការយល់ដឹងពីការប្រើប្រាស់ប្រព័ន្ធនេះនៅឡើយ។

# ជំពូកទី ៤
# ពិភាក្សាបញ្ហា និងដំណោះស្រាយ

## ៤.១. បញ្ហាប្រឈម

ប្រធានទីប្រឹក្សាទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) លោក អូតា ម៉ាសាយ៉ា លើកឡើងថា ទន្ទឹមនិងចំនួនរថយន្តមានការកើនឡើងប្រទេសកម្ពុជា នៅមិនទាន់មានប្រព័ន្ធត្រួតពិនិត្យលក្ខណៈបច្ចេកទេសត្រឹមត្រូវនៅឡើយទេ។ លោកបន្តថា ក្រោយមានការស្នើសុំពីរាជរដ្ឋាភិបាលកម្ពុជាទីភ្នាក់ងារJICA បានចាប់ផ្តើមសិក្សាស្រាវជ្រាវទៅលើបញ្ហានេះកាលពីឆ្នាំ ២០១២ និងបានបង្កើតគម្រោងមួយឈ្មោះថា គម្រោងទំនើបកម្មប្រព័ន្ធចុះបញ្ជី និងត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត។ ក្នុងសន្និសិទសារព័ត៌មានលើសកម្មភាពរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ទាក់ទងអំពីគម្រោងនេះកាលពីចុងខែ មករា ឆ្នាំ ២០១៨ **លោក អូតា ម៉ា សាយ៉ា** លើកឡើងអំពីបញ្ហាធំៗ ៣ ដែលប្រទេសកម្ពុជាយើងកំពុងជួបប្រទះទាក់ទង និងប្រព័ន្ធចុះបញ្ជីយានយន្ត និងត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តនេះថា៖

**ទី ១ គឺ** ប្រព័ន្ធចុះបញ្ជីយានយន្ត ដោយយានយន្តដែលមិនបានចុះបញ្ជី គឺនៅចរាចរនៅលើដងផ្លូវនៅឡើយ។ ការផ្ទេរកម្មសិទ្ធិយានយន្តនិងការចុះបញ្ជីមិនត្រូវបានធ្វើឡើងទេ។ រដ្ឋាភិបាលមិនមានលទ្ធភាពគ្រប់គ្រងព័ត៌មានចុះបញ្ជីយានយន្ត។

**ទី ២ គឺ** ប្រព័ន្ធ IT សម្រាប់ការចុះបញ្ជី និងត្រួតពិន្យិតលក្ខណៈបច្ចេកទេសយានយន្តមានលក្ខណៈចាស់ណាស់ ហើយដោយសារតែមិនទាន់បានធ្វើបច្ចុប្បន្នភាពរយៈពេលជាង ១០ ឆ្នាំមកហើយ។ ការធ្វើបច្ចុប្បន្នភាពទៅលើការចុះបញ្ជីយានយន្តមិនទាន់បានធ្វើនៅឡើយ។

**ទី ៣ គឺ** ប្រព័ន្ធត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តមិនទាន់មានការគ្រប់គ្រាន់នៅឡើយចំណែកគុណភាពនៃការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តគឺ នៅមានកម្រិតទាបមិនមានបទដ្ឋានត្រឹមត្រូវសម្រាប់ផ្ទៀងផ្ទាត់ និងត្រួតពិនិត្យជាប្រចាំលើឧបករណ៍ត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត។ ជាងនេះទៅទៀតនោះគឺ មានបញ្ហាមួយដែលមិនទាន់មានការសហការដើម្បីតភ្ជាប់ប្រព័ន្ធ IT សម្រាប់ព័ត៌មានចុះបញ្ជី និងត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត។

## ៤.២. ដំណោះស្រាយ

**ទី ១** ការចុះបញ្ជីយាយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម (Online) នេះស្ថិតនៅក្នុងកម្រិតមួយត្រូវការការផ្សព្វផ្សាយឱ្យបានច្រើនជាងពេលបច្ចុប្បន្ននេះទៅទៀត ដូចនេះត្រូវតែទៅធ្វើការផ្សព្វផ្សាយនៅតាមជនបទឱ្យបានដឹងអំពីប្រព័ន្ធនៃការចុះបញ្ជីនេះឱ្យដូចជាអ្នកនូវទីក្រុង ឬទីប្រជុំ

ជនដែរ។ គួរគប្បីធ្វើការផ្សព្វផ្សាយនៅតាមទីសាធារៈអំពី ប្រព័ន្ធចុះបញ្ជីយានយន្តដោយអាចដាក់បង្ហាញនូវតាមផ្ទាំងប៉ាណូធំៗតាមដងផ្លូវទាំងនៅទីក្រុង និងទីប្រជុំជននៅតាមជនបទផង។ ចំពោះយានយន្តដែលមិនបានចុះបញ្ជីដែលនៅមានការធ្វើចរាចរណ៍នៅលើដងផ្លូវត្រូវតែធ្វើ ការត្រួតពិនិត្យឱ្យបានតឹងរឹងជាងពេលបច្ចុប្បន្ននេះបន្ថែមទៀត។ ដើម្បីធ្វើឱ្យការបញ្ឈប់យានយន្តដែលមិនទាន់ចុះបញ្ជីនេះមានដំណោះស្រាយមួយចំនួនដូចខាងក្រោម៖

- ➢ រដ្ឋមន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូន គួរតែចេញបទបញ្ជាដើម្បីអនុវត្តន៍បេសកកម្ម ក្នុងការចុះបញ្ជីយានយន្តទាំងឡាយមិនបានចុះបញ្ជីឱ្យបានតឹងរឹងនៅក្នុងរយៈពេលកំណត់ជាក់លាក់មួយ
- ➢ ក្នុងដំណើរការលក់យានយន្ត ពីម្ចាស់ម្នាក់ទៅម្ចាស់យានយន្តថ្មីម្នាក់ទៀតត្រូវតែធ្វើការកាត់ឈ្មោះពីម្ចាស់កម្មសិទ្ធិដើមទៅឱ្យម្ចាស់កម្មសិទ្ធិបន្ទាប់បានឆាប់បំផុត តាមដែរអាចធ្វើបាន។ ឧទាហរណ៍ លោក A ជាម្ចាស់យានយន្តចាស់ត្រូវបានលុបឈ្មោះចេញពីបញ្ជី ហើយជំនួយមកវិញនូវម្ចាស់យានយន្តថ្មី
- ➢ រាជរដ្ឋាភិបាលគួរតែជំរុញការអភិវឌ្ឍ សមត្ថភាពរបស់មន្ត្រីរាជការដែលទទួលបន្ទុកផ្នែកចុះបញ្ជីយាយន្តឱ្យកាន់តែទូលំទូលាយ ស្របទៅតាមតម្រូវការវិត្តនៃប្រព័ន្ធព័ត៌មានវិទ្យា និងតម្រូវការ

**ទី ២** រដ្ឋាភិបាលគួរតែជំរុញការអភិវឌ្ឍន៍នូវ ប្រព័ន្ធចុះបញ្ជីយានយន្តឱ្យកាន់តែមានលក្ខណៈល្អប្រសើរស្របទៅតាមភាពជឿនលឿន ក៏ដូចជាតម្រូវការនៃការចុះបញ្ជីតាមរយៈការសហការជាមួយដៃគូរអភិវឌ្ឍន៍ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ដែលជាអង្គការមានបច្ចេកទេសជឿនលឿននៅក្នុងការដាក់ឱ្យដំណើរការប្រព័ន្ធបច្ចេកវិទ្យា

**ទី ៣** ធ្វើការពង្រីកទីតាំងត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តឱ្យបានទូលំទូលាយគ្រប់ដណ្តប់ទូទាំង ២៥ រាជធានី ខេត្ត ក្រុងដើម្បីជុំរុញឱ្យការចុះបញ្ជីយានយន្តកាន់តែមានភាពឆាប់រហ័ស ដោយឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងខេត្តនីមួយៗ។ ជាងនេះទៅទៀត ត្រូវធ្វើការពង្រីកការតភ្ជាប់ប្រព័ន្ធព័ត៌មានវិទ្យា (IT) សម្រាប់ចុះបញ្ជីបានគ្រប់មន្ទីរទាំងអស់ដែលនៅតាមបណ្តាលខេត្តនានា។

# សេចក្តីសន្និដ្ឋាន

លទ្ធផលដែលទទួលបានតាមរយៈ ការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មនៃការចុះបញ្ជីយានយន្តនេះគឺ ពិតជាបានធ្វើឱ្យមានភាពងាយស្រួលដល់អ្នកទិញរថយន្តពិតប្រាកដមែន បើទោះបីជា ការរចុះបញ្ជីនោះភាគច្រើនធ្វើឡើងដោយហាងលក់រថយន្តក៏ដោយ វាក៏បានធ្វើឱ្យប្រព័ន្ធនេះដំណើរការបានល្អជាងមុនពេល។ តាមរយៈការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម (Online) នេះបានធ្វើឱ្យប្រជាពលរដ្ឋដែលមានលទ្ធភាពទិញរថយន្តទទួលបានផ្លាកលេខភ្លាមៗ ដោយមិនចាំបាច់ចំណាយពេលវេលាច្រើនដូចពីមុន ក៏ដូចជា បានធ្វើការកាត់បន្ថយការចំណាយក្រៅផ្លូវការជាច្រើន និងបានធ្វើឱ្យការប្រមូលពន្ធលើការប្រើប្រាស់រថយន្ត ក៏មានភាពងាយស្រួលដោយសារតែនៅលើផ្លាកលេខថ្មីនោះគឺ មានភ្ជាប់នូវប្រព័ន្ធបច្ចេកវិទ្យាមួយដែលមានឈ្មោះថាឃ្យូអកូត (QR code) ដែលអាចបង្ហាញអំពីព័ត៌មានរថយន្តបានយ៉ាងច្បាស់ និងការពារការក្លែនបន្លំបានថែមទៀតផង។ តាមការសង្កេតមើលអំពីដំណើរការចុះបញ្ជីនេះរួចមកយើងមកមើលលើ លទ្ធផលនៃការចុះបញ្ជីយានយន្តតាមប្រព័ន្ធនេះដោយធ្វើការប្រៀបធៀបជាមួយ នឹងយានយន្តដែលបាននាំចូលលើទីផ្សារយើងសព្វថ្ងៃនេះដោយគិតចាប់ពីឆ្នាំ ១៩៩០ ដល់ឆ្នាំ ២០១៦ យានយន្តបានចុះបញ្ជីសរុបចំនួន ៣.៦៦៨.៨២០ គ្រឿង ( ម៉ូតូ ៣.១៣២.៣៦១ គ្រឿង និងរថយន្ត ៥៣៧.៤៥៩ គ្រឿង)។ ដោយឡែកការចុះបញ្ជីយានយន្តក្នុងឆ្នាំ ២០១៦ មានចំនួន ៤៥៩.៥៩៧ គ្រឿង ក្នុងនោះមានម៉ូតូចំនួន ៤០៦.២៤៨ គ្រឿង កើនឡើង ១៨.៧៦% និងរថយន្តគ្រប់ប្រភេទ ៥៣.៣៤៩ គ្រឿង ថយចុះ ៦.៥៥% ធៀបនឹងឆ្នាំ ២០១៥។ ចំនួនយានយន្តដែលបានចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនៅពេលបច្ចុប្បន្ននេះ គិតត្រឹមថ្ងៃដាក់ឱ្យដំណើរការរហូតថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០១៨ មានចំនួន៥៦៤ គ្រឿងនេះជាចំនួនយានយន្តដែលធៀបនឹងចំនួនយានយន្តតាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្មមានដំណើរការបានល្អជាងមុនបានដូងនឹងគោលបំណងរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន។

នេះជាភាពជោគជ័យរបស់ក្រសួងក្រោមការដឹកនាំរបស់លោកទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** ក្នុងការផ្តល់សេវាតាមរយៈបច្ចេកវិទ្យា ICT ដែលជាផ្នែកមួយដែលស្ថិតនៅគម្រោងររបស់ការគ្រប់គ្រងតាមបែប រដ្ឋាភិបាលអេឡិចត្រូនិក (E-government) ដូចទៅ នឹងក្រសួងពាណិជ្ជកម្មដែលបានអនុវត្តន៍មុនគេនៅក្នុងប្រទេសកម្ពុជាយើង។

ចំនុចមួយដែលគួរឱ្យកត់សម្គាល់ នៅក្នុងដំណើរការនៃការចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម(Online) នេះគឺ ពុំសូវមានអតិថជន ឬ ម្ចាស់រថយន្តធ្វើការអនុវត្តន៍វាដោយខ្លួនឯងផ្ទាល់នៅឡើយ ចំណុចនេះហើយដែលឱ្យការអនុវត្តន៍ប្រព័ន្ធនេះនូវតែមានប្រពលរដ្ឋ ឬម្ចាស់រថយន្ត

ជាច្រើនមិនបានដឹងពីសារៈប្រយោជន៍មួយនេះ។ ប្រសិនបើ ការចុះបញ្ជីនៅតែប្រគល់ទៅឱ្យហាងលក់ជាអ្នកចុះបញ្ជីជំនួសម្ចាស់យានយន្តលើការបំពេញពាក្យតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម (Online) ។

# អនុសាសន៍

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវយ៉ាងលម្អិតទៅលើការចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម (Online) រួចមកយើងកត់សម្គាល់ឃើញថា ការប្រើប្រាស់ប្រព័ន្ធនេះពិតជាបានផ្តល់នូវសារៈសំខាន់យ៉ាងច្រើនទៅដល់ភាគីទាំងពីរពោលគឺភាគីរដ្ឋ និងភាគីឯកជនទាំងថវិកានិងពេលវេលា។ ដោយផ្អែកទៅលើសារៈប្រយោជន៍ដ៏លើសលប់ដូចដែលបានរៀបរាប់កន្លងមក យើងខ្ញុំពិតជាចង់ឱ្យរាជរដ្ឋាភិបាលធ្វើការអនុវត្តនូវប្រព័ន្ធនេះប្រកបដោយចេរភាព និងប្រកបដោយប្រសិទ្ធភាពផងដែរ។ ដើម្បីឱ្យការប្រតិបត្តទៅលើប្រព័ន្ធខាងលើប្រកបទៅដោយភាពជោគជ័យយើងខ្ញុំសូមផ្តល់នូវអនុសាសន៍មួយចំនួនដូចខាងក្រោមៈ

- ធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយតាមគ្រប់មធ្យោបាយដូចជា ទូរទស្សន៍ វិទ្យុ និងប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀត អំពីការចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម និងសារៈប្រយោជន៍នៃការប្រើប្រាស់របស់វាទៅដល់ម្ចាស់យានយន្ត និងលើកទឹកចិត្តអោយគាត់ប្រើប្រាស់អោយបានច្រើន។
- ពង្រឹកការអនុវត្តដោយធ្វើការ បង្កើននូវធនធានមនុស្សដែលមានបច្ចេកទេសនូវក្នុងការគ្រប់គ្រងប្រព័ន្ធនេះឱ្យកាន់តែច្រើន និងមានកញ្ចប់ថវិកាមួយច្បាស់លាស់សម្រាប់ទំនុកបម្រុងទៅលើដំណើរការនេះ។

# ឯកសារយោង

១. ច្បាប់ស្តីពី ច្បាប់ចរាចរណ៍ឆ្នាំ ២០០៧

២. សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសាធារណៈការ និងដឹកជញ្ជូន ស្តីពី គម្រោងទំនើបកម្មប្រព័ន្ធចុះបញ្ជី និងត្រួតតពិនិត្យបច្ចេកទេសយានយន្ត កាលពី ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៨

៣. បទបង្ហាញស្តីពី ប្រព័ន្ធស្វ័យប្រវត្តិកម្ម ប្តូរ ពន្យារ និងចុះបញ្ជីបណ្ណបើកបរ ចុះបញ្ជីយានយន្ត និងត្រួតពិនិត្យបច្ចេកទេសយានយន្ត (ឆៀក) ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៦

៤. បទបង្ហាញរបស់ក្រសួងសាធារណៈការ និងដឹកជញ្ជូននៅ CJCC ថ្ងៃទី ២៣ ខែ កម្ភុះ ឆ្នាំ ២០១៦

៥. ប្រសាន៍របស់នាយករដ្ឋមន្ត្រី ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៧

៦. ទេសរដ្ឋមន្ត្រី ស៊ុន ចានថុល ចុះត្រួតពិនិត្យការប្រើសេវាចុះបញ្ជីយាយន្តតាមអនឡាញ (Online) នៅក្រុមហ៊ុនលក់យានយន្តថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៧

៧. កិច្ចប្រជុំគណៈកម្មការសម្របសម្រលរួមលើកទី ៣ ស្តីពី គម្រោមទំនើបកម្មប្រព័ន្ធចុះបញ្ជី និងត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត MVRI ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៧

៨. ពិធីដាក់ឱ្យដំណើរការជាផ្លូវការប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះ ត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ ផ្តល់ប័ណ្ណបើកយានយន្ត កម្មវិធីយល់ដឹងពីទ្រឹស្តីនៃការបើកបរលើទូរសព្ទ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៧

៩. ការចុះចែកខិតប័ណ្ណផ្សាព្វផ្សាយអំពី ប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួងសាធារណៈការ និងដឹកជញ្ជូន ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៧

១០. ពិព័រប្រព័ន្ធស្វ័ប្រវត្តិកម្មរបស់ក្រសួងសាធារណៈការ និងដឹកជញ្ជូននៅក្នុងកិច្ចប្រជុំ IELMIN ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៧

១១. គណៈប្រតិភូនៃសាធារណៈរដ្ឋសហភាពមីយ៉ាន់ម៉ាមកទស្សនៈកិច្ចសិក្សានៅកម្ពុជា ដើម្បីស្វែងយល់អំពីកិច្ចដំណើការនៃការផ្តដល់សេវាចុះបញ្ជីយានយន្ត

១២.ការចុះបញ្ជី និងត្រួតពិនិត្យយានយន្តជាកត្តាដែលធ្វើមានសុវត្ថិភាពចរាចរណ៍

១៣. សិក្ខាសាលាអំពី រដ្ឋាភិបាលអេឡិចត្រូនិក ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៤

១៤. https://en-wikiedra.org/wiki (Moto vehicle registration)

១៥. https://www.quora.com

# បញ្ជីឧបសម្ព័ន្ធ

| លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នឹងក្រសួងសាធារណការ និងដឹកជញ្ជូន | |
|---|---|
| ១ | លិខិតលេខ ១៥៨ សក.ដជគ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧ ការជម្រាបមកលោក លោកស្រី ជាម្ចាស់ក្រុមហ៊ុន ឬហាងលក់យានយន្ត |
| ២ | លិខិតលេខ០១២ សជណ សក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៧ សេចក្តីជូនដំណឹង ស្តីពីការអនុញ្ញាតឲ្យហាងលក់យានយន្តចុះបញ្ជីយានយន្តជូនអតិថិជន |
| ៣ | លិខិតលេខ ០១២៥សជណ សក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ សេចក្តីជូនដំណឹង |
| ៤ | ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន |
| ៥ | អនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសាធារណការ និងដឹកជញ្ជូន |
| ៦ | ប្រកាសលេខ០៤៦ សក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៧ ស្តីពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីយានយន្ត ការផ្តល់ផ្លាកលេខសម្គាល់យានយន្ត និងការលុបចេញពីបញ្ជីយានយន្ត |
| ៧ | តារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ ០១០ សហវ.ប្រក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន |

# ឧបសម្ព័ន្ធ

# ព្រះរាជក្រម

នស/រកម/០១៩៦/០៣

## យើង

## ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

## ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

## ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

---

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពនៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន ដែលរដ្ឋសភាបានអនុម័តនាសម័យ ប្រជុំលើកទី ៥ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅៈ

# ច្បាប់
# ស្តីពី
# ការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន

**មាត្រា ១ :** ត្រូវបានបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន ចំណុះរាជរដ្ឋាភិបាលកម្ពុជា។

**មាត្រា ២ :** ក្រសួងសាធារណការ និងដឹកជញ្ជូន មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យសាធារណការ និងដឹកជញ្ជូន នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣ :** ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលមានអមដោយរដ្ឋលេខាធិការ និង ឬអនុរដ្ឋលេខាធិការតាមការចាំបាច់។

**មាត្រា ៤ :** ការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា ៥ :** បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៦ :** ច្បាប់នេះ ត្រូវប្រកាសជាប្រញាប់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

**ព្រះបរមលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រីទី ១**　　**នាយករដ្ឋមន្ត្រីទី ២**

**នរោត្តម រណឫទ្ធិ**　　**ហ៊ុនសែន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

---

**រាជរដ្ឋាភិបាលកម្ពុជា**

អនុក្រឹត្យ/១៩ អនក្រ.បក                                                        ០៣ មីនា ១៩៩៨

# អនុក្រឹត្យ

# ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ

# របស់ក្រសួងសាធារណការ និងដឹកជញ្ជូន

# រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ១៩៩៤ និង ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសម្រួល សមាសភាព រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ ១៩៩៧ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ដែលមានបេសកកម្មពិសេស
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន
- តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៨

## សម្រេច

## ជំពូក ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះរៀបចំបណ្ដាញអង្គភាព នៃក្រសួងសាធារណការ និងដឹកជញ្ជូន និងកំណត់បេសកកម្ម របស់ក្រសួង និងមុខការ នៃបណ្តាអគ្គនាយកដ្ឋាន និងនាយកដ្ឋាននានា ។

## ជំពូក ២

## បេសកកម្ម និងរចនាសម្ព័ន្ធ

**មាត្រា ២.-**

ក្រសួងសាធារណការ និងដឹកជញ្ជូនត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ប្រគល់បេសកកម្មអោយដឹកនាំ និងគ្រប់គ្រង វិស័យសាធារណការ និងដឹកជញ្ជូន នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.-**

ក្រសួងសាធារណការ និងដឹកជញ្ជូនមានមុខងារនិងភារកិច្ចដូចតទៅ:

- គ្រប់គ្រងការអនុវត្តនយោបាយជាតិ លើវិស័យសំណង់សាធារណៈទូទៅ ដោយរៀបចំគោលការណ៍ច្បាប់ និងសហការជាមួយស្ថាប័ននានា ដើម្បីអភិវឌ្ឍន៍ប្រទេសជាតិ ។
- សាងសង់ ថែទាំ គ្រប់គ្រងលើហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពាន កំពង់ផែ ផ្លូវដែក ផ្លូវទឹក និង អាគាររដ្ឋ ។
- ដាក់ចេញបទបញ្ជាស្តីពីអាជីវកម្ម លើហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ផ្លូវដែក ផ្លូវទឹក ។
- ដាក់ចេញបទបញ្ជា និងត្រួតពិនិត្យលើការដឹកជញ្ជូន តាមផ្លូវថ្នល់ ផ្លូវដែក ផ្លូវទឹក ។
- ចូលរួម និងសហការដាក់ចេញច្បាប់ បទប្បញ្ញត្តិ បទដ្ឋាននានា ដែលពាក់ព័ន្ធនឹងសំណង់ ។
- សាងសង់សំណង់ផ្សេងៗ ទៀត ដែលរាជរដ្ឋាភិបាលប្រគល់អោយ ។
- សហការជាមួយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល រាល់ការងារសំណង់ផ្លូវអាកាស ។

**មាត្រា ៤.-**

ក្រសួងសាធារណការ និងដឹកជញ្ជូនមានរចនាសម្ព័ន្ធដូចតទៅ:

- អគ្គាធិការដ្ឋាន
- អគ្គនាយកដ្ឋាន រដ្ឋបាលរួមមាន:
  + នាយកដ្ឋាន រដ្ឋបាល
  + នាយកដ្ឋាន បុគ្គលិកធនធានមនុស្ស
  + នាយកដ្ឋាន គណនេយ្យ ហិរញ្ញវត្ថុ
  + នាយកដ្ឋាន ផែនការ
- អគ្គនាយកដ្ឋានសាធារណការនិងសំណង់រួមមាន:
  + នាយកដ្ឋាន ផ្លូវថ្នល់
  + មជ្ឈមណ្ឌលគ្រឿងចក្រធំៗ

• មន្ទីរពិសោធន៍ ស្រាវជ្រាវ បច្ចេកទេស
• នាយកដ្ឋាន សំណង់អាគារ
• នាយកដ្ឋាន ផ្លូវទឹក
• នាយកដ្ឋាន សំណង់ផ្លូវអាកាស

- អគ្គនាយកដ្ឋានដឹកជញ្ជូនមាន:
  • នាយកដ្ឋាន ដឹកជញ្ជូន ផ្លូវគោក
  • នាយកដ្ឋាន ដឹកជញ្ជូន ផ្លូវទឹក
  • នាយកដ្ឋាន នាវាចរណ៍សមុទ្រ
- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អង្គភាពមូលដ្ឋាន
  • មន្ទីរសាធារណការ និងដឹកជញ្ជូនតំបន់
  • មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុង
- សហគ្រាស សាធារណៈ
- អង្គការស្វ័យតការកសាធារណៈ នៅក្រោមអាណាព្យាបាលក្រសួង និងស្ថាប័នពាក់ព័ន្ធនានាដែលជារបស់ក្រសួងសាធារណការ និងដឹកជញ្ជូនដោយយោងតាមឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ ។

## ជំពូកទី ៣
## អគ្គាធិការដ្ឋាន

**មាត្រា ៥.-**

អគ្គាធិការដ្ឋានរបស់ក្រសួងសាធារណការ និងដឹកជញ្ជូនមានតួនាទីៈ

- ធ្វើអធិការកិច្ចជាប្រចាំនៅគ្រប់អង្គភាពក្រោមឱវាទក្រសួង ។
- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី ពីការប្រព្រឹត្តទៅរបស់អង្គភាព ដែលបានធ្វើអធិការកិច្ចហើយនោះ និងពីមធ្យោបាយកែលំអការប្រព្រឹត្តទៅរបស់អង្គភាពទាំងនោះ ។
- ប្រតិបត្តិភារកិច្ចតាមការដែលរដ្ឋមន្ត្រីបានប្រគល់ជូន ។

អគ្គាធិការដ្ឋានដឹកនាំដោយអគ្គាធិការមួយរូប អមដោយអគ្គាធិការរងជាជំនួយតាមការចាំបាច់ ។

## ជំពូក ៤
## អគ្គនាយកដ្ឋាន រដ្ឋបាល

**មាត្រា ៦.-**

អគ្គនាយកដ្ឋានរដ្ឋបាល ទទួលបន្ទុកធ្វើការងាររដ្ឋបាល សំរាប់ជួយគ្រប់គ្រងកិច្ចការរដ្ឋបាល បុគ្គលិក សំភារៈ គណនេយ្យ ហិរញ្ញវត្ថុ ព្រមទាំងធ្វើការសិក្សា និងផែនការការងារ ។

អគ្គនាយកដ្ឋានដឹកនាំដោយ អគ្គនាយកមួយរូប និងមានអគ្គនាយករងជាជំនួយការតាមការចាំបាច់ ។ អគ្គនាយកដ្ឋាននេះមាននាយកដ្ឋានចំនួន ៤ ដូចមានចែងក្នុងមាត្រាខាងក្រោម ។

**មាត្រា ៧.-**

នាយកដ្ឋាន រដ្ឋបាលទទួលបន្ទុក:

- សំរបសំរួលសកម្មភាពគ្រប់ផ្នែក របស់ក្រសួងនៅថ្នាក់កណ្តាល រវាងថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋាន ក្រោមចំណុះ ។
- គ្រប់គ្រង និងរក្សាឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង ។
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល ។
- សរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់ក្រសួង ។

**មាត្រា ៨.-**

នាយកដ្ឋានបុគ្គលិក និងធនធានមនុស្សទទួលបន្ទុក:

- គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈ របស់ក្រសួងដោយទំនាក់ទំនង និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។
- រៀបចំលិខិតបទដ្ឋានសំរាប់ការគ្រប់គ្រងអាជីព ។
- ធ្វើកម្មវិធីពិពណ៌នាតំណែងឯកទេស និងធនធានមនុស្សរបស់ក្រសួង ។
- វាយតម្លៃតម្រូវការ ក្នុងការបណ្តុះបណ្តាលបុគ្គលិក ។
- រៀបចំគោលនយោបាយបណ្តុះបណ្តាលដំបូង និងបន្តដោយទំនាក់ទំនង និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងអនុវត្តគោលនយោបាយនោះ ។
- រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងនាគំរោងប្រតិបត្តិ ។
- គ្រប់គ្រងការងារសង្គមរបស់ក្រសួង ។

**មាត្រា ៩.-**

នាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុទទួលបន្ទុក:

- កាន់បញ្ជីជាប្រចាំនូវសាលាកប័ត្រ និងគណនេយ្យរូបធាតុ ។
- តាមដានវិភាគអំពីសកម្មភាពទាំងហិរញ្ញវត្ថុ និងបញ្ជីគណនី ។
- លើកគំរោងថវិកាក្រសួង និងតាមដានពីការប្រតិបត្តិ ។
- ប្រមូលចំណូលដោយបានសមស្របតាមច្បាប់ហិរញ្ញវត្ថុ ។
- ប្រមូលពន្ធ និងសំរបសំរួលជំពូកថវិកា ។
- ប្រមូលពន្ធ និងសំរបសំរួលរាល់ចំណាយរបស់ក្រសួង ។
- គ្រប់គ្រងគណនេយ្យរបស់ការអនុវត្តលទ្ធកម្មសាធារណៈ ។

**មាត្រា ១០.-**

នាយកដ្ឋានផែនការទទួលបន្ទុក:

- ប្រមូលផ្តុំតម្រូវការធនធានកម្មវិធីវិនិយោគគ្រប់គ្រងការរៀបចំផ្គុំផែនការ: និងបរិក្ខាររបស់ក្រសួង
- តាមដានការគ្រប់គ្រងគណនីពិសេស ។
- ត្រួតពិនិត្យបច្ចេកទេស នៃការប្រតិបត្តិ លទ្ធកម្មសាធារណៈ
- រៀបចំ និងគ្រប់គ្រងប្រព័ន្ធទិន្នន័យរបស់ក្រសួង និងកំណត់កម្មវិធីអភិវឌ្ឍន៍លើគ្រប់វិស័យទាំងអស់
- ធ្វើកម្មវិធីសហប្រតិបត្តិការក្នុង និងក្រៅប្រទេសលើវិស័យសាធារណការ និងដឹកជញ្ជូន ។
- សំរបសំរួលជំនួយពីបរទេស និងត្រួតពិនិត្យការអនុវត្ត ។

## ជំពូក ៥

## អគ្គនាយកដ្ឋានសាធារណការ និងសំណង់

**មាត្រា ១១.-**

អគ្គនាយកដ្ឋានសាធារណការ និងសំណង់ទទួលបន្ទុកគ្រប់គ្រង ដឹកនាំ តាមដាន និងត្រួតពិនិត្យការងារ សាងសង់ជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពាន តាមដាន ត្រួតពិនិត្យវិស័យសាងសង់ អាគារសាធារណៈ និងគ្រប់គ្រង សាងសង់ ការជួសជុលបរិក្ខារឧបករណ៍របស់រដ្ឋ ដែលរាជរដ្ឋាភិបាលប្រគល់ អោយក្រសួង ។

អគ្គនាយកដ្ឋានដឹកនាំដោយ អគ្គនាយកមួយរូប និងមានអគ្គនាយករងជាជំនួយតាមការចាំបាច់ ។ អគ្គនាយក ដ្ឋាននេះ មាននាយកដ្ឋានចំនួន ៦ ដូចមានចែងក្នុងមាត្រាខាងក្រោម ។

**មាត្រា ១២.-**

នាយកដ្ឋានផ្លូវថ្នល់ទទួលបន្ទុក:

- សម្ថិទ្ធិ ថែទាំគ្រប់គ្រង និងអភិវឌ្ឍបទបញ្ញត្តិការពារហេដ្ឋារចនាសម្ព័ន្ធផ្លូវជាតិ ផ្លូវថ្នល់ ផ្លូវលំ សិក្សាការប្រឹក្សា កំណត់ស្តង់ដា សាកល្បង និងផ្តល់ព្រូង ។

ក្នុងតួនាទីនេះនាយកដ្ឋានផ្លូវថ្នល់មានមុខងារដូចតទៅ:

**ក. រៀបចំកម្មវិធីការងារថែទាំ និងគ្រប់គ្រងផ្លូវថ្នល់ និងស្ពាន:**

- ធ្វើសារពើភណ្ឌ និងប្រើប្រាស់ទិន្នន័យដោយបង្កើតប្រព័ន្ធព័ត៌មានបណ្តាញផ្លូវ ។
- គ្រប់គ្រងឯកសារបច្ចេកទេសប្រើផ្លូវ និងសិក្សាការរុះរើ ព្រមទាំងគតិមានទាំងឡាយដែល ពាក់ព័ន្ធនឹងបណ្តាញផ្លូវថ្នល់ ។
- រៀបចំផែនការ ថែទាំមធ្យោបាយ តាមដាន និងត្រួតពិនិត្យលើការងារថែទាំ ។
- គ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈ ផ្លូវថ្នល់ ផ្លូវទឹក និងផ្លូវដែក ។

**ខ. គ្រប់គ្រងការដ្ឋានផ្លូវថ្នល់ និងស្ពាន:**

- សិក្សាគ្រប់គ្រង និងរៀបចំកម្មវិធីនីតិវិធីការថែទាំផ្លូវថ្នល់ និងស្ពាន ។

- រៀបចំលិខិត រៀបចំឯកសារបច្ចេកទេសតាមជាន់ និងត្រួតពិនិត្យការដ្ឋានផ្ទាល់ និងស្ពាន។
- វាយតម្លៃការដ្ឋានដែលសាងសង់រួចហើយ។
- គ្រប់គ្រងកំពង់ចម្លង សាឡាង។

**មាត្រា ១៣.-**

មជ្ឈមណ្ឌលគ្រឿងចក្រធំៗ ទទួលបន្ទុក:

- សិក្សាស្រាវជ្រាវ ធ្វើគំរោង និងសាងសង់ការដ្ឋានធំៗ។
- គ្រប់គ្រង និង ត្រួតពិនិត្យបរិក្ខារ និងគ្រឿងចក្រនៅក្រោមអាណាព្យាបាល។
- សិក្សា និងរៀបចំបណ្តុះបណ្តាលបុគ្គលិកខាងគ្រឿងចក្រ។

**មាត្រា ១៤.-**

មជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេស ទទួលបន្ទុក:

- រៀបចំបទដ្ឋានបច្ចេកទេស និងការងារសំរាប់អនុវត្ត។
- សិក្សាស្រាវជ្រាវ រៀបចំគំរោងសំណង់សាធារណការ។
- ពិសោធន៍សំណង់ គុណភាពសំភារៈ និងបង្កើតវិធីថ្មីៗដើម្បីសំរាប់អនុវត្តការងាររបស់ក្រសួង។

**មាត្រា ១៥.-**

នាយកដ្ឋានសំណង់អាគារ ទទួលបន្ទុក:

- ចូលរួមសហការជាមួយ ស្ថាប័នពាក់ព័ន្ធ សិក្សាគំរោង រៀបចំ ត្រួតពិនិត្យ តាមដាន វិស័យសាងសង់អាគារសាធារណៈ និងវិស័យឯកជន។
- គ្រប់គ្រងការសាងសង់ និងការជួសជុលអគាររដ្ឋបាលរបស់រដ្ឋ ដែលរាជរដ្ឋាភិបាលបានប្រគល់ឲ្យក្រសួង។
- សហការជាមួយស្ថាប័នផ្សេងៗ ក្នុងការបង្កើតការិយាល័យសំណង់។
- ស្នើបង្កើតសំណុំរឿងសិក្សា សំណង់អាគារ និងធ្វើការណែនាំសំរាប់ធានាសុវត្ថិភាព សាធារណៈ។
- ដាក់ចេញកម្មវិធី និងរៀបចំផែនការនៃកិច្ចសហប្រតិបត្តិការនៃបណ្តាការវិនិយោគធំៗ សំរាប់ផ្សព្វផ្សាយទូទៅ។
- ត្រួតពិនិត្យបច្ចេកទេស និងហិរញ្ញវត្ថុ នៃសមិទ្ធិកម្មប្រតិបត្តិការថែទាំ។
- អនុវត្តបទបញ្ជាស្តីពីអនុញ្ញាតសាងសង់។
- អនុវត្តបទដ្ឋានបច្ចេកទេស និងសុវត្ថិភាពការសាងសង់។
- ស្រង់ប្រមូល និងប្រើប្រាស់ទិន្នន័យស្ថិតិ នៃបណ្តាផ្នែកសាងសង់អាគារសាធារណៈ និងឯកជន។

**មាត្រា ១៦.-**

នាយកដ្ឋានផ្លូវទឹក ទទួលបន្ទុក:

- សិក្សា និងធ្វើការងាររៀបចំច្បាប់ដែលទាក់ទងដល់ការដឹកជញ្ជូន នាវាចរណ៍ តាមផ្លូវទឹកសម្រាប់ជាតិ ។
- ធ្វើប្លង់ និងថែទាំមាត់ទន្លេ ច្រកទន្លេ ច្រកសមុទ្រ ។
- កសាងស្លាក និងគោលសញ្ញា នាវាចរណ៍ តាមផ្លូវទន្លេ ។
- រៀបចំវិធានការណ៍ទាំងឡាយ ដែលទាក់ទងនឹងសុវត្ថិភាព ដល់នាវាចរណ៍ និងចរន្តផ្លូវទឹក ។
- ផ្សព្វផ្សាយជូនដំណឹងដល់អ្នកបើកបរ នូវឧបសគ្គដែលកើតឡើងថ្មី ។
- រៀបចំសារាចរបទបញ្ជាចរាចរណ៍ក្នុងកំពង់ ផ្ទះបណ្តែតទឹក ។ល។ ចតនៅតាមកន្លែងសមស្រប ត្រឹមត្រូវ ។
- ពិនិត្យលើការស្នើសុំសាងសង់ក្នុងទន្លេ ក្រោមមេខ្សែលើអាកាសឆ្លងកាត់ទន្លេ ។
- សិក្សាស្រាវជ្រាវលើការចោះ និងការការពារច្រាំង ។
- លើកវិធានការណ៍ និងប្រមូលព្យាករណ៍ធាតុអាកាសនៃជំនោរទឹក ដើម្បីបំពេញការងារជីកដីក្នុងទន្លេ ។
- សាងសង់កំពង់ផែក្នុងស្រុក ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន ។
- គ្រប់គ្រងដីសណ្តផ្លូវទឹក ។
- ពិនិត្យសំណើសុំយកទឹកពីទន្លេ និងបញ្ចូលទឹកមកក្នុងទន្លេវិញ ដែលអាចមានផលប៉ះពាល់ ដល់ជំរៅទឹក ។
- កសាងទូក និងគ្រឿងបន្លាស់ចក្រដឹកជញ្ជូនដែលប្រើប្រាស់ក្នុងនាវាចរណ៍ ។
- កត់ត្រាស្ថិតិកំពស់ទឹក តាមដានធ្វើទូទាត់ប្រាប់សម្រាប់ការដឹកជញ្ជូនផ្លូវទឹក ។

**មាត្រា ១៧.-**

នាយកដ្ឋានសំណង់ផ្លូវអាកាស ទទួលបន្ទុកសហការជាមួយរដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល ក្នុងការរៀប សាងសង់ អាកាសយានដ្ឋាន:

- សិក្សាត្រួតពិនិត្យ និងតាមដានលើការងារសាងសង់អាកាសយានដ្ឋានទូទាំងប្រទេស ទាំងសំណង់ ធ្វើដោយរដ្ឋ ព្រមទាំងសំណង់ធ្វើដោយឯកជន ដើម្បីផលប្រយោជន៍រដ្ឋ ... ជាដើម ។
- សិក្សា ជ្រើសរើស ត្រួតពិនិត្យ ទីតាំងសំណង់ថ្មីនៃអាកាសយានដ្ឋាន ។
- រៀបចំគោលការណ៍បច្ចេកទេស ស្តីពីការសាងសង់អាកាសយានដ្ឋាន ។

## ជំពូក ៦
## អគ្គនាយកដ្ឋានដឹកជញ្ជូន

**មាត្រា ១៨.-**

អគ្គនាយកដ្ឋានដឹកជញ្ជូនទទួលបន្ទុកគ្រប់គ្រង ត្រួតពិនិត្យមធ្យោបាយដឹកជញ្ជូនតាម ផ្លូវគោក ផ្លូវទឹក ផ្លូវសមុទ្រ និងតាក់តែងរៀបចំបទប្បញ្ញត្តិទាំងឡាយ ដើម្បីសម្រួល និងធានាសុវត្ថិភាពដល់ការ ធ្វើចរាចរ ។

អគ្គនាយកដ្ឋានដឹកនាំដោយអគ្គនាយកដ្ឋានមួយរូប និងមានអគ្គនាយករងជាជំនួយការ តាមការចាំបាច់ ។

អគ្គនាយកដ្ឋានដឹកជញ្ជូន មាននាយកដ្ឋានចំនួន៣ ដូចមានចែងក្នុងមាត្រាខាងក្រោម ។

**មាត្រា ១៩.-**

នាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ទទួលបន្ទុក:

- រៀបចំតាក់តែង តាក់តែងបទបញ្ជាត្រួតពិនិត្យ រក្សាសុវត្ថិភាព និងសម្របសម្រួលការដឹកជញ្ជូន ផ្លូវគោក ជាអាទិ៍ ផ្លូវថ្នល់ ផ្លូវទីក្រុង និងផ្លូវដែក ។

**ក. ការគ្រប់គ្រងតាមពត៌មានវិទ្យាលើរាល់សកម្មភាព:**

- ធ្វើពត៌មានវិទ្យា ប័ណ្ណបើកបរ វិញ្ញាបនបត្រចុះបញ្ជី និងលិខិតអនុញ្ញាតស្តីពីការដឹកជញ្ជូន ។
- គ្រប់គ្រងសំណុំសាលាកប័ត្រនៃ វិញ្ញាបនបត្រ ។
- រៀបចំស្ថិតិគ្រប់សកម្មភាពរបស់នាយកដ្ឋាន ។

**ខ. ការត្រួតពិនិត្យបទបញ្ជា និងត្រួតពិនិត្យការធ្វើចរាចរ:**

- តាក់តែងបទបញ្ជាទាំងឡាយទាក់ទងនឹងការធ្វើចរាចរតាមផ្លូវថ្នល់ ។
- ត្រួតពិនិត្យការបណ្តុះបណ្តាល មេប្រយោគប្រឡងប័ណ្ណបើកបរ និងគ្រូបង្ហាត់រថយន្ត រៀនបើកបរ ។
- សម្របសម្រួល សកម្មភាពទប់ស្កាត់គ្រោះថ្នាក់តាមផ្លូវ និងត្រួតពិនិត្យចរាចរតាមផ្លូវថ្នល់ ។
- ផ្តល់អោយ និងចេញប័ណ្ណចរាចរ ។

**គ. ការរៀបចំតាក់តែង និងការគ្រប់គ្រងការដឹកជញ្ជូនផ្លូវគោក:**

- សិក្សាដាក់អោយអនុវត្តត្រួតពិនិត្យបទបញ្ជា សម្របសម្រួល និងសុខដុម ការដឹកជញ្ជូនអ្នកដំណើរ ។
- សិក្សា និងដាក់អោយអនុវត្ត និងត្រួតពិនិត្យបទបញ្ជាសម្របសម្រួលការដឹកជញ្ជូនទំនិញតាមផ្លូវ ។
- ចេញលិខិតអនុញ្ញាតអោយដឹកជញ្ជូនអន្តរជាតិ និងក្នុងតំបន់សំរាប់អ្នកដំណើរ និងទំនិញ ។
- ណែនាំដល់ក្រុង និងទីប្រជុំជនក្នុងការដឹកជញ្ជូនតាមក្រុង និងទីប្រជុំជន ។
- សម្របសម្រួលបច្ចេកទេស និងតារាងតំលៃផ្លូវដែក ផ្លូវថ្នល់ ។

**មាត្រា ២០.-**

នាយកដ្ឋានដឹកជញ្ជូនផ្លូវទឹកទទួលបន្ទុក:

- គ្រប់គ្រងការដឹកជញ្ជូនតាមទន្លេ ព្រែក ស្ទឹង បឹង ។
- តាក់តែង និងត្រួតពិនិត្យការគោរពបទបញ្ជា និងវិន័យនៃការដឹកជញ្ជូនតាមផ្លូវទន្លេ ។
- ត្រួតពិនិត្យ និងតាមដានមធ្យោបាយ អភិវឌ្ឍន៍ការដឹកជញ្ជូនទាំងនោះ ។

- ចេញប័ណ្ណបើកបរ ប័ណ្ណសំគាល់នាវា ប័ណ្ណយន្តការី និងលិខិតអនុញ្ញាតធ្វើអាជីវកម្ម ។
- ត្រួតពិនិត្យលើតំបន់ផែទាំងឡាយនៅក្នុងស្រុក ។
- ត្រួតពិនិត្យលើពលកម្មិកៈនាវាក្នុងប្រទេស ។

**មាត្រា ២១.-**

នាយកដ្ឋាននាវាជំនួញសមុទ្រទទួលបន្ទុក:

**ក. ការងាររដ្ឋបាលទូទៅ នៃកងនាវាជំនួញរបស់រដ្ឋ និងគ្រឹះស្ថានសាធារណៈរបស់រដ្ឋ:**

- គ្រប់គ្រងការងារដឹកជញ្ជូនទៀតទាត់តាមផ្លូវសមុទ្រ និងត្រួតពិនិត្យការអនុវត្តបទបញ្ជា ត្រួតពិនិត្យនាវាវិចារកិច្ចក្រៅកិច្ចព្រមព្រៀង (armaments hors conference)
- ស្រាវជ្រាវដើម្បីបញ្ចូលនាវាវិចារកិច្ចរបស់រដ្ឋ ក្នុងចលនាដឹកនាំតាមឯកទេស ។
- សិក្សា និងវាយតម្លៃគុណភាព និងបរិមាណតម្រូវការរបស់រដ្ឋស្តីពីកងនាវាជំនួញ ។
- សិក្សាដើម្បីការកែលំអ នៃនាវាវិចារកិច្ចរបស់រដ្ឋ ។
- ស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកទេសស្តីពីទស្សនាទាននាវា ។
- ណែនាំឯកសារបច្ចេកទេស ជំនួយដល់ការវិនិយោគនាវាចរណ៍ ។
- រៀបចំបែបបទអំពីលក្ខន្តិកៈនាវាសមុទ្រ ។

**ខ. ការងារសហប្រតិបត្តិការផ្លូវសមុទ្រក្នុងតំបន់ និងអន្តរជាតិ:**

- តាក់តែង និងស្នើមូលដ្ឋានបច្ចេកទេសនៃកិច្ចសហប្រតិបត្តិការផ្លូវសមុទ្រក្នុងតំបន់ និងអន្តរជាតិ ។
- គ្រប់គ្រងកិច្ចសហប្រតិបត្តិការផ្លូវសមុទ្រក្នុងតំបន់ និងអន្តរជាតិ ។
- គ្រប់គ្រងកិច្ចព្រមព្រៀងទ្វេភាគីនៃកិច្ចសហប្រតិបត្តិការក្នុងវិស័យដឹកជញ្ជូនតាមផ្លូវសមុទ្រ ។
- សមាជអន្តរជាតិក្នុងវិស័យដឹកជញ្ជូនតាមផ្លូវសមុទ្រ ។

**គ. គ្រប់គ្រងវិជ្ជាជីវៈបន្ទាប់បន្សំក្នុងការដឹកជញ្ជូនតាមផ្លូវសមុទ្រ ។**

## ជំពូក ៧

## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា ២២.-**

ខុទ្ទកាល័យរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលកំណត់តាមបទប្បញ្ញត្តិនៃ អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ដូចមានចែងក្នុងមុខបទខាងលើ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន ។

## ជំពូក ៨

## អគ្គាធិការដ្ឋាន

**មាត្រា ២៣.-**

នៅទូទាំងព្រះរាជាណាចក្រកម្ពុជាមានមន្ទីរសាធារណការ និងដឹកជញ្ជូនតំបន់ និងមន្ទីរ សាធារណការ និងដឹកជញ្ជូនខេត្ត ក្រុង ដែលទទួលបន្ទុកអនុវត្ត និងសំរបសំរួលសកម្មភាពរបស់ក្រសួង។ ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពមូលដ្ឋានត្រូវកំណត់ដោយអនុក្រឹត្យដោយឡែកទៀត។

## ជំពូក ៥

## សហគ្រាសសាធារណៈ

**មាត្រា ២៤.-**

ក្រសួងសាធារណការ និងដឹកជញ្ជូនមានសហគ្រាសសាធារណៈដូចខាងក្រោម:

**I.** អង្គភាពដែលស្ថិតក្រោម អនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ ១៩៩៧

**ក. សហគ្រាសសាធារណៈក្រោមអាណាព្យាបាលមានលក្ខន្តិកៈ កំណត់តាមលេខរៀងខាងមុខ:**

១. រាជាយស្ម័យយានកម្ពុជា

២. កំពង់ផែក្រុងព្រះសីហនុ

៣. កំពង់ផែភ្នំពេញ

៤. នាយកដ្ឋាន ភ្នាក់ងារកម្ពុជានាវាចរ (កាំសាប)

៥. ក្រុមហ៊ុន ដឹកជញ្ជូនដោយរថយន្ត

៦. ក្រុមហ៊ុន ដឹកជញ្ជូនអ្នកដំណើរ

៧. នាយកដ្ឋាន សំភារៈ

៨. សហគ្រាស សំណង់ភ្នំពេញ

៩. សហគ្រាស គ្រឿងចក្រសំណង់ ជួសជុល

១០. សហគ្រាស សិក្សាស្រាវជ្រាវ គូរប្លង់

១១. សហគ្រាស សំណង់កំពង់ផែ

១២. សហគ្រាស សំភារៈដឹកជញ្ជូន

១៣. សហគ្រាស ក្រួសឡាក់ តាអេម

១៤. សហគ្រាស សំណង់សិល្បការ

១៥. រោងចក្រ ឥដ្ឋពណ៌

១៦. សាលាបង្រៀនបើកបររថយន្ត

**ខ. អង្គភាពជួលតាមកិច្ចសន្យា និងនីតិវិធីកំពុងដំណើរការ:**

១៧. រោងចក្រ អារឈើ

១៨. រោងចក្រ ឡូត្ស

១៩. រោងចក្រ ហ្វ៊ីប្រូស៊ីម៉ង់ត៍

២០ រោងជាង ជួសជុលនាវាលេខ ៧ មករា

**II.** សហគ្រាសសាធារណៈមានលក្ខន្តិកៈកំណត់រួចហើយ:

ក. គ្រឹះស្ថានសាធារណៈមានឧបនិស្ស័យរដ្ឋបាលសេដ្ឋកិច្ច មន្ទីរពិសោធន៍សំណង់ និងសាធារណការ ( ម.ព.ស.ស)

ខ. សហគ្រាសសាធារណៈរដ្ឋចំរុះឯកជន:

ក្រុមហ៊ុន កម្ពុជាខាវ៉ាដឹកជញ្ជូន ( កាំត្រង់ស៊ុប)

## ជំពូក ១០

## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា ២៥.-**

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមល័ក្ខខ័ណ្ឌ ដែលបានបញ្ជាក់ក្នុង អនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៤ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកាក្នុងបណ្តាក្រសួង។

## ជំពូក ១១

## អវសានប្បញ្ញត្តិ

**មាត្រា ២៦.-**

ការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងនៅរដ្ឋបាលកណ្តាល ចាប់ពីថ្នាក់ក្រោម នាយកដ្ឋានចុះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន។

**មាត្រា ២៧.-**

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី និងរដ្ឋលេខាធិការទាំងអស់ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមភារកិច្ចរៀងៗខ្លួន។

**មាត្រា ២៨.-**

អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែមីនា ឆ្នាំ១៩៩៨

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មិនា ឆ្នាំ ១៩៩៨

## អង្គការលេខរបស់ក្រសួងក្រសួងសាធារណការ និងដឹកជញ្ជូន



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន
លេខ: ០១៥៥ សាធា.សក.

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង

ក្នុងគោលបំណង ដើម្បីបង្វិតសេវាឲ្យទៅជិតប្រជាពលរដ្ឋ បង្កភាពងាយស្រួល ចំណេញពេលវេលា និងកាត់បន្ថយការចំណាយរបស់ប្រជាពលរដ្ឋក្នុងការទទួលបានសេវាសាធារណៈប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ក្រសួងសាធារណការ និងដឹកជញ្ជូន មានកិត្តិយសសូមជម្រាបជូនសាធារណជនទាំងអស់ ឲ្យបានជ្រាបថា៖ ក្រសួងបានសម្រេចដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវមណ្ឌលប្តូរ និងពន្យារបណ្ណបើកបរយានយន្ត នៅ**ជាន់ទីមួយ ផ្សារទំនើប AEON Mall** មានអាសយដ្ឋានស្ថិតនៅក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពី**ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦** តទៅ។ មណ្ឌលនេះអនុញ្ញាតឲ្យប្រជាជនខ្មែរ ទាំង២៥រាជធានី-ខេត្ត អាចមកទទួលសេវា ជារៀងរាល់ថ្ងៃ ចាប់ពី**ម៉ោង០៨ព្រឹក រហូតដល់ ម៉ោង១០យប់**។

បានទទួលសេចក្តីជំណឹងនេះ សូមសាធារណជនទាំងអស់ ដែលមានបណ្ណបើកបរយានយន្តអស់សុពលភាព ខូច ឬបាត់បង់ដោយប្រការណាមួយ អាចអញ្ជើញទៅកាន់មណ្ឌលប្តូរ និងពន្យារបណ្ណបើកបរយានយន្ត នៅផ្សារទំនើប AEON Mall ចាប់ពីកាលបរិច្ឆេទដាក់ឲ្យដំណើរការជាផ្លូវការខាងលើនេះតទៅ។

សូមអរគុណ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣*៥៣*៥

ក្រសួងសាធារណការ និងដឹកជញ្ជូន

លេខៈ ០១៤ សសណ.សក

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអនុញ្ញាតឱ្យហាងលក់យានយន្តចុះបញ្ជីយានយន្តជូនអតិថិជន

ក្នុងគោលបំណងបង្កើតសេវាសាធារណៈជិតប្រជាពលរដ្ឋ និងជំរុញនូវការផ្តល់សេវាឱ្យបានរហ័សទាន់ចិត្ត និងមានប្រសិទ្ធភាពខ្ពស់ ក្រសួងសាធារណការ និងដឹកជញ្ជូនបានដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធស្វ័យប្រវត្តិកម្ម នៃការចុះបញ្ជីយានយន្ត កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧កន្លងមកនេះ។ ទន្ទឹមនឹងនេះដែរ ក្រសួងសាធារណការ និងដឹកជញ្ជូនសូមជម្រាបជូន និងអំពាវនាវដល់សាធារណជន និងម្ចាស់ហាងលក់យានយន្តទាំងអស់(ក្រុមហ៊ុនមេ សាខា និងសាខារងនៅទូទាំងប្រទេស)ដូចខាងក្រោម៖

១. ដើម្បីបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋ ក្រសួងអនុញ្ញាតឱ្យហាងលក់យានយន្តទាំងអស់មានសិទ្ធិចុះបញ្ជីយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីផ្តល់បណ្ណសម្គាល់ និងបំពាក់ផ្លាកលេខ ជូនអតិថិជនរបស់ខ្លួននៅហាងតែម្តង ដោយគ្រាន់តែដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតបំពេញបែបបទចុះបញ្ជីយានយន្តទៅអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក។

២. ហាងលក់យានយន្តត្រូវធានាថាយានយន្តដែលបានលក់ជូនអតិថិជនពីហាងរបស់ខ្លួនត្រូវមានបណ្ណសម្គាល់ និងបំពាក់ផ្លាកលេខ ដើម្បីអាចធ្វើចរាចរណ៍លើផ្លូវថ្នល់បាន។

៣. ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៧ ខាងមុខនេះតទៅហាងលក់យានយន្តទាំងអស់ត្រូវមានលិខិតអនុញ្ញាតបំពេញបែបបទចុះបញ្ជីយានយន្ត និងបំពេញកាតព្វកិច្ចចុះបញ្ជី ដើម្បីផ្តល់បណ្ណសម្គាល់ និងផ្លាកលេខជូនអតិថិជនរបស់ខ្លួន។ ក្នុងន័យនេះម្ចាស់ហាងលក់យានយន្តដែលមិនទាន់មានលិខិតអនុញ្ញាត ត្រូវរួសរាន់មកដាក់ពាក្យសុំនៅអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោកកុំបីខាន។

៤. ម្ចាស់យានយន្តត្រូវស្នើសុំចុះបញ្ជីយានយន្តរបស់ខ្លួននៅហាងលក់យានយន្ត។ក្នុងករណីនេះ ការចុះបញ្ជីយានយន្តនៅមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្តឬទីតាំងផ្តល់សេវាសាធារណៈដទៃទៀតមិនត្រូវបានអនុញ្ញាតឡើយចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៧ ខាងមុខនេះតទៅ ។

ក្រសួងសាធារណការ និងដឹកជញ្ជូន សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់យានយន្ត និងម្ចាស់ហាងលក់យានយន្តទាំងអស់ បានជ្រាបជាព័ត៌មាន និងសហការអនុវត្តតាមការជូនដំណឹងនេះ ដោយជាក់ខាន។

សូមអរគុណ!

មហាវិថីព្រះនរោត្តម កែងផ្លូវលេខ១០៦, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ, កម្ពុជា
Corner Norodom Blvd, St. 106, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia
ទូរស័ព្ទ/ទូរសារៈ (៨៥៥) ០២៣ ៤២៦ ៦៤០ (៨៥៥) ០២៣ ៤២៧ ៨៦២
Tel/Fax: (855) 23 426 640, (855) 23427862 គេហទំព័រ៖ www.mpwt.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសាធារណការ និងដឹកជញ្ជូន**
**អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក**
លេខ:...១៥៤១...សក.ផដគ..

រាជធានីភ្នំពេញ, ថ្ងៃទី.២៥..ខែ.មេសា....ឆ្នាំ២០១៧

**ជម្រាបមក**
**លោកឧកញ៉ា លោក-លោកស្រី ជាម្ចាស់ក្រុមហ៊ុន ឬហាងលក់យានយន្ត**

**យោង** ៖ សេចក្តីជូនដំណឹងលេខ ០១២ សជណ សក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៧ ស្តីពីការអនុញ្ញាតឲ្យហាងលក់យានយន្តចុះបញ្ជីយានយន្តជូនអតិថិជន។

យោងតាមសេចក្តីជូនដំណឹងខាងលើ អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក មានកិត្តិយសសូមគោរពអញ្ជើញម្ចាស់ ឬតំណាងក្រុមហ៊ុន ឬហាងលក់យានយន្តទាំងអស់ មកដាក់"**ពាក្យសុំលិខិតអនុញ្ញាតបំពេញបែបបទចុះបញ្ជីយានជំនិះតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម**" នៅអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ឲ្យបានមុនថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៧។ ការចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម មានគោលបំណងធានាឲ្យការបំរើសេវាសាធារណៈចុះបញ្ជីជូនប្រជាពលរដ្ឋមានភាពឆាប់រហ័ស និងកាត់បន្ថយការចំណាយកម្រៃក្រៅផ្លូវការ ខុសពីតម្លៃដែលកំណត់ដោយក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកឧកញ៉ា លោក-លោកស្រី ជាម្ចាស់ក្រុមហ៊ុន ឬហាងលក់យានយន្ត** មកដាក់ពាក្យសុំលិខិតអនុញ្ញាតកុំបីអាក់ខាន។

សូម **លោកឧកញ៉ា លោក -លោកស្រី** ទទួលនូវការគោរពរាប់អានអំពីខ្ញុំ។

**អគ្គនាយក**

**ពៅ_ម៉ាលី**

**បញ្ជាក់ ៖**
ព័ត៌មានបន្ថែមសូមទំនាក់ទំនងទូរស័ព្ទលេខ ៖
- កញ្ញា គា សុខា (069 70 71 50)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសាធារណការ និងដឹកជញ្ជូន**

លេខ: ០៨៦ សក

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧

# ប្រកាស
## ស្តីពី
## បែបបទនិងនីតិវិធីនៃការចុះបញ្ជីយានយន្ត ការផ្តល់ផ្លាកលេខសម្គាល់យានយន្ត និងការលុបចេញពីបញ្ជីយានយន្ត

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ២១៦អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ៧៧អនក្រ.បក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការចេញផ្លាកលេខសម្គាល់យានជំនិះ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសាធារណការនិងដឹកជញ្ជូន



អគារលេខ ១ មហាវិថី ព្រះនរោត្តម, ភ្នំពេញ
ទូរស័ព្ទ-ទូរសារ: (៨៥៥) ២៣ ៤២៧ ៨៦២

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងគ្រប់គ្រងយានជំនិះ ដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព និងសិទ្ធិជាកម្មសិទ្ធិលើយានជំនិះ។

**ប្រការ២.-**

ប្រកាសនេះ មានគោលដៅដូចខាងក្រោម៖

- កំណត់បែបបទនិងនីតិវិធីនៃការចុះបញ្ជីផ្តល់បណ្ណសម្គាល់និងផ្លាកលេខយានជំនិះ
- កំណត់នីតិវិធីនៃការលុបយានជំនិះដែលបានចុះបញ្ជីចេញពីបញ្ជីយានជំនិះ។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការចុះបញ្ជីផ្តល់បណ្ណសម្គាល់និងផ្លាកលេខយានជំនិះ និងការលុបចេញពីបញ្ជីយានជំនិះ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤.-**

ម្ចាស់យានជំនិះ ត្រូវដាក់ពាក្យសុំចុះបញ្ជីយានជំនិះតាមប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះ ដែលមានអាសយដ្ឋាន vehicle.mpwt.gov.kh ទៅទីតាំងផ្តល់សេវាសាធារណៈ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន តាមគំនូសបំព្រួញអំពីដំណើរការចុះបញ្ជីយានជំនិះដូចមានចែង ក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ ដោយត្រូវភ្ជាប់សំណុំឯកសារដូចខាងក្រោម៖

**១. យានជំនិះដែលជាកម្មសិទ្ធិឯកជន**

- ពាក្យសុំចុះបញ្ជីយានជំនិះ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ
- បង្កាន់ដៃពន្ធយានយន្ត
- វិក្កយបត្រហាងលក់យានយន្ត។

**២. យានជំនិះដែលជាកម្មសិទ្ធិក្រុមហ៊ុន**

- ពាក្យសុំចុះបញ្ជីយានជំនិះ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលក្ខន្តិកៈក្រុមហ៊ុន ឬវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម
- វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ
- បង្កាន់ដៃពន្ធយានយន្ត
- វិក្កយបត្រហាងលក់យានយន្ត។

**៣. យានជំនិះដែលជាកម្មសិទ្ធិក្រសួងស្ថាប័នរដ្ឋ**

- ពាក្យសុំចុះបញ្ជីយានជំនិះ
- លិខិតស្នើសុំរបស់ក្រសួងស្ថាប័នសាមី
- វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ
- បង្កាន់ដៃពន្ធយានយន្តជាបន្ទុករបស់រដ្ឋ។

ករណីស្នើសុំចុះបញ្ជីយានជំនិះ ដែលមានបង្កាន់ដៃពន្ធយានយន្ត ត្រូវភ្ជាប់ជាមួយនឹងវិក្កយបត្រហាងលក់យានយន្ត។

ក្នុងករណីអាសយដ្ឋានបច្ចុប្បន្ន ខុសពីអាសយដ្ឋានដែលមាននៅក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ត្រូវភ្ជាប់សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ហើយចំពោះជនបរទេស ត្រូវភ្ជាប់លិខិតឆ្លងដែន និងសៀវភៅស្នាក់នៅ។

**៤. យានជំនិះដែលជាកម្មសិទ្ធិស្ថានទូត អង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល**

- ពាក្យសុំចុះបញ្ជីយានជំនិះ
- លិខិតអនុញ្ញាតពីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ឬក្រសួងមហាផ្ទៃ
- វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ
- បង្កាន់ដៃពន្ធយានយន្តជាបន្ទុករបស់រដ្ឋ។

ករណីស្នើសុំចុះបញ្ជីយានជំនិះ ដែលមានបង្កាន់ដៃពន្ធយានយន្ត ត្រូវភ្ជាប់ជាមួយនឹងវិក្កយបត្រហាងលក់យានយន្ត។

**៥. យានជំនិះក្រោមរបបគយនាំចូលបណ្ដោះអាសន្ន**

- ពាក្យសុំចុះបញ្ជីយានជំនិះ
- លិខិតអនុញ្ញាតពីក្រសួងស្ថាប័នសាមី
- វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ
- បង្កាន់ដៃពន្ធយានយន្តក្រោមរបបគយនាំចូលបណ្ដោះអាសន្ន។

**ប្រការ៥.-**

ម្ចាស់យានជំនិះ ដែលមានអាសយដ្ឋានអចិន្ត្រៃយ៍នៅរាជធានីខេត្តណា ត្រូវយកលេខចុះបញ្ជីរបស់រាជធានីខេត្តនោះ។

ម្ចាស់យានជំនិះ ជាក្រសួងស្ថាប័នរដ្ឋ ស្ថានទូត អង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងម្ចាស់យានជំនិះក្រោមរបបគយនាំចូលបណ្ដោះអាសន្ន ត្រូវដាក់ពាក្យសុំចុះបញ្ជីយានជំនិះ តាមប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះ ទៅអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក។

**ប្រការ៦.-**

ទម្រង់ពាក្យសុំចុះបញ្ជីយានជំនិះ មានចែងក្នុងឧបសម្ព័ន្ធទី២នៃប្រកាសនេះ។

ទម្រង់បណ្ណសម្គាល់យានជំនិះ មានចែងក្នុងឧបសម្ព័ន្ធទី៣នៃប្រកាសនេះ។

**ប្រការ៧.-**

ម្ចាស់យានជំនិះ មានកាតព្វកិច្ចបំពេញបែបបទលុបចេញពីបញ្ជីយានជំនិះនូវយានជំនិះទាំងឡាយដែលឈប់ប្រើប្រាស់ ក្នុងករណីដូចខាងក្រោម៖

- យានខូចទាំងស្រុង មិនអាចប្រើប្រាស់តទៅទៀតបាន
- យានត្រូវបាននាំចេញទៅក្រៅប្រទេស។
- មូលហេតុផ្សេងៗទៀត។

ម្ចាស់យានជំនិះ ត្រូវដាក់លិខិតស្នើលុបចេញពីបញ្ជីយានជំនិះនូវយានជំនិះរបស់ខ្លួនទៅទីតាំងផ្តល់សេវាសាធារណៈណាមួយរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន ដោយត្រូវភ្ជាប់មកជាមួយនូវៈ

- បណ្ណសម្គាល់យានជំនិះ
- ផ្លាកលេខយានជំនិះ។

ក្រោយទទួលបានលិខិតស្នើលុបចេញពីបញ្ជីយានជំនិះ បណ្ណសម្គាល់យានជំនិះ និងផ្លាកលេខយានជំនិះ អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ត្រូវចេញលិខិតបញ្ជាក់អំពីការលុបចេញពីបញ្ជីយានជំនិះនូវយានជំនិះនោះ។

លិខិតស្នើលុបចេញពីបញ្ជីយានជំនិះ និងលិខិតបញ្ជាក់អំពីការលុបចេញពីបញ្ជីយានជំនិះមានចែងក្នុងឧបសម្ព័ន្ធទី៤នៃប្រកាសនេះ។

**ប្រការ៨.-**

គ្រប់សំណុំឯកសារចុះបញ្ជីយានជំនិះ ត្រូវរក្សាទុកនៅៈ

- អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ចំពោះរថយន្ត រ៉ឺម៉ក សឺមីរ៉ឺម៉ក
- មន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានីខេត្ត ចំពោះទោចក្រយានយន្ត ត្រីចក្រយានយន្ត យានយន្តកសិកម្មកែច្នៃ។

**ប្រការ៩.-**

ក្នុងករណីបណ្ណសម្គាល់យានជំនិះរហែកឬខូច ឬយានជំនិះត្រូវប្តូរពណ៌ឬប្តូរម៉ាស៊ីន ឬម្ចាស់យានជំនិះប្តូរអាសយដ្ឋាន ម្ចាស់យានជំនិះ ត្រូវដាក់ពាក្យសុំប្តូរបណ្ណសម្គាល់យានជំនិះថ្មី ដោយត្រូវភ្ជាប់មកជាមួយនូវបណ្ណសម្គាល់យានជំនិះចាស់។

ក្នុងករណីផ្លាកលេខយានជំនិះបាក់ រហែក រលុបអក្សរឬលេខ ម្ចាស់យានជំនិះ ត្រូវដាក់ពាក្យសុំប្តូរយកផ្លាកលេខយានជំនិះថ្មី ដោយត្រូវភ្ជាប់មកជាមួយនូវផ្លាកលេខយានជំនិះចាស់។

ក្នុងករណីបណ្ណសម្គាល់យានជំនិះ ឬផ្លាកលេខយានជំនិះបាត់ ម្ចាស់យានជំនិះ ត្រូវដាក់ពាក្យសុំទុតិយតាបណ្ណសម្គាល់យានជំនិះ ឬផ្លាកលេខយានជំនិះ។

ទម្រង់ពាក្យសុំប្តូរបណ្ណសម្គាល់យានជំនិះ ផ្លាកលេខយានជំនិះ ឬទុតិយតាបណ្ណសម្គាល់យានជំនិះ ផ្លាកលេខយានជំនិះ មានចែងក្នុងឧបសម្ព័ន្ធទី៥នៃប្រកាសនេះ។

**ប្រការ១០.-**

ក្រសួងសាធារណការនិងដឹកជញ្ជូន អនុញ្ញាតឲ្យម្ចាស់ហាងលក់យានយន្ត បំពេញបែបបទចុះបញ្ជីយានជំនិះ ឲ្យបានចប់សព្វគ្រប់ មុននឹងប្រគល់ឲ្យអ្នកទិញ។

ម្ចាស់ហាងលក់យានយន្ត ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតបំពេញបែបបទចុះបញ្ជីយានជំនិះតាមប្រព័ន្ធស្វ័យប្រវត្តិកម្មផ្តល់លិខិតអនុញ្ញាតបំពេញបែបបទចុះបញ្ជីយានជំនិះទៅទីតាំងផ្តល់សេវាសាធារណៈដែលកំណត់ដោយក្រសួងសាធារណការនិងដឹកជញ្ជូន ដោយត្រូវភ្ជាប់សំណុំឯកសារដូចខាងក្រោមៈ

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម
- បណ្ណប៉ាតង់។

ក្នុងករណីអាសយដ្ឋានបច្ចុប្បន្ន ខុសពីអាសយដ្ឋានដែលមាននៅក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ត្រូវភ្ជាប់សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ហើយចំពោះជនបរទេស ត្រូវភ្ជាប់លិខិតឆ្លងដែន និងសៀវភៅស្នាក់នៅ។

លិខិតអនុញ្ញាតបំពេញបែបបទចុះបញ្ជីយានជំនិះ មានសុពលភាព ៣(បី)ឆ្នាំ។ លិខិតអនុញ្ញាតបំពេញបែបបទចុះបញ្ជីយានជំនិះ ត្រូវអស់សុពលភាព ក្នុងករណីដូចខាងក្រោម៖

- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម អស់សុពលភាព
- ប្តូរអាសយដ្ឋានហាងលក់យានយន្ត
- មិនគោរពតាមច្បាប់ជាធរមាន។

ទម្រង់ពាក្យសុំលិខិតអនុញ្ញាតបំពេញបែបបទចុះបញ្ជីយានជំនិះ និងលិខិតអនុញ្ញាតបំពេញបែបបទចុះបញ្ជីយានជំនិះ មានចែងនៅក្នុងឧបសម្ព័ន្ធទី៦ នៃប្រកាសនេះ។

**ប្រការ១១.-**

ការចុះបញ្ជីយានជំនិះ ការអនុញ្ញាតបំពេញបែបបទចុះបញ្ជីយានជំនិះ ត្រូវបង់កម្រៃសេវាសាធារណៈ តាមការកំណត់ក្នុងប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**ប្រការ១២.-**

អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ត្រូវគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងណែនាំអនុវត្តការចុះបញ្ជីយានជំនិះ ការអនុញ្ញាតបំពេញបែបបទចុះបញ្ជីយានជំនិះ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ១៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៤.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានផែនការនិងគោលនយោបាយ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកនៃអគ្គនាយកដ្ឋានសាធារណការ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារកម្ម អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានជំនាញ ប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានីខេត្ត ប្រធានអង្គភាពក្រោមឱវាទក្រសួងសាធារណការនិងដឹកជញ្ជូន និងអ្នកពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តរៀងៗខ្លួន តាមខ្លឹមសារនៃប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ស៊ុន ចាន់ថុល**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រសួងស្ថាប័នពាក់ព័ន្ធ
- សាលារាជធានីខេត្ត
  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៨
  " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

គំនូសបំព្រួញអំពីដំណើរការចុះបញ្ជីយានជំនិះ

ប្រកាសលេខ...០៤៦......... ចុះថ្ងៃទី២៧.... ខែ...មករា.... ឆ្នាំ..២០១៧...

ស្តីពីបែបបទនិងនីតិវិធីនៃការចុះបញ្ជីយានយន្ត

ការផ្តល់ផ្លាកលេខសម្គាល់យានយន្ត និងការលុបចេញពីបញ្ជីយានយន្ត




**សម្គាល់៖** ប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះ មានអាសយដ្ឋាន៖ vehicle.mpwt.gov.kh

**ឧបសម្ព័ន្ធទី២**

ទម្រង់ពាក្យសុំចុះបញ្ជីយានជំនិះ

ប្រកាសលេខ......០៤៦........ ចុះថ្ងៃទី.២៧.... ខែ.មករា...... ឆ្នាំ.២០១៧....

ស្តីពីបែបបទនិងនីតិវិធីនៃការចុះបញ្ជីយានយន្ត

ការផ្តល់ផ្លាកលេខសម្គាល់យានយន្ត និងការលុបចេញពីបញ្ជីយានយន្ត

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំចុះបញ្ជីយានជំនិះ

ម្ចាស់កម្មសិទ្ធិ.......................................................ភេទ.............សញ្ជាតិ........................

អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ.......................................................អាសយដ្ឋានបច្ចុប្បន្ន - ផ្ទះលេខ

..............ផ្លូវ...........................ភូមិ.........................................សង្កាត់/ឃុំ..........................................

ខណ្ឌ/ក្រុង/ស្រុក..................................................រាជធានី/ខេត្ត....................................................

លេខទូរស័ព្ទ............................................អ៊ីម៉ែល.....................................................។

សំណើសុំចុះបញ្ជីយានជំនិះ ដែលមានភិនភាគដូចខាងក្រោម៖

ផ្លាកលេខ.....................................................ម៉ាក .................................................

ប្រភេទ........................................................ទំហំស៊ីឡាំង...................................

ពណ៌..........................................................ទម្ងន់ទទេ...........................................

លេខម៉ាស៊ីន..................................................ទម្ងន់ផ្ទុក..........................................

លេខសាក់ស៊ី.................................................ចំនួនភ្លៅ............................................

លេខតួ........................................................។

| លេខតួ | លេខសាក់ស៊ី |
|---|---|
| (បិទលេខផ្តិតចម្លងជាក់ស្តែង) | (បិទលេខផ្តិតចម្លងជាក់ស្តែង) |

ធ្វើនៅ..............ថ្ងៃទី.........ខែ..........ឆ្នាំ.........

**ហត្ថលេខា ឬស្នាមមេដៃ**

**ឯកសារភ្ជាប់៖**

- បង្កាន់ដៃពន្ធយានយន្ត
- វិក្កយបត្រឬលិខិតលក់ក្នុងករណីយានជំនិះជាកម្មសិទ្ធិឯកជន
- វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- លិខិតស្នើសុំរបស់សាមីក្រសួង ស្ថាប័នក្នុងករណីយានជំនិះ ជាកម្មសិទ្ធិរបស់រដ្ឋ ស្ថានទូត អង្គការក្រោមរបបគយនាំចូលបណ្តោះអាសន្ន

## ឧបសម្ព័ន្ធទី៣

ទម្រង់បណ្ណសម្គាល់យានជំនិះ

ប្រកាសលេខ...០៤៦... ចុះថ្ងៃទី...២៧... ខែ...មករា... ឆ្នាំ...២០១៧...

ស្តីពីបែបបទនិងនីតិវិធីនៃការចុះបញ្ជីយានយន្ត

ការផ្តល់ផ្លាកលេខសម្គាល់យានយន្ត និងការលុបចេញពីបញ្ជីយានយន្ត

### ទម្រង់បណ្ណសម្គាល់យានជំនិះសម្រាប់ទោចក្រយានយន្ត






ទម្រង់បណ្ណសម្គាល់យានជំនិះសម្រាប់រថយន្ត រ៉ឺម៉ក សឺមីរ៉ឺម៉ក






## ឧបសម្ព័ន្ធទី៤

ទម្រង់លិខិតស្នើសុំលុបចេញពីបញ្ជីយានជំនិះ និងលិខិតបញ្ជាក់អំពីការលុបចេញពីបញ្ជីយានជំនិះ

ប្រកាសលេខ.....០៤២........ ចុះថ្ងៃទី.២៧.... ខែ..មករា...... ឆ្នាំ.២០១៧...

ស្តីពីបែបបទនិងនីតិវិធីនៃការចុះបញ្ជីយានយន្ត

ការផ្តល់ផ្លាកលេខសម្គាល់យានយន្ត និងការលុបចេញពីបញ្ជីយានយន្ត

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតស្នើសុំលុបចេញពីបញ្ជីយានជំនិះ

ម្ចាស់កម្មសិទ្ធិ.......................................................ភេទ.............សញ្ជាតិ........................

អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ......................................................អាសយដ្ឋានបច្ចុប្បន្ន - ផ្ទះលេខ

...............ផ្លូវ.............ភូមិ......................សង្កាត់/ឃុំ.........................

ខណ្ឌ/ក្រុង/ស្រុក.....................................................រាជធានី/ខេត្ត....................................................

លេខទូរស័ព្ទ................................................អ៊ីម៉ែល.......................................................។

សំណើសុំលុបយានជំនិះ ដែលមានភិនភាគដូចខាងក្រោម៖

ផ្លាកលេខ..................................................

ម៉ាក ........................................................

ពណ៌.........................................................

លេខតួ/សាក់ស៊ី..........................................

មូលហេតុ៖

- យានជំនិះ ខូចប្រើប្រាស់លែងកើត
- យានជំនិះ ត្រូវបាននាំចេញទៅក្រៅប្រទេស
- មូលហេតុផ្សេងទៀត។

ធ្វើនៅ.........................ថ្ងៃទី.......ខែ.......ឆ្នាំ...............

ហត្ថលេខា ឬស្នាមមេដៃ

**ឯកសារភ្ជាប់៖**

- បណ្ណសម្គាល់យានជំនិះ
- ផ្លាកលេខយានជំនិះ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- លិខិតបញ្ជាក់អំពីមូលហេតុនៃការលុបយានជំនិះ បើមាន



ក ព

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតបញ្ជាក់អំពីការលុបចេញពីបញ្ជីយានជំនិះ

អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក សូមបញ្ជាក់ថាយានជំនិះដែលមានភិនភាគដូចខាងក្រោម៖

ផ្លាកលេខ......................................................ម៉ាក ............................................................ ពណ៌.........................................................លេខតួ/សាក់ស៊ី............................................................ ម្ចាស់កម្មសិទ្ធិឈ្មោះ................................អាសយដ្ឋានបច្ចុប្បន្ន - ផ្ទះលេខ .................................... ផ្លូវលេខ....................សង្កាត់/ឃុំ..............................ខណ្ឌ/ក្រុង/ស្រុក............................................ រាជធានី/ខេត្ត....................................ត្រូវបានលុបចេញពីបញ្ជីយានជំនិះតាមការលិខិតស្នើសុំលេខ ................................ ចុះថ្ងៃទី........ខែ........... ឆ្នាំ ............ តទៅ។

មូលហេតុ៖...........................................................................................................។

លិខិតនេះចេញជូនសាមីខ្លួនយកទៅប្រើប្រាស់តាមការដែលអាចប្រើបាន។

រាជធានីភ្នំពេញ ថ្ងៃទី...... ខែ............ឆ្នាំ.................

**អគ្គនាយក**

## ឧបសម្ព័ន្ធទី៥

ទម្រង់ពាក្យសុំប្តូរបណ្ណសម្គាល់យានជំនិះ ផ្លាកលេខយានជំនិះ
ឬទុតិយតាបណ្ណសម្គាល់យានជំនិះ ផ្លាកលេខយានជំនិះ
ប្រកាសលេខ.....០៤៦.........ចុះថ្ងៃទី២៧ ខែ.មករា. ឆ្នាំ២០១៧....
ស្តីពីបែបបទនិងនីតិវិធីនៃការចុះបញ្ជីយានយន្ត
ការផ្តល់ផ្លាកលេខសម្គាល់យានយន្ត និងការលុបចេញពីបញ្ជីយានយន្ត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំប្តូរបណ្ណសម្គាល់យានជំនិះ ផ្លាកលេខយានជំនិះ ឬទុតិយតា បណ្ណសម្គាល់យានជំនិះ ផ្លាកលេខយានជំនិះ

ម្ចាស់កម្មសិទ្ធិ.......................................................ភេទ.............សញ្ជាតិ........................
អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ.......................................................អាសយដ្ឋានបច្ចុប្បន្ន - ផ្ទះលេខ
.......................ផ្លូវ........................ភូមិ..............................សង្កាត់/ឃុំ..............................................
ខណ្ឌ/ក្រុង/ស្រុក.........................................................រាជធានី/ខេត្ត..............................................
លេខទូរស័ព្ទ..................................................អ៊ីម៉ែល.....................................................។

សំណើសុំប្តូរ/ទុតិយតា........................................................................សម្រាប់យានជំនិះ
ដែលមានភិនភាគដូចខាងក្រោម៖

ផ្លាកលេខ.........................................................ម៉ាក ..................................................
ប្រភេទ.............................................................ទំហំស៊ីឡាំង........................................
ពណ៌................................................................ទម្ងន់ទទេ............................................
លេខម៉ាស៊ីន......................................................ទម្ងន់ផ្ទុក............................................
លេខសាក់ស៊ី.....................................................ចំនួនភ្លៅ.............................................
លេខតួ.................................................................។

ធ្វើនៅ...............ថ្ងៃទី.......ខែ..........ឆ្នាំ.............
ហត្ថលេខា ឬស្នាមមេដៃ

**ឯកសារភ្ជាប់៖**
-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សម្រាប់កម្មសិទ្ធិករឯកជន
-បណ្ណសម្គាល់យានជំនិះ
-ផ្លាកលេខយានជំនិះ ក្នុងករណីប្តូរ
-លិខិតបញ្ជាក់ពីនគរបាលប៉ុស្តិ៍រដ្ឋបាល ក្នុងករណីទុតិយតា

**ឧបសម្ព័ន្ធទី៦**

ទម្រង់ពាក្យសុំលិខិតអនុញ្ញាតបំពេញបែបបទចុះបញ្ជីយានជំនិះ

និងលិខិតអនុញ្ញាតបំពេញបែបបទចុះបញ្ជីយានជំនិះ

ប្រកាសលេខ...០៤៦......... ចុះថ្ងៃទី២៧..... ខែ..មករា..... ឆ្នាំ២០១៧...

ស្តីពីបែបបទនិងនីតិវិធីនៃការចុះបញ្ជីយានយន្ត

ការផ្តល់ផ្លាកលេខសម្គាល់យានយន្ត និងការលុបចេញពីបញ្ជីយានយន្ត

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំលិខិតអនុញ្ញាតបំពេញបែបបទចុះបញ្ជីយានជំនិះ

ម្ចាស់កម្មសិទ្ធិ.......................................................ភេទ.............សញ្ជាតិ.....................................

អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ.....................................................អាសយដ្ឋានបច្ចុប្បន្ន - ផ្ទះលេខ

....................ផ្លូវ......................ភូមិ............................សង្កាត់/ឃុំ............................................

ខណ្ឌ/ក្រុង/ស្រុក..........................................រាជធានី/ខេត្ត......................................................

លេខទូរស័ព្ទ..........................................អ៊ីម៉ែល.....................................................។

សំណើសុំលិខិតអនុញ្ញាតបំពេញបែបបទចុះបញ្ជីយានជំនិះ.......................................

ក្រុមហ៊ុន/ហាងនាមៈ...........................................................................................

អាសយដ្ឋានៈ ......................................................................................................

..............................................................................................................................

.............................................................................................................។

ធ្វើនៅ.................ថ្ងៃទី........ខែ..........ឆ្នាំ.................

**ហត្ថលេខា និងត្រាក្រុមហ៊ុន**

**ឯកសារភ្ជាប់ៈ**

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

-វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម

-បណ្ណប៉ាតង់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន
អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក
លេខ៖.......................................

## លិខិតអនុញ្ញាតបំពេញបែបបទចុះបញ្ជីយានជំនិះ

នាមករណ៍ក្រុមហ៊ុន.................................................................................................................................
កម្មវត្ថុអាជីវកម្ម ...................................................................................................................................
អាសយដ្ឋាន ...........................................................................................................................................
.................................................................................................................................................
.................................................................................................................................................
កាលបរិច្ឆេទចេញ.........................................................................
កាលបរិច្ឆេទផុតសុពលភាព............................................................។

ម្ចាស់ហាងលក់យានយន្ត មានកាតព្វកិច្ចដូចខាងក្រោម៖

១. បំពេញបែបបទចុះបញ្ជីយានជំនិះ ក្នុងនោះយានយន្តត្រូវមានបណ្ណសម្គាល់ និងផ្លាកលេខយានជំនិះ មុននឹងប្រគល់យានយន្តទៅម្ចាស់យាន
២. ធានាថាយានជំនិះដែលបានលក់ មានពន្ធនាំចូលយានយន្តត្រឹមត្រូវ មិនមានការកែលេខតួ ឬលេខសាក់ស៊ី និងយថាប្រភេទរបស់យាន
៣. អនុវត្តតាមការណែនាំរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន និងច្បាប់ បទបញ្ញាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**អគ្គនាយក**